D25220
(DC-Cam)

# មជ្ឈមណ្ឌលឯកសារកម្ពុជា

**ករណី មន្ទីរសន្តិសុខ ១៣ (ម-១៣)**
**សម្ភាសន៍ជាមួយ ហម អ៊ិន អាយុ៨៧ឆ្នាំ**
**ភេទប្រុស រស់នៅភូមិស្តុកស្អាត ឃុំមានជ័យ ស្រុកទឹកឈូ ខេត្តកំពង់ស្ពឺ**
**ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៣**

**ផ្នែក «ក»**

រ៉ាស៊ី: ពូឈ្មោះអីដែរពូ?

អ៊ិន: ខ្ញុំឈ្មោះ ហម អ៊ិន

រ៉ាស៊ី: អាយុប៉ុន្មានហើយពូ?

អ៊ិន: អាយុ៨៩ឆ្នាំ ។

រ៉ាស៊ី: ពូរស់នៅភូមិហ្នឹងគេហៅភូមិអីដែរ?

អ៊ិន: ភូមិស្តុកស្អាត ឃុំមានជ័យ ស្រុកទឹកឈូ ។

រ៉ាស៊ី: ខេត្តកំពង់ស្ពឺ?

អ៊ិន: បាទ!

រ៉ាស៊ី: លើកមុន ខាងខ្ញុំ មជ្ឈមណ្ឌលឯកសារកម្ពុជាបានមកសម្ភាសន៍ពូម្តងរួចហើយ ហើយជួបពូម្តងនេះ ខ្ញុំចង់ឲ្យពូជួយបញ្ជាក់បន្ថែមពីគុក ១៣ ឬហៅថាមន្ទីរ ១៣ ដែលគ្រប់គ្រងដោយ តាឌុច ខ្ញុំចង់ឲ្យលោកពូរៀបរាប់តាំងពីដើម តាំងពីការបង្កើតគុកហ្នឹងពីឆ្នាំណា ហើយរហូតមកដល់គុកហ្នឹងត្រូវបញ្ចប់ តាមអ្វីដែលពូបានដឹង?

អ៊ិន: គុក បើតាមដែលខ្ញុំមៅជាប់គុកហ្នឹង ជាប់នៅក្នុងឆ្នាំ១៩៧៣ តែខ្ញុំបានឮអ្នកដែលនៅក្នុងហ្នឹងនិយាយថាឈ្មោះ ឌុច ហ្នឹងមិនមែនមកនៅក្នុងឆ្នាំ ៧៣ ទេ គឺមៅងតាំងពីឆ្នាំ១៩៧២ម៉េះ ។

រ៉ាស៊ី: អញ្ចឹងពូដឹងប្រវត្តិគុកហ្នឹងម៉េចខ្លះដែរ?

អ៊ិន: ប្រវត្តិគុកដែលខ្ញុំនៅនោះ ឃើញតែ ពិបាកភ្នែកមើលណាស់ កាលខ្ញុំនៅនោះ ឃើញតែវៃសម្លាប់ខ្លាំងក្លាណាស់ ។ មនុស្សចូលម៉ារយ ម៉ាពាន់ គឺជាអត់មានរស់មួយទេ ងាប់ទាំងអស់ កម្រមានរស់ណាស់ ។ ម៉ារយ ម៉ាពាន់ ម៉ាម៉ឺន គឺអត់មានរស់ទេ ។ ឲ្យតែចូលកន្លែងហ្នឹងគឺថាស្លាប់ហ្មងអត់មានកន្លែងវិលវិញទេ ។

រ៉ាស៊ី: គុកហ្នឹងស្ថិតនៅឯណាដែរពូ ក្នុងភូមិអី ឃុំអីដែរ?

អ៊ិន: គុកហ្នឹងស្ថិតនៅខាងជើង ថ្នគុប ។

រ៉ាស៊ី: ភូមិអីដែរ?

អ៊ីនៈ ភូមិថ្មគុប ហ្នឹង តែគ្រាន់វានៅខាងម៉ាចំហៀងមាត់ស្ទឹងឯណោះ ។ ឃ្លាតពីភូមិហ្នឹងប្រហែលជាដីម៉ាគីឡូ ។

វ៉ាស៊ីៈ ក្នុងឃុំអីដែរពូ?

អ៊ីនៈ ឃុំអមលាំង ។

វ៉ាស៊ីៈ ចុះពូមានដឹងទេ ទីតាំងគុកហ្នឹងកាលពីមុនរបបខ្មែរក្រហម មុនឆ្នាំ១៩៧២ហ្នឹង តើជាកន្លែងអីដែរ?

អ៊ីនៈ ពីដើមឡើយ ពីឆ្នាំ ៧២ តាមដែលខ្ញុំឮពួកម៉ាក់ខ្ញុំនិយាយមៅថា ឈ្មោះ ឌុច នេះមិនមែនកសាងមន្ទីរគុកហ្នឹងនៅកន្លែងហ្នឹងទេថានៅឯ ថ្មយោង ឯណាណោះ ។ ឈ្មោះថា មន្ទីរថ្មយោងលាក់ការណ៍នៅកណ្ដាលព្រៃភ្នំ ។

វ៉ាស៊ីៈ ហ្នឹងនៅឆ្នាំណាដែរពូ?

អ៊ីនៈ នៅឆ្នាំ១៩៧២ ។ ហើយដល់ពេលហ្នឹងអ្នកនៅក្នុងគុកហ្នឹងបានចាក់អ្នកកងការពារហ្នឹង បាញ់ត្រូវ អាខ្លះកាប់ត្រូវក អាខ្លះបាញ់ត្រូវក្បាល ហើយអាតូកអាតាក់ដ្បើលអស់ម៉ាសារហ្នឹងទៅបានរើគុកហ្នឹងមៅនៅយើង ថ្មគុប ។

វ៉ាស៊ីៈ បាទ! អញ្ចឹងបានន័យថាមុនដំបូងនៅថ្មយោង?

អ៊ីនៈ បាទ!

វ៉ាស៊ីៈ ហើយពេលដែលមានប្រតិកម្មដែលថាអ្នកទោសវៃជាមួយកងការពារហ្នឹង មន្ទីរហ្នឹងក៏រើមកដាក់នៅថ្មគុបនេះវិញ?

អ៊ីនៈ បាទ!

វ៉ាស៊ីៈ ហើយកាលហ្នឹង ឌុច អ្នកកាន់កាប់ដែរ?

អ៊ីនៈ បាទ! ឌុច អ្នកកាន់កាប់ ។

វ៉ាស៊ីៈ ហើយកាលហ្នឹងអ៊ំមានដឹងថា ឌុច អាយុប៉ុន្មានដែរ?

អ៊ីនៈ ខ្ញុំអត់បានដឹងទេ ប៉ុនខ្ញុំដឹងថា ឌុច ហ្នឹងបានប្រាប់ថាគាត់ឆ្នាំ មមី ។ ឪពុកខ្ញុំឆ្នាំ មមី ដែរគាត់ថាគាត់ឆ្នាំមមីដែរ ប៉ុន មមី លើខ្ញុំម៉ាខ្សែប៉ុណ្ណឹង ។

វ៉ាស៊ីៈ ពូមានដឹងថាមូលហេតុអីបានជាគេបង្កើតគុកហ្នឹងទេ?

អ៊ីនៈ ខ្ញុំអត់បានដឹងផង ស្រាប់តែគេចាប់ទៅដល់ហ្នឹង ។ ចាប់មិនមែនតែខ្ញុំទេ ចាប់ម៉ាដុំគ្នាខ្ញុំដែលនៅម៉ាអគ្គភាព គិតទៅអគ្គភាពសិល្បៈតំបន់៣២ហ្នឹង ចាប់ទៅសុទ្ធតែមេសំខាន់ៗទាំងអស់ ។ ក្រុមស្នូលហ្នឹងទាំងអស់យកទៅដាក់ ។

វ៉ាស៊ីៈ មានកំហុសអីបានជាយកទៅដាក់?

អ៊ុនៈ ទៅដល់ហ្នុងអត់ដឹងថាមានកំហុសអីទេ ។ ស្រឡាំងកាំងទាំងអស់គ្នាហ្នុងទាំងគ្នាខ្ញុំអីទាំងអស់អត់ដឹងថាមានកំហុសអី ហើយទៅដល់ហ្នឹងទៀតអ្នកដែលនៅក្នុងគុកហ្នឹង គេផ្តល់ពត៌មានមកថា បើកាលណាឆ្លើយថាអត់ ត្រូវតែស្លាប់ហ្នឹង ។

រ៉ាស៊ីៈ អ្នកណាអ្នកនិយាយអញ្ចឹង?

អ៊ុនៈ អ្នកនៅក្នុងគុកគេខ្សឹបប្រាប់ខ្ញុំណា៎! បើគេហៅសួរ កុំឆ្លើយថាអត់ បើឆ្លើយថាអត់គ្រោះថ្នាក់ហ្នុង

រ៉ាស៊ីៈ អត់ហ្នឹង បានន័យថាអត់មានធ្វើអីខុសអ្ហេះ?

អ៊ុនៈ បើយើងឆ្លើយថាអត់គេចាប់មោ៉ធ្វើអី ព្រោះតែយើងខ្មាំងហើយបានជាគេចាប់មោ៉ ។

ឃិនៈ អញ្ចឹងបានន័យថាយើងជាខ្មាំងជាអីហ្នុង?

អ៊ុនៈ បាទ!

រ៉ាស៊ីៈ ទោះយើងមិនមែនជាខ្មាំងក៏ដោយ?

អ៊ុនៈ បាទ! ឲ្យតែចាប់ទៅដល់កន្លែងនោះហើយ គឺពិតជាខ្មាំងហ្នុង ហើយមិនមែនតែខ្ញុំទេ ខ្ញុំឃើញច្រើនណាស់ ផ្នែកទព័ ផ្នែកប្រជាជន ឬក៏ទព័គ្នារកទិញអន្ទរអីនៅក្បែរៗនោះ ហើយកងការពារទៅចាប់ក្រញឹបដាក់ៗ ។

រ៉ាស៊ីៈ ទព័ហ្នឹងទព័ខាងណាដែរពូ?

អ៊ុនៈ ទព័ហ្នឹង ឃើញមោ៉ពីមុខៗអីអញ្ចឹងទៅ ទៅទិញស្បៀងទិញអីតាមភូមិតាមអីហ្នឹង?

រ៉ាស៊ីៈ ទព័ហ្នឹងមិនមែនទព័របស់ខ្មែរក្រហមទេអ្ហេះ ទព័របស់លន់ ណុលទេអ្ហី?

អ៊ុនៈ អត់ទេ! ទព័ហ្នឹងទព័របស់ខ្មែរក្រហម ។

រ៉ាស៊ីៈ ហ្នឹងនៅក្នុងឆ្នាំណាដែរ ដែលទព័ហ្នឹងមោ៉រកទិញអន្ទរទិញអី?

អ៊ុនៈ នៅឆ្នាំ ៧៣ ដែល ខ្ញុំនៅនេះហើយ ។

រ៉ាស៊ីៈ អញ្ចឹងពេលដែលពូបានទៅជាប់ហ្នឹង ខ្ញុំចង់ដឹងថាគុកហ្នឹងគេសង់ពីអី ហើយប្រក់អីដែរ?

អ៊ុនៈ គុកហ្នឹង របងវាខាងៗគេដាក់បង្គោលឈើ ប្រវែងបីម៉ែត្រមួយៗ គេវៃអានឯកណ្តាលហើយគេត្បាញឫស្សីពន្លៃនេះ បញ្ឈរឡើងលើទាំងអស់ជុំវិញ ។

រ៉ាស៊ីៈ ហើយកំពស់ប៉ុន្មានទៅ?

អ៊ុនៈ កំពង់ចុងឫស្សីយើងខ្ពស់៥ - ៦ម៉ែត្រ ។ ត្បាញបញ្ឈរឡើងលើ ។

រ៉ាស៊ីៈ ហើយចុះទំហំនៅខាងក្នុងវិញប្រហែលជាប៉ុន្មានម៉ែត្រ?

អ៊ុនៈ ទំហំនៅក្នុងហ្នុងប្រហែលជាខ្ទង់៣០ម៉ែត្របួនជ្រុង ។

រ៉ាស៊ីៈ ហ្នឹងគ្រាន់តែជុំវិញរបងទេអ្ហេះ?

អ៊ុនៈ បាទ! នៅជុំវិញរបង ហើយមានគេដាក់ខាងក្រៅនេះផ្សេងទៀត ។

រ៉ាស៊ីៈ អាក្រៅៗហ្នឹង បានន័យថាម៉េចទៅ?

អុិនៈ អាក្រៅៗហ្នឹង ដូចកន្លែងគាត់ (ឌុច) អញ្ចឹងណា គាត់ដាក់ឲ្យឃ្លាតឆ្ងាយពីគុកហ្នឹងទៅ ជិតហួសត្រពាំងអញ្ចឹងទៅ គាត់សម្រាប់យកអ្នកទោសសំខាន់ៗទៅសួរឯណោះទៅ ។ អានេះកន្លែងការពារ យកមកដាក់ដំបូង គឺសម្រាប់ការពាររត់ ។

ឃិនៈ ហើយបានយកមួយៗទៅសួរទៀត?

អុិនៈ បាទ! យកសួរហ្នឹង គេយកសួរនៅក្នុងរណ្ដៅដីខាងក្នុងណោះ ។ គេធ្វើរណ្ដៅដីហ្នឹងរណ្ដៅខាងក្រោមបួនម៉ែត្របួនជ្រុងអញ្ចឹង គេដាក់បង្គោលក្រាក់កណ្ដាល យកអ្នកទោសទៅសួរចម្លើយហ្នឹង គេចាក់សោរច្រវ៉ាក់ ។ រួចទាញអាច្រវ៉ាក់ហ្នឹងជាប់ហ្នឹងអាបង្គោលក្រាក់កណ្ដាលហ្នឹង តែខាងលើគេប្រក់ជិតដែរណា៎ ហើយបានគេយកអាច្រវ៉ាក់មៅចាក់សោរហ្នឹងហើយ បន្តជាប់អាបង្គោលក្រាក់ ហើយដៃហ្នឹងយកទៅដាក់នៅលើតុគេ មានអាម្ជុលគេមួយនោះ ម្ជុលគេកំណត់ហួសដល់ណោះ ( អុិន បានបង្ហាញតាមការធ្វើកាយវិការរបស់គាត់ពីការចាក់ម្ជុលទៅក្នុងម្រាមដៃ) ។ វ៉ៃហ្នឹងបន្ទាត់ វ៉ៃឲ្យគ្រប់ម្រាមទាំងអស់ហ្នឹង បានសួរអស់ចិត្តបានគេយកតាកាប់ (ដង្កាប់) ចាប់ទាញ ។

ភាស៊ីៈ អញ្ចឹងពូរៀបរាប់មុិញថា អាបង្គោលកំពស់ប៉ុន្មាននាក់ហ្នឹងមានទំហំ ៣០ម៉ែត្របួនជ្រុងអ្ហេះ ចុះនៅខាងក្នុងបរិវេណហ្នឹង មានធ្វើរោងអីទៀតទេ?

អុិនៈ ក្នុងបរិវេណហ្នឹងមានរណ្ដៅគុកជម្រៅទៅក្រោម ។

ភាស៊ីៈ អូរមានតែរណ្ដៅហ្នឹង អត់មានធ្វើរោងអីទេអ្ហេះ?

អុិនៈ មានធ្វើរោងដែរ ។

ភាស៊ីៈ មានដែរ?

អុិនៈ បាទ! រោងអាបង្ហារស្លឹកហ្នឹងណាស់ គេដាក់រោងបង្ហារស្លឹកទទេអញ្ចឹងទៅ ប្រហែលជា៤ម៉ែត្រ ៤ជ្រុងក្នុងម៉ាប្រឡោះៗ ។ មានអា៤ម៉ែត្រ៤ជ្រុងគេដាក់៣ប្រឡោះអញ្ចឹង គេដាក់រូងដីម៉ាប៉ុនណឹងអញ្ចឹងមៅ មៅរណ្ដៅខាងណោះមួយគេដាក់រូងដីខាងហ្នឹងទៀត រួចសង់អាបន្ទាយគេនៅតាមទំនប់ដីហ្នឹងទៅ ហើយអាចំពាមកៅស៊ូគេហ្នឹង បើនរណាបែបមិនស្រួល ចំពាមកៅស៊ូបាញ់ក្បាល

ភាស៊ីៈ ក្នុងម៉ាអន្លង់ហ្នឹងដាក់មនុស្សបានប៉ុន្មាននាក់?

អុិនៈ ក្នុងម៉ាអន្លង់ហ្នឹង ដាក់មនុស្សបាន២០នាក់ ។ គេមានអានងគេដាក់អញ្ចឹងមៅ ខ្ទោះគេក្រោមនេះ

ភាស៊ីៈ អញ្ចឹងអន្លង់គេហ្នឹង អន្លង់ធំអ្ហេះ?

អុិនៈ បាទ!

ភាស៊ីៈ អញ្ចឹងក្នុងរោងមួយហ្នឹងគេជីកអន្លង់មួយ?

អុិនៈ បាទ!

ភាស៊ីៈ ហើយអាចដាក់មនុស្សបាន២០នាក់?

អ៊ីនៈ បាទ! ហើយនៅមានកន្លែងមួយទៀត អាហ្នឹងអន្លង់គេជីកតែកន្លះម៉ែត្រទេ ជម្រៅទៅក្រោមពីរម៉ែត្រ ហើយគេជីកទទឹងកន្លះម៉ែត្រ ហើយគេដាក់ក្ដារម៉ាសន្ទឹកនៅហ្នឹង ហើយគេជីកឲ្យដង្ហែរគ្នាទៅ គេចេះរូងដីពីក្រោមអញ្ចឹងទៅ គេដាក់ឫស្សី ហើយយកច្រវ៉ាក់មៅឲ្យរត់តាមហ្នឹងមៅ បានគេដាក់ខ្នោះជាប់ទៅ ហើយឲ្យដេកនៅក្នុងហ្នុងទៅ ។

រ៉ាស៊ីៈ ដេកឈរហ្នឹង?

អ៊ីនៈ បាទ!

យិនៈ ដេកឈរត្រង់អី?

អ៊ីនៈ អត់ដេកឈរទេ គេជីកដូចអារណ្ដៅកប់ខ្មោចអញ្ចឹងហ្នុង ។

រ៉ាស៊ីៈ បានន័យថាជីកកន្លះម៉ែត្រចុះទៅ បណ្ដោយអញ្ចេះពីរម៉ែត្រអ្ហេះ?

អ៊ីនៈ បាទ! ២ម៉ែត្រ ។

រ៉ាស៊ីៈ ហើយចោះរូងដីខាងក្រោមហ្នឹងដាក់ខ្នោះ?

អ៊ីនៈ បាទ! ចោះខាងចុងជើង ។

រ៉ាស៊ីៈ ហើយពេលដែលជាប់នៅក្នុងហ្នុងខ្មែរក្រហមវាមានឲ្យភួយ ឲ្យអីសន្ដប់ទេ?

អ៊ីនៈ មុនដំបូងវាយកទៅ ជួនកាលវាស្រាតចេញអស់ហើយ ។ វាស្រាតដោះអាវទាំងអស់ មើលថាគេថាគេសួរយើងបានម៉ាដងហើយ បានវាយកអាវមកឲ្យពាក់ ។ អញ្ចឹងអាវពាក់មួយៗម្នាក់ ។

រ៉ាស៊ីៈ មានអាវរបស់គេដែរ?

អ៊ីនៈ អាវអាអ្នកទោសដដែលហ្នឹង ។

រ៉ាស៊ីៈ បាទ!

អ៊ីនៈ ហើយមានអារណ្ដៅមួយទៀត អាហ្នឹងរណ្ដៅគេជីកកន្លះម៉ែត្របួនជ្រុង ជម្រៅទៅក្រោមម៉ាម៉ែត្រកន្លះអាហ្នឹងសម្រាប់ដាក់ខ្នោះអន្ទុយ ។ អាហ្នឹងអត់ដំបូលទេ ។

រ៉ាស៊ីៈ ប៉ុន្តែនៅក្នុងបរិវេណហ្នឹងដែរ?

អ៊ីនៈ បរិវេណហ្នឹងដែរ ។

រ៉ាស៊ីៈ ចុះអានៅក្រៅបរិវេណហ្នឹងដែលពូរៀបរាប់ថានៅឆ្លងត្រពាំងហ្នឹងមានមន្ទីររបស់ ឌុច មួយហ្នឹង!

អ៊ីនៈ បាទ! មានមន្ទីររបស់ ឌុច មួយទៀត ។

រ៉ាស៊ីៈ អាហ្នឹងមនុស្សប្រភេទអីដែលបញ្ជូនទៅហ្នឹង?

អ៊ីនៈ អហ្នឹងអត់មានមនុស្សប្រភេទណាទេ ឲ្យតែគាត់ត្រូវការយកសួរគឺ ។

រ៉ាស៊ីៈ យកចេញពីនេះទៅ?

អ៊ុនៈ បាទ! យកចេញពីនេះទៅ យកទៅដល់ដាក់ខ្មោះហ្នឹង។ ពេលគាត់យកទៅសួរ ចន្ទុះយើងអាក្រាក់តាអ៊ុននោះ អាប៉ិនៗណេះហ្នឹងអត់មានរុំទេ គាត់យកដែកគៀបកណ្តាលដុត ហើយសម្រក់ពីកញ្ចឹងកមៅ ហូរដវរ៉ូចាប់ផ្តើមសម្រក់ត្រង់ណេះទៀត។

ភ័ស៊ីៈ គាត់ធ្វើទារុណកម្មខ្លួនគាត់ ឬក៏?

អ៊ុនៈ គាត់ធ្វើផ្ទាល់ខ្លួនគាត់។ កន្លែងសួរចម្លើយមិនមែនសួរតែមាក់កន្លែងទេ ៧ ៨ ៩កន្លែងណោះ។ អាកន្លែងណាដែលតឹង វាឲ្យកូនក្មេងសួរ អាតូចៗហ្នឹង។ វាឲ្យវៃតាមចិត្ត អស់ចិត្តសិនបានឲ្យយកទៅគាត់។

ភ័ស៊ីៈ អាយុប្រហែលប៉ុន្មានដែរ កូនក្មេងដែលជាអ្នកសួរចម្លើយហ្នឹង?

អ៊ុនៈ កូនក្មេងសួរចម្លើយមានអាយុ ៨ឆ្នាំ ៩ឆ្នាំ ១០ឆ្នាំអីហ្នឹង។

ឃិនៈ អញ្ចឹងលោកពូថាមាន ៨កន្លែង ៩កន្លែង?

អ៊ុនៈ បាទ!

ឃិនៈ ពួកអាក្មេងៗសួរហើយ បានយកទៅ ឌុច សួរចុងក្រោយ?

អ៊ុនៈ បាទ!

ភ័ស៊ីៈ ហើយក្មេងៗអស់ហ្នឹងយកពីណាមកវិញពូ?

អ៊ុនៈ ក្មេងៗវាជ្រើសខ្លួនវា។ វាយកក្មេងៗធ្វើកងការពារ ដែលដុះចេញឡើង វាយកក្មេងៗទៅបណ្តុះហ្នឹង។

ភ័ស៊ីៈ ឌុច អ្នករើសខ្លួនឯង ឬក៏មានអ្នកផ្សេងគេទៅ?

អ៊ុនៈ ឌុច ជាអ្នករើសខ្លួនឯង។ ឥឡូវនៅមានកងការពារច្រើនណាស់ដែលនៅរស់ នៅជុំវិញខ្ញុំនេះនៅរស់ដែរ។

ឃិនៈ មានឈ្មោះអីខ្លះ ដែលកងការពារដែលនៅរស់នោះណា?

អ៊ុនៈ កងការពារដែលនៅរស់សល់ ខ្ញុំមានកត់នៅក្នុងនេះដែរ

ឃិនៈ ណិន ហើយនឹង វឿន ហ្នឹងអ្ហេះ?

អ៊ុនៈ ណិន, វឿន, ខន, ហើយហ្នឹង ជន ហើយហ្នឹង វន ហៅ ឌិន។

ភ័ស៊ីៈ សព្វថ្ងៃនៅរស់ទាំងអស់ អ្នកទាំងអស់ហ្នឹងអ្ហេះ?

អ៊ុនៈ បាទ!

ភ័ស៊ីៈ នៅក្នុងភូមិអី ឃុំអីដែរ?

ឃិនៈ វឿន នៅភូមិអី?

អ៊ុនៈ វឿន នៅកុមាររមាស។ ជន នៅថ្នល់បំបែក(ថ្នល់បំបែកអមលាំង)

ឃិនៈ ណិន នៅឯណា?

អ៊ីនៈ ណិន នៅទំនាប (ភូមិទំនាប) ឃុំអមលាំង។ ខន នៅភូមិក្បាលចិន។ ឌិន នៅស្តុកស្អាតនេះ។ ខ្ញុំឃើញ ឈិន ជួបខ្ញុំម៉ាភ្លែត។ ខ្ញុំថា អុញ! គេមានស្គាយកាំភ្លើង គ្នាពីរនាក់ឃើញដើរកាត់ភ្នំទៅអញ្ចឹងទៅ ហើយខ្ញុំបរទេសទៅទៅជួបនឹង........

ភ៉ាស៊ីៈ ឈិន ណា?

អ៊ីនៈ ឈិន មាននៅក្នុង.....

ឃិនៈ ប៊ុនមិនដឹងថាគាត់រស់នៅភូមិណាមិនដឹង? ប៊ុនឃើញគាត់ដែរណោះ ធ្វើអី ឈិន ហ្នឹង?

អ៊ីនៈ ឈិន ហ្នឹងកាលពីដើមគេហៅទៅហ៊ុកហ៊ុនជាកងការពារហ្នឹង។

ភ៉ាស៊ីៈ មន្ទីរសន្តិសុខហ្នឹង ម៉េចបានជាគេហៅថាមន្ទីរសន្តិសុខ ១៣ លោកតូ?

អ៊ីនៈ ហ្នឹង ខ្ញុំមៅដល់គេហៅថា មន្ទីរភូមិភាគពិសេស ម-១៣។ ម-១៣ ហ្នឹងមានសាខាវាទៅខាង ៩៩(មន្ទីរសន្តិសុខ ៩៩) ហ្នឹង ក៏ ម-៩៩។

ភ៉ាស៊ីៈ មានកន្លែងណាទៀតពូដែលជាសាខា?

អ៊ីនៈ ហើយសាខាយើងនៅប្រសិទ្ធិនេះ មានឈ្មោះ មិនដឹងដែរ ភ្លេចហើយ។

ឃិនៈ មិនដឹង ម ប៉ុន្មានទេ ប៉ុន្តែវាជាសាខាអាហ្នឹង?

អ៊ីនៈ បាទ! មានសាខាគាត់មួយទៀតនៅនេះហ្នង នៅភូមិខ្ញុំនេះ នគរបាល ដែលមាន តាស៊ុម គាត់ជាអ្នកកាន់កាប់។

ភ៉ាស៊ីៈ ហ្នឹងគេហៅមន្ទីរអី?

អ៊ីនៈ ហ្នឹងគេហៅមន្ទីរនគរបាលហ្នង។

ឃិនៈ មិនមានកំណត់លេខប៉ុន្មានទេណោះ?

អ៊ីនៈ បាទ!

ភ៉ាស៊ីៈ នគរបាល ហ្នឹងជាឈ្មោះភូមិ ឬក៏ជាកន្លែងអី?

អ៊ីនៈ គេហៅ នគរបាល អញ្ចឹងហ្នង។

ភ៉ាស៊ីៈ ចុះសព្វថ្ងៃនៅហៅ កន្លែងនគរបាល អញ្ចឹងដែរ?

អ៊ីនៈ នៅហៅជាប់រហូត។

ភ៉ាស៊ីៈ ចុះកន្លែងហ្នឹងមានប្រជាជនរស់នៅទេឥឡូវហ្នឹង?

អ៊ីនៈ អត់មានទេ នៅតែស្រះជនាន់វាជីកអីហ្នឹង។

ភ៉ាស៊ីៈ អញ្ចឹងមន្ទីរភូមិភាគពិសេស ម-១៣ ហ្នឹងមានសាខាវាបីកន្លែងហ្នឹងគឺ ម-៩៩, ភ្នំបាសិទ្ធិ និង នគរបាល។

អ៊ីនៈ បាទ!

រ៉ាស៊ីៈ ហើយអ្នកដែលគ្រប់គ្រងតាមមន្ទីរហ្នឹង ដឹងថានៅមន្ទីរភូមិភាគពិសេសហ្នឹងមាន ឌុច ជាអ្នកគ្រប់គ្រង ចុះនៅមន្ទីរ៩៩ នៅបាសិទ្ធិ និងនៅនគរបាលនេះ?

អ៊ុនៈ នៅមន្ទីរ ៩៩ ហ្នឹង ខ្ញុំទៅដល់ហ្នឹងអត់បានជាប់គុកទេ គ្រាន់តែបានលត់ដំទេ ខ្ញុំអាចដឹងពត៌មានច្រើន ។ វាផ្លាស់ប្តូរកម្មាភិបាលច្រើននាក់ណាស់ ។ ខ្ញុំទៅមុនដំបូងមានឈ្មោះ ខាន់ ជាអ្នកគ្រប់គ្រង ។ មុនដំបូងគេបង្ហួស់ ខ្ញុំឮថាមានឈ្មោះ តាម៉ុក អូរ! មិនមែនទេ ឈ្មោះអីទេ.....។

រ៉ាស៊ីៈ អត់អីទេពូ អាហ្នឹងខ្ញុំទៅស្រាវជ្រាវម្តងរួចហើយ ។

អ៊ុនៈ តែគ្រាន់ពេលដែលខ្ញុំ ទៅដល់ខ្ញុំឃើញឈ្មោះ ខាន់ ។ ដល់ហើយពី ខាន់ មៅបានឈ្មោះ ណម ។ ដល់ ណម ហ្នឹង កាលហ្នឹងពួកហ្នឹងផ្តើលបាញ់គ្នា ចលាចលហ្នឹងខ្ញុំក៏អត់បានចាប់អារម្មណ៍ណាណីខ្ញុំអត់ដឹង ។ ខ្ញុំគេឲ្យសែងអ្នករបួសចេញទៅ ត្រឡប់មៅភូមិវិញ គេថាគេមិនឲ្យចូលភូមិហ្នឹងទេ ចូលអត់បានទេ ។

រ៉ាស៊ីៈ ចុះនៅបាសិទ្ធិមានឈ្មោះអីគ្រប់គ្រង?

អ៊ុនៈ ឈ្មោះ វុទ្ធ ។

រ៉ាស៊ីៈ ឯនៅនគរបាលមានឈ្មោះ ស៊ុម?

អ៊ុនៈ បាទ! ឈ្មោះ ស៊ុម ។

រ៉ាស៊ីៈ ហើយពូមានដែលបានសង្កេតឃើញឈ្មោះ ស៊ុម និងវុធ ហើយអ្នកដឹកនាំខាងមន្ទីរ៩៩ មានដែលឃើញថា ឌុច កោះហៅឲ្យមកប្រជុំដាក់ផែនការអីទេ?

អ៊ុនៈ ក្នុងម៉ាអាទិត្យ គេហៅទៅប្រជុំម្តងនៅមន្ទីរតា ឌុច នេះហ្នឹង ។ ម៉ាអាទិត្យគេហៅសាខាមកប្រជុំ ហើយដល់ពេលអញ្ចឹង ពេលមួយនោះ តាស៊ុម គាត់សួរខ្ញុំថា ឌុច ហ្នឹង កាលទឹកសាយលិចមនុស្សងាប់អស់ច្រើន អត់មានរាយការណ៍អីយ៉ាងម៉េចៗ គាត់ឲ្យខ្ញុំជួយយកពត៌មានយកការណ៍អី ខ្ញុំថាខ្ញុំអត់ហ៊ានទេ ដរីដល់គ្នាមិនមែនងាប់ដរីទេ តាអាណិតខ្ញុំទៅ ។ ខ្ញុំលែងហ៊ានប៉ះពាល់ហើយអារឿងអញ្ចឹងៗ ។ តែថាងាប់ៗច្រើនមែន អាទឹកសាយមៅ អារណ្តៅវាលិច ។

រ៉ាស៊ីៈ នៅឆ្នាំណាទៅអាទឹកឡើងលិចហ្នឹង?

អ៊ុនៈ ទឹកឡើងលិចហ្នឹងនៅក្នុងឆ្នាំ ៧៣ ។

រ៉ាស៊ីៈ នៅក្នុងហ្នឹងមានអ្នកទោសខ្ទះថ្មី អ្នកទោសខ្ទះចាស់ដែរអ្ហេះ?

អ៊ុនៈ មាន ។

រ៉ាស៊ីៈ ចុះពូថាម៉ាទិត្យប្រជុំម្តង ចុះក្រោយពីប្រជុំមៅ ពូមានសង្កេតឃើញថាក្នុងមន្ទីរមួយៗហ្នឹងមានបម្រែបម្រួលយ៉ាងម៉េចទៅ ក្រោយពីប្រជុំជាមួយ តាឌុច មៅ?

អ៊ុនៈ ខ្ញុំអត់ដែលបានឮថាគេប្រជុំយ៉ាងម៉េចអីយ៉ាងម៉េចដែរ ឃើញតែគេហៅទៅប្រជុំ ហើយក្រោយមកទៀតឃើញគេហៅសុទ្ធតែខាងហាណូយទាំងអស់ ខ្មែរហាណូយ ។

ភ៉ាស៊ីៈ ម៉េចបានពូដឹងថាខាងខ្មែរហាណូយ?

អ៊ីនៈ ព្រោះពួកគាត់សុទ្ធតែមានប្រពន្ធ កាំភ្លើងខ្លីម៉ាដើម អាការម៉ាដើម អញ្ចឹងយកទៅសួរចម្លើយ ។ សួរចម្លើយយូរៗ ថាឲ្យទៅរៀនសូត្រឯណា ដកកាំភ្លើងអីណាថាឲ្យទៅកាន់មេទ័ពនៅឯណាឯណី ទេ បញ្ជូនយកមកក្រោយស៊ីងណេះចាប់គ្នាវ៉ៃចោលអស់អាលីងហ្នឹង ។

ភ៉ាស៊ីៈ ចាប់ខាងហាណូយយកទៅអ្ហេះ?

អ៊ីនៈ បាទ! ពួកមេ៉ាពីរៀននៅហាណូយ ។

ឃិនៈ ច្រើនទេ?

អ៊ីនៈ ប្រហែលជាង១០នាក់ ។

ឃិនៈ តែមើលទៅសភាពពួកហាណូយហ្នឹង សុទ្ធតែកម្មាភិបាល សុទ្ធតែមានកាំភ្លើងខ្លី?

អ៊ីនៈ បាទ! សុទ្ធតែកម្មាភិបាលធំៗ

ឃិនៈ ហើយមោ៉ដល់ហ្នឹងគេដកកាំភ្លើងខ្លីអស់?

អ៊ីនៈ មោ៉ដល់ហ្នឹងមុនដំបូងគេអត់ដកទេ គេធ្វើនយោបាយឲ្យពួកហ្នឹងទៅសួរចម្លើយអ្នកទោសអីណាណី ដល់សួរចម្លើយអ្នកទោសយូរៗ មើលទៅសភាពការមិនស្រួលញបានគេទៅចាប់ ។ ដកកាំភ្លើង ហើយប្រាប់ថា ឌុច ឲ្យទៅប្រជុំឲ្យគាត់ទៅកាន់ទ័ពនៅផ្នែកណាមួយៗ ។ ស្រាប់តែដល់ទៅខ្ញុំ ឃើញស្បែកជើងរបស់ពួកហាណូយនៅកងការពារពាក់ ។

ភ៉ាស៊ីៈ ហ្នឹងនៅឆ្នាំណាដែរ?

អ៊ីនៈ នៅចុង៧៤ ។

ភ៉ាស៊ីៈ អញ្ចឹងពេលដែលពូទៅដល់ហ្នឹងដំបូង ពូទៅឃើញអ្នកទោសជាប់នៅហ្នឹងស្រាប់ ឬក៏អត់ទាន់ឃើញ ទេ?

អ៊ីនៈ អូរអ្នកទោសនៅច្រើនណាស់ គេចងព្យួរ ។ ទៅដល់ក្លាមហ្នឹងគេដោះអាវដោះអីនៅតែខោខ្លី ហើយគេចងដៃទៅក្រោយអញ្ចឹងហើយ គេមានអាបង្គោលគេខ្ពង់ ប្រហែលជា៤ម៉ែត្រទៅលើ អញ្ចឹងទៅ បានគេយកអាកន្ទុយខ្សែហ្នឹងទៅពាក់លើចុងបង្គោលមោ៉ រ៉កឲ្យដៃស្ទូចទៅអញ្ចឹងល្មម តែជើងផុតដីហ្នឹង ។ គេព្យួរហ្នឹងល្មមតែម៉ាមោ៉ងពីរមោ៉ងអីបានគេស្រាយហើយគេដាក់ខ្នោះជើង បណ្តោយ ។

ឃិនៈ មុនដំបូងចងសិន?

អ៊ីនៈ បាទ! ខ្ញុំទៅដល់ដំបូងគេព្យួរអញ្ចឹងជាមួយបងខ្ញុំ ។ ខ្ញុំ......................គាត់ដើរមកចាប់ ។

ឃិនៈ បងជាប់ដែរអញ្ចឹងពីរនាក់?

ភ៉ាស៊ីៈ មូលហេតុអីបានជាមន្ទីរហ្នឹងត្រូវបំបែកនៅឆ្នាំ៧៥ លោកពូ?

អ៊ីនៈ ខ្ញុំពួកកងការពារជដែកគ្នាសប្បាយអឺងកងលាន់ ថាគេខ្វះទៅនៅភ្នំពេញ ។ ឯខ្ញុំណោះគេបញ្ជូនទៅខាង ៩៩ហ្នឹង មានគ្នាបីនាក់ ។ កងការពារនោះបីនាក់ដែរទៅដល់ ៩៩ ។ ខ្ញុំស្មានថាគេសម្លាប់ចោលតាមផ្លូវហើយ ។

ភ៉ាស៊ីៈ ចុះអ្នកទៅជាមួយពូពីរនាក់ទៀតមានឈ្មោះអីដែរ?

អ៊ីនៈ មួយឈ្មោះ តាសុខ ។

ភ៉ាស៊ីៈ ឈ្មោះអីទៀត?

អ៊ីនៈ ភ្លេចឈ្មោះហើយ ។

ភ៉ាស៊ីៈ ហើយចុះអ្នកដែលនៅរស់ផ្សេងៗទៀត?

អ៊ីនៈ អ្នកដែលនៅរស់ផ្សេងៗទៀត គេឲ្យទៅកាប់រណ្តៅនៅឯជិតកន្លែង ឌុច នៅខាងជើង វាដាក់ខ្សែឲ្យកងការពារនេះ ឲ្យកាប់រណ្តៅខ្លួនឯង ហើយក៏ខ្ញុំគេបញ្ជូនខ្ញុំទៅ ដល់ក្រោយមោ៉មិនដឹងយ៉ាងម៉េច ខ្ញុំអត់ដឹង ។

ភ៉ាស៊ីៈ ហើយចុះអ្នកដែលទៅកាប់រណ្តៅហ្នឹងអត់ដឹងថាស្លាប់ឬរស់ទេ?

អ៊ីនៈ បើតាមខ្ញុំយល់ហ្នឹង អ្នកដែលកាប់រណ្តៅហ្នឹងគឺអត់មានរស់មួយទេ ។ គាត់បានប្រាប់ខ្ញុំផ្ទាល់ថា ឌុច គាត់ថា “មោ៉ដល់កន្លែងនេះ តែវ៉ៃឲ្យមានស្លាកស្នាមបន្តិចហើយ អត់ទុកទេ” ។ បើគាត់បម្រុងទុក ដូចខ្ញុំអីខ្ញុំចេះតែអង្វរលន់តួគាត់ ។ គេចងព្យួរខ្ញុំថា ទម្លាក់ខ្ញុំសិនទៅ ចាំរករឿងហេតុស្រួលបួលសិន ។ ដល់អញ្ចឹងគាត់ឲ្យកងការពារ ធូរដែរ ។

ភ៉ាស៊ីៈ បាទ! ចុះគាត់មើលទៅជាមួយពូមើលទៅមិនសូវកាចសាហាវប៉ុន្មានទេ?

អ៊ីនៈ អត់សូវកាចសាហាវដែរ ។ ដល់ហើយហ្នឹងមោ៉គាត់លែងខ្ញុំមោ៉ ឲ្យខ្ញុំទៅនៅស្រែ ខ្ញុំនៅតែក្បាល នៅតែស្គម នៅតែឆ្អឹងហើយនឹងស្បែក ។ ពុំមានសាច់ហូប ខ្ញុំចេះតែដើរចាប់ត្រីចាប់អីទៅ ខ្ញុំចេះតែបម្រើទៅឲ្យគាត់យល់ចិត្ត ។ គាត់ចេះតែស្រឡាញ់ខ្ញុំ ។

ភ៉ាស៊ីៈ ពូមានធ្វើអីខុសទេ បានជាគេបញ្ជូនពូទៅ ៩៩ និងអ្នកផ្សេងឲ្យទៅជាប់ហ្នឹង?

អ៊ីនៈ មុនដំបូងគាត់បម្រុងបញ្ជូនខ្ញុំទៅពោធិ៍សាត់ គាត់ហៅខ្ញុំទៅសួរផ្ទាល់ គាត់ថាឥឡូវមនុស្សដែលគាត់បម្រុងហៅទៅនៅភ្នំពេញនោះម៉ាចំនួនបញ្ជូនទៅខាងពោធិ៍សាត់ ។ ម៉ាចំនួនបញ្ជូនទៅ ៩៩ គាត់សួរថា តើខ្ញុំស្ម័គ្រចិត្តទៅខាងណា ។ ខ្ញុំថា តាអ៊ើយ! បើខ្ញុំស្លាប់សុំស្លាប់នៅក្នុងស្រុកខ្លួនឯងចុះ ។ ដល់អញ្ចឹងគាត់ឲ្យខ្ញុំទៅ ៩៩ ។

ភ៉ាស៊ីៈ ហើយពូដឹងថាមានបញ្ហាអីមោ៉ពីណាទេ ដែលនាំឲ្យផ្លាស់ប្តូរពីមន្ទីរ ១៣ ហ្នឹងទៅភ្នំពេញវិញ?

អ៊ីនៈ ខ្ញុំអត់ដឹងថាមានបញ្ហាពីណាមោ៉ទេ តែគ្រាន់តែ កាលពីខ្ញុំនៅជាប់គុក ខ្ញុំឃើញយកប្រពន្ធគាត់ទៅនៅក្នុងចុងឆ្នាំ១៩៧៣ហ្នឹង ឃើញយកប្រពន្ធគាត់ទៅ ហើយកូនគាត់ឈ្មោះ អាទីន នោះមួយ ហើយឈ្មោះអីណា កូនពីរនាក់ ។

រ៉ាស៊ីៈ ចុះមួយទៀត ឈ្មោះ ទីន មួយ ឈ្មោះអីទៀត?

អ៊ីនៈ មិនដឹងឈ្មោះអីទៀតទេ ។

រ៉ាស៊ីៈ ស្រី១ ប្រុស១ អេ្ហះ?

អ៊ីនៈ បាទ! ស្រី១ ប្រុស១ ។ ដល់ក្រោយម៉ោកូនគាត់ស្រី ត្រូវស្លាប់ ។

រ៉ាស៊ីៈ នៅឆ្នាំណាដែរពូ?

អ៊ីនៈ នៅឆ្នាំខ្ទង់ ៧៨ ។

រ៉ាស៊ីៈ មូលហេតុអីបានស្លាប់?

អ៊ីនៈ អត់ដឹងមូលហេតុអីដែង ។

ឃិនៈ ស្លាប់នៅហ្នឹង?

អ៊ីនៈ អត់ទេ! ស្លាប់នៅ គាត់ឲ្យកូនគាត់ទៅធ្វើនៅមណ្ឌល ។

រ៉ាស៊ីៈ មណ្ឌលអីគេ?

អ៊ីនៈ មណ្ឌលសហករណ៍គេនៅវត្តត្រពាំងញ្ញោ ។

រ៉ាស៊ីៈ អញ្ជឹងនៅមណ្ឌលត្រពាំងញ្ញោ?

អ៊ីនៈ បាទ! មណ្ឌលត្រពាំងញ្ញោ សហករណ៍គេ ។

រ៉ាស៊ីៈ ត្រពាំងញ្ញោហ្នឹងជាសហករណ៍គេ?

អ៊ីនៈ បាទ! គេមានមណ្ឌលកុមារ ។

ឃិនៈ ត្រង់ហ្នឹងមានវត្តមួយអេ្ហះ?

អ៊ីនៈ បាទ!

រ៉ាស៊ីៈ កន្លែងហ្នឹងត្រូវ ឌុច ប្រើប្រាស់ធ្វើអីដែរពូ?

អ៊ីនៈ អត់មានប្រើប្រាស់អីទេ ការងារគាត់នៅតែមន្ទីរហ្នឹងហ្នង ។ គាត់ចេញក្រៅហើយគាត់និយាយដូចថាចាប់ប្តីគេម៉ោអញ្ជឹង ហើយគាត់និយាយបញ្ឆោក់ទៀត អត់ទេនិយាយពាក្យអីស្លូតណាស់ ។ ដល់កន្លែងគុកសួរជាមួយអ្នកទោស គាត់និយាយដូចគេលេងក្នុងរឿងអញ្ជឹង ។ និយាយសើចពុប៊ិនវ៉ៃអត់អាណិត ។

រ៉ាស៊ីៈ ពូមានចាំសម្តីគាត់ទេ? លើកឧទាហរណ៍មួយមើល!

អ៊ីនៈ និយាយលេងសើចជាមួយខ្ញុំ កាលហ្នឹងគាត់ថា អញអ្ហា៎! កាលពីឆ្នាំប៉ុន្មានទេ អញជាប់គុកម្តងដែរ ។ និយាយអញ្ជឹងទៅ សើចហាស៎ៗៗជាមួយអ្នកទោសទៅ ។ ពេលធ្វើការគាត់ទៅអង្គុយមើលអីអត់ប្រកាន់ទេ ។ ពេលធ្វើការអ្នកទោសអត់ខ្លាចគាត់ទេ តែបើគាត់មានការចាំបាច់ គាត់បញ្ជាថា នែ៎!យកអានេះមួយទៅវ៉ៃចោល ហើយយកអានោះមួយទៅវ៉ៃចោលទៅ ហើយក្មេងតូចៗជាអ្នកយកទៅវ៉ៃចោល ។

ភ៉ីស៊ីៈ ពូធ្លាប់ពួសួរគាត់និយាយអញ្ចឹងដែរ?

អ៊ីនៈ បាទ! អាក្មេងតូចៗ អាខ្លះកំពុងតែជាន់អន្ទាក់ហ្នឹង ដោះបេះប្រវ៉ាក់ យកសោមកចងវិញ។

ឃិនៈ អូរអាពេលជាន់អន្ទាក់ហ្នឹង ប្រវ៉ាក់នៅតែជាប់ក?

អ៊ីនៈ បាទ! ធ្វើការងាររអីក៏គេដាក់ប្រវ៉ាក់ទាំងអស់ៗ ដាក់បួននាក់ៗ ។ ប្រវ៉ាក់ដូចប្រវ៉ាក់ដរីអញ្ចឹង។

ភ៉ីស៊ីៈ ដល់ដោះអាណាមួយយកទៅវិញដោះប្រវ៉ាក់យកទៅវិញ?

អ៊ីនៈ បាទ! គេត្បៀបអញ្ចឹងមោ៉ គេដាក់ម្នាក់ អាណាចុងគេគ្រាន់បានស្រួល អាណាកណ្តាលគេរាង ធ្ងន់ជាងគេ។ តែដល់នេះទៅអត់បានយូរដូចគ្នាហ្នឹង បើអត់ដែលបានបាយស៊ីហ្នឹង បបរហ្នឹងមាន តែអង្ករ ម៉ាខ្លះហ្នឹងមានអង្ករតែប្រហែលជាពីរកំប៉ុងទេ គេដាក់អាពោតក្រហមហ្នឹង ពោតកិន ហ្នឹងលាយជាមួយអាស្លឹកដំឡូងមី ស្លឹកដំឡូងឈ្វាអីដូចបបរបាយជ្រូកអញ្ចឹង។

ភ៉ីស៊ីៈ ពូថា ឌុច បានបញ្ជាឲ្យយកអ្នកនេះអ្នកនោះទៅវៃចោល អញ្ចឹងពូដឹងថាអ្នកដែលត្រូវ ឌុច យក ទៅវៃចោលហ្នឹង មានកំហុសអីដែរពូ?

អ៊ីនៈ បើតាមខ្ញុំយល់ទៅ មនុស្សសុទ្ធតែអត់មានកំហុសអីទេ ខ្ញុំនៅក្នុងគុកជដែកគ្នាលេង បើសិនជា យើងឆ្លើយថាអត់ គេយកទៅវៃចោលហើយ ទាល់ឆ្លើយថាខ្មាំងៗ ខ្ញុំទៅដល់ ខ្ញុំថាខ្មាំងអាម៉េច អីអាម៉េចទេៗ ខ្ញុំថាខ្ញុំពីដើមឡើយខ្ញុំគេឲ្យធ្វើជាប៉ូលីសពាក់លឿងបីជាន់ ខ្ញុំចេះតែថាទៅ បើ យើងនឹកឃើញថាវៃឲ្យងាប់ចោលអស់ហ្នឹងទៅខ្ជិលៗ តែខ្ញុំចេះនិយាយស្លូតៗជាមួយគាត់ ចេះ យកចិត្តណាស់ៗ ម្យ៉ាងទៀត ឪពុកខ្ញុំនោះគាត់អ្នកកាន់កាប់នៅក្នុងសហករណ៍ឃុំ គាត់ជាអ្នក កុម្មុយនិស្តមួយ គាត់ចេះភាសាវៀតណាមអាលាយតែហ្នឹងៗ រៀនបានទៅដូចណា ជួយធ្វើ ត្រង់សេ ខ្ញុំតាំងពីឆ្នាំ ៧០-៧១ៗ ទៅជួយធ្វើត្រង់សេ ឪពុកខ្ញុំទៅប្រាជ្ញាណែនៗផ្ទះ ខ្ញុំអត់ ដែលទេ មោ៉យើង៧៩ទៀត កាលដែលខ្ញុំជាប់គុក ខ្ញុំព្រួយបារម្ភខ្លាចតែចាប់ឪពុកខ្ញុំទៅទៀតទេ

**ផ្នែក «១»**

អ៊ីនៈ ........ច្រើនណាស់រឿងសម្ពាប់ហ្នឹងៗ

ភ៉ីស៊ីៈ ពូរៀបរាប់ខ្លះមើល៍?

អ៊ីនៈ សម្លាប់មួយ គេយកអាសម្លាប់ប្រភេទច្រើនរាប់រយហ្នឹង ដែលយកទៅរាប់រយហ្នឹង ជួនកាល ពីររយ ច្រើនណែនផ្ទះអញ្ចឹងមោ៉ គេយកទៅដល់ គេយកក្រមា៉រុំករពីរជុំអញ្ចេះ ម្នាក់ទាញចុង ជាយម្ខាងៗ អាកាំបិតយើងអ៊ែរកែងមុខពីរសំលៀងឲ្យស្តើងដូចស្លាបមាន់អញ្ចឹង គេចាក់ពីក្នុង មោ៉គាស់ភុតៗ គេចងមុខ គេឲ្យអាម្នាក់ចងដៃឲ្យតឹងទៅក្រោយហើយ គេមានអារណ្តៅដាក់ ឈាមកន្ទះម៉ែត្របួនជ្រុងអញ្ចឹងមោ៉ៗ ទៅដល់ហ្នឹងមានអាជើងអស់ទាស់គេ គេយកអាកាំបិត

ហ្នឹងសឹក (ចាក់បំពង់ក) ត្រង់ហ្នឹងដាច់គាស់កុត ។ ចំណែកអាពីរនាក់ហ្នឹង យួរទៅរៀបនៅក្នុងអារណ្ដៅដែលខ្ញុំបង្ហាញ អារណ្ដៅធំៗដែលមានជម្រៅទៅក្រោមប្រហែលខ្ពង់៤-៥ម៉ែត្រ បីមុំចង្រ្កានជិតគ្នាអញ្ចឹងទៅ យកទៅរៀបអញ្ចឹង ។

ឃិនៈ រៀបដូចជាអូសម៉ែត្រអញ្ចឹង?

អ៊ីនៈ បាទ! រៀបទាល់តែពេញបានគេលប់ ។ រួចនៅអាក្រោយនោះស្អុយពេញ លលាដ៏ក្បាលនិយាយពីនៅជុំទិសទាំងអស់ ។ អ្នកស្រែលែងខ្លាចលែងអីអស់ហើយខ្មោច ។

ភ៉ាស៊ីៈ ហើយចុះវិធីខ្លះទៀតលោកពូ?

អ៊ីនៈ វិធីខ្លះទៀតប្រើក្មេងៗឲ្យវៃហ្នឹង ហើយអាវិធីសម្លាប់ដូចបងខ្ញុំគឺ គេចងដៃព្យួរទៅលើ សម្រាតខោអស់គេកាន់ចុងកាំបិតឲ្យចេញចុងបិណ្ឌីងមោ៉ង គាត់ចាក់ហ្នឹង ឌុច ហ្នឹង ។

ឃិនៈ ឌុច អ្នកចាក់?

អ៊ីនៈ បាទ! ប៉ឹបៗៗៗ តាំងពីចន្លកហ្នឹង បុកចាក់យកហ្នឹង ។ គេចាក់ឲ្យហូរទៅក្រោម គេយកចានដែកត្រងឈាម ។ ហ្នឹងសុទ្ធតែអ្នកដែលមានសាច់ធំៗ ។

ឃិនៈ ហ្នឹងអ្នកដែលធាត់?

អ៊ីនៈ បាទ! ទាល់តែសន្ទប់បាត់មាត់ហ្នឹងបានគេយកទៅដាក់ហាលសន្សើម ។ មើលតែដឹងខ្លួន រស់ភ្លឹះៗហើយ កាលហ្នឹងមានពេទ្យមួយមើលព្យាបាល ។ ពេទ្យហ្នឹងក៏ជាអ្នកទោសដែរ ហើយថ្នាំនោះមិនដឹងជាស្អីៗដែរ ខ្ញុំរកមើលអត់យល់ដែរ ។ ព្យាបាលអីមើលទៅនៅតែភ្លឹះៗ បានគេយកសួរ ។ សួរបើថាឆ្លើយថា «ទេ» គេវៃ គេយកអាញួរ(ញញួរ) ឈើវៃដើមទ្រូងវៃពីខ្នង វៃពីមុខពីក្រោយៗ ដៃទាំងពីរហ្នឹងសាប់យកហ្នឹង ។

ភ៉ាស៊ីៈ ឌុច ជាអ្នកសួរអ្ហេះ?

អ៊ីនៈ ឌុច ហើយខុសពីកន្លែង ឌុច ហ្នឹងក៏មានដែរ ។ ឌុច ក៏សួរផ្ទាល់ដែរ ។

ភ៉ាស៊ីៈ សួរនៅក្នុងមន្ទីររបស់ ឌុច ហ្នឹងហ្នឹង?

អ៊ីនៈ បាទ! នៅក្នុងមន្ទីររបស់ ឌុច ព្រោះអីនៅក្នុងនោះមានច្រើនណាស់ ខ្ញុំឃើញមានឈ្មោះ ប៉ុន ឈ្មោះ ចាន់ ហើយឈ្មោះ ផល ។ ផល ហ្នឹងក៏មានវិវាទគ្នានៅជិតចុងឆ្នាំ១៩៧៥ហ្នឹង ឌុច ហ្នឹងបានមកសួរខ្ញុំហ្នឹង ខ្ញុំរួចហ្នឹងមោ៉ពីធ្វើការគេឲ្យមោ៉នៅក្នុងគុកដដែលគ្រាន់ធ្វើ ចិញ្ចឹមមាន់ទាហ្នឹង ដល់អញ្ចឹងគាត់ថា ល្ងាចនេះចាប់មនុស្សម្នាក់ហើយ ។

ភ៉ាស៊ីៈ ឌុច និយាយអញ្ចឹងអ្ហេះ?

អ៊ីនៈ បាទ! ប្រកាសចាប់មនុស្សម្នាក់ មាននរណាទាយត្រូវអត់ បើទាយត្រូវឲ្យទទួលកង់ពីវា ។ ដល់អញ្ចឹងអត់មានពីណាទាយត្រូវ ដល់អញ្ចឹងយកដាក់កន្លែងគាត់ ចង់ដាក់កន្លែងគាត់ ។ ដល់អញ្ចឹងឲ្យខ្ញុំទៅមើល ។ អ៊ីន ឯងធ្វើដើរទៅកន្លែងអញសួរចម្លើយនោះមើល អានោះវាស្គាល់អីយ៉ាង

ម៉េច តែកំបាច់សួរវាអីគ្រាន់តែដើរទៅមើលបានហើយ ។ អានោះក៏អ្នកអស់ទាស់ដែរណាស់ ។ ដល់ពេលខ្ញុំទៅដល់ខ្ញុំឃើញ ផល ។ ចាប់គ្នាវាមៅ ។

យិនៈ ផល ដែលធ្លាប់សួរចម្លើយគេហ្នឹង?

អ៊ុនៈ បាទ!

ភ៉ាស៊ីៈ ហេតុអីបានចាប់មៅ?

អ៊ុនៈ ខ្ញុំអត់ដឹងរឿងហេតុដែរ ។

ភ៉ាស៊ីៈ ហ្នឹងមុននឹងដូរទៅភ្នំពេញអ្ហេះ?

អ៊ុនៈ បាទ!

ភ៉ាស៊ីៈ ពូមានចាំទេ ដូរទៅភ្នំពេញនៅឆ្នាំ ៧៥ ហ្នឹងនៅក្នុងខែណាដែរ?

អ៊ុនៈ អត់មានចាំទេ ។

ភ៉ាស៊ីៈ បែក ១៧ មេសាហើយ ឬអត់ទាន់ដល់ហ្នុងទេ?

អ៊ុនៈ ១៧ មេសាហើយៗ ក្នុងឆ្នាំ១៩៧៥ហ្នឹង ។

ភ៉ាស៊ីៈ ចុះបើគិតពីខែខ្មែរវិញ ដល់ខែភ្លៀងនៅកាលហ្នុង?

អ៊ុនៈ កាលហ្នុងអត់ទាន់ដល់ខែភ្លៀងទេ ខែប្រាំងហ្នឹង ព្រោះគេបញ្ជូនខ្ញុំទៅ៩៩ ហ្នឹង ។

ភ៉ាស៊ីៈ អូរ! គ្រាន់តែ១៧ មេសា ហើយភ្លាមហ្នឹងគេដូរទៅ!

អ៊ុនៈ បាទ! ពូគេថាជ័យជំនះភ្នំពេញ ។

ភ៉ាស៊ីៈ ពូមានដែលស្តាប់ពូ ឌុច ហ្នឹងដាក់បញ្ហាដល់កងសន្តិសុខហ្នឹងថាម៉េចៗទេ?

អ៊ុនៈ ខ្ញុំអត់បានស្តាប់ពូទេ ប៉ុនគ្រាន់តែបានដឹងថាក្រុមគាត់ហ្នឹងគេប្រជុំគ្នាថា គេនៅសហករណ៍ គេដាំដំឡូងមីក្នុងមាំថ្ងៃ១០០គុម្ព ឯងសម្លាប់ខ្មាំងក្នុងមាំថ្ងៃដែលគេចាប់បាន ចាត់ឲ្យសម្លាប់ពីរនាក់សម្លាប់អត់ឆាប់ ។

ភ៉ាស៊ីៈ អូរ! ឌុច និយាយអញ្ចឹងហ្នូងអ្ហេះ?

អ៊ុនៈ បាទ! គេថាឲ្យកូនក្មេងតូចៗដែលវាយកទៅបង្រៀន ។

ភ៉ាស៊ីៈ ហើយចុះមានដឹងថាម៉ែឪពួកក្មេងៗហ្នឹង ពេលដែលគេហៅកូនទៅមានថាម៉េចទេ?

អ៊ុនៈ អត់មានថាម៉េចទេ នៅផ្ទះទាំងអស់ ហើយសុទ្ធតែនៅភូមិនៅអីទាំងអស់ ។

ភ៉ាស៊ីៈ ម៉ែឪអត់មានជំទាស់ដែរ?

អ៊ុនៈ អត់មានជំទាស់ដែរ ។

ភ៉ាស៊ីៈ នៅម្តុំនេះគេស្គាល់ ឌុច ច្រើនគ្នាដែរទេ?

អ៊ុនៈ ស្គាល់សឹងទាំងអស់ ។

ភាស៊ីៈ ហើយតាមពុសផ្ដេតមើល អ្នកដែលស្គាល់ ឌុច ទាំងអស់ហ្នឹងយល់ថា ឌុច ជាមនុស្សយ៉ាងម៉េចដែរ?

អ៊ុនៈ បើគេនៅខាងក្រៅ គេអត់ដឹងថាយ៉ាងម៉េចទេ គេលាក់ការណ៍ណាស់ ។ នៅកន្លែងនោះកាលណាមានអ្នកចូលទៅដល់គេត្រូវចាប់ហើយថែមហើយ ។

ភាស៊ីៈ ចុះមានដឹងថាអ្នកណាជាអ្នកបញ្ជា ឌុច ឲ្យមកកាន់នៅមន្ទីរ ១៣ ហ្នឹងទេ?

អ៊ុនៈ ខ្ញុំអត់ដឹងដែរ ឃើញតែប្រហែលជាពីរអាទិត្យ ឬបីអាទិត្យឃើញ ឌុច ហ្នឹងពាក់ខោអាវឡើងទៅប្រជុំម្ដង ។

ភាស៊ីៈ ប្រជុំនៅឯណាទៅ?

អ៊ុនៈ មិនដឹងនៅឯណា ឃើញតែម៉ូមីឡែតមួយ គាត់ដាក់នៅខាងកើតស្ទឹង ។

ភាស៊ីៈ ហើយពីប្រជុំមកវិញ តើគាត់មានផែនការអីផ្លាស់ប្ដូរទេ?

អ៊ុនៈ មៅពីប្រជុំវិញ ជួនកាលគាត់ប្រើក្មេងឲ្យមៅដោះថាឥឡូវនៃវើយ ពួកអ្នែងទៅយកអានោះមួយ អានោះមួយៗៗយកទៅវៃចោលទៅ ។ យកមៅវៃហ្នឹង អាណាសួរចម្លើយ.........អីហ្នឹងវៃសាប់នៅកន្លែងហ្នឹងអត់មានថាអ្នកយកគល់ឈើ អាគល់ទឹកដោះប៉ិនណាណីដាក់ហ្មង ។ ខ្លះគេថាសុំបត់ជើងបត់ដៃអី វាថាយី!បត់ជើងបត់ដៃអីអ្នែងសាប់ឥឡូវហើយហ្នឹង វៃទាល់ណាណី ។ ពួកក្មេងៗវៃម៉េចសាប់ ទាល់តែពួកកងការពារធំៗមៅទាត់ម៉ាដៃម៉ាជើងម្នាក់ទៅ ។

ភាស៊ីៈ ប៊ុន ចាន់ ផល អីហ្នឹងអ្ហេះ?

អ៊ុនៈ បាទ!

ភាស៊ីៈ កន្លែងសម្លាប់ស្ថិតនៅកន្លែងណា?

អ៊ុនៈ ប៊ុន ចាន់ ផល មាស ។ មាស ហ្នឹងក៏កំពូលដែរ ជំនិតរបស់ ឌុច ដែរ ។

ភាស៊ីៈ ចុះរាល់ថ្ងៃនេះនៅរស់ទេ?

អ៊ុនៈ មាស គាត់ស្លាប់ហើយ ។

ភាស៊ីៈ ចុះ ប៊ុន?

អ៊ុនៈ ប៊ុន ខ្ញុំអត់ដឹងដែរ ។

ភាស៊ីៈ ចាន់?

អ៊ុនៈ ចាន់ ខ្ញុំអត់ដឹងដែរ ។

ភាស៊ីៈ ពូមានដឹងថាត្រកូលរបស់ ប៊ុន មានឈ្មោះអីដែរ ហើយត្រកូលរបស់ ចាន់ ឈ្មោះអី?

អ៊ុនៈ អត់បានដឹងឈ្មោះអីទាំងអស់ ។

ឃិនៈ ចុះ ទុំ អីអត់ដឹងដែរណោះ?

អ៊ុនៈ អត់ដែរ ។

រ៉ាស៊ីៈ ប៉ុន ចាន់ ហើយនឹង ប៉ុន ហ្នឹងក្រោយមៅទៅភ្នំពេញជាមួយគ្នា ឬក៏គាត់ទៅកាន់កន្លែងផ្សេង?

អ៊ីនៈ បើតាមខ្ញុំស្មានទៅ ទៅជាប់ជាមួយ ឌុច ហ្នឹងតែ ចាន់ ហើយនឹង ឌុច ។

រ៉ាស៊ីៈ ហ្នឹងពូដឹងច្បាស់ថានៅជាប់គ្នាហ្នន ទោះមៅនៅភ្នំពេញក៏ដោយ?

អ៊ីនៈ បាទ! ព្រោះពីរនាក់ហ្នឹងគេធ្វើការជាមួយគ្នា ជួនកាលគេនិយាយភាសាបារាំងអីអញ្ចឹងទៅ ព្រឹសព្រុះៗស្តាប់មិនបាន ។ កាលនោះគេកំពុងប្រជុំម្តង ខ្ញុំដើរកាត់ ខ្ញុំអត់ដឹងគេកំពុងប្រជុំ គាត់ហៅខ្ញុំត្រឡប់មៅវិញហ្នន អ្ហែងម៉េច អ្ហែងចង់យកការណ៍អ្ហេះបើអ្ហែងខ្លាំង ដាក់ប្រជុំមៅ ខ្ញុំនេះភ័យបណ្តោយ ។ កាលហ្នឹងខ្ញុំរួចហើយណាស់ ហើយបើអ្ហែងខ្លាំង អ្ហែងម៉េចមិនព្រមយកក្បាលមាន់មកដាក់ពីលើដំបូងហើយចុចចោលហ្នឹងទៅ ។ រកអាហ្នឹងដាក់ទៅ បើចង់ស្តាប់គេប្រជុំ ។ គេថាខ្ញុំក្រវិចក្រវិលចង់ស្តាប់គេប្រជុំ ។ ខ្ញុំអត់ដឹង ។

រ៉ាស៊ីៈ ប្រជុំនៅក្នុងមន្ទីរ ១៣ ហ្នឹង?

អ៊ីនៈ ប្រជុំនៅកន្លែងរោងបាយគេផ្សេង រោងបាយហ្នឹងប្រពន្ធ ចាន់ ហ្នឹងគេអ្នកធ្វើជីវភាព ។

រ៉ាស៊ីៈ ប៉ុននៅក្នុងបរិវេណមន្ទីរ ១៣ ហ្នឹងដែរ?

អ៊ីនៈ បាទ! នៅក្នុងបរិវេណហ្នឹងដែរ ។

ឃិនៈ ហើយលោកពូឯងដើរទៅធ្វើអីកន្លែងហ្នឹង?

អ៊ីនៈ ប្រពន្ធ ចាន់ ហ្នឹងហើយនឹងខ្ញុំត្រូវគ្នា ហើយខ្ញុំខស្សាហរណ៍ដើររកចាប់ត្រីតាមស្ទឹងហ្នឹង ត្រីខ្ញុំប៉ុនចាប់ត្រីណាស់ ចាប់នឹងដៃនោះ ។ ខ្ញុំចាប់មៅបានយកទៅឲ្យ ឌុច សរសើរអ៊ើយសរសើរ ថាអើ ឌុច ឯងលែងមានទោសហើយណា កងការពារលែងឲ្យប្រមាថគាត់លែងឲ្យអីទៅ ។ យូរៗទៅចង់ឲ្យកាំភ្លើងខ្ញុំយកទៅបាញ់ត្រីរស់អីទៀតណោះ ។ ខ្ញុំថាអត់ហ៊ានកាន់ទេតា ខ្ញុំខ្លាចកាំភ្លើងណាស់ ។

រ៉ាស៊ីៈ ពូស្មានមើលតាំងពីពូជាប់នៅឆ្នាំ១៩៧៣ មៅដល់មន្ទីរ១៣ ហ្នឹងត្រូវផ្លាស់ប្តូរទៅភ្នំពេញ តើពូគិតថាអ្នកទោសដែលជាប់ហ្នឹងស្លាប់អស់ប៉ុន្មាននាក់?

អ៊ីនៈ ហ៊ឺ! តាមខ្ញុំស្មានទៅបែបស្លាប់អស់ច្រើនណាស់ បែបខ្ទង់៣ម៉ឺននាក់ ព្រោះជួនកាលមៅដៃមានពីររយនាក់ក៏មាន ។

ឃិនៈ អាហ្នឹងឆ្នាំណាដែលថាមានច្រើនហ្នឹង?

អ៊ីនៈ វាមានអារណ្តៅគេធំមួយទៀត វាយកទៅដាក់ទៅណែនហ្នឹងហ្នន ដល់អា........បាត់អស់ បានគេបញ្ចេញយកទៅវៃហ្នន គេចងតែមុខទេ ដូចខ្ញុំថាអញ្ចឹង ។ ដើរតំរៀបនៅក្នុងរណ្តៅធំៗ ។

ឃិនៈ មិនមែនបាញ់រះអីទេអញ្ចឹង?

អ៊ីនៈ អត់បាញ់ទេ ។

រ៉ាស៊ីៈ អាករអើបើមនុស្សពីរបីរយនាក់ វាចេះចាក់ករហ្នឹងវាស្មានណាបានអស់ទៅ?

អ៊ុនៈ អាមួយម៉ៅដល់កន្លែងគេហ្នឹងទៅ គេរុំក្រមាពីរជុំអញ្ចឹងទៅ ម្នាក់ទាញចុងជាយម្ខាងៗ កាំបិតគេសិកនៅប្រឡោះករហ្នឹងហើយកាស់ខ្ចិច ។ កាស់ខ្ចិចហើយបានអាពីរនាក់សែនដៃ និងជើងទៅរៀបក្នុងណេ្ដ បានអាពីរនាក់នោះទៅយកទៀតបាត់ហើយ ។ យកទៀតម៉ៅអានេះដាក់ខ្ចិចទៅអាណេះទៅយកទៅទៀត អានោះទៅយកមកទៀតបាត់ហើយ ។

រ៉ាស៊ីៈ ហ្នឹងក្នុងអ្នកសម្លាប់ហ្នឹងមានឈ្មោះទាំងអស់ហ្នឹងទេ មាស ប៉ុន ចាន់....?

អ៊ុនៈ មានតែ មាស ទេអ្នកសម្លាប់ ។

រ៉ាស៊ីៈ ហើយបើតាមពូដឹងម៉ៅ តើ ឌុច ម្នាក់ឯងហ្នឹងបានសម្លាប់មនុស្សអស់ប៉ុន្មានហើយ?

អ៊ុនៈ ហ៊ឺ! អស់ច្រើនណាស់ ឌុច ហ្នឹង ។

រ៉ាស៊ីៈ ពូមានឃើញផ្ទាល់ភ្នែកទេ?

អ៊ុនៈ ខ្ញុំមិនបានឃើញវៃឲ្យស្លាប់នៅកន្លែងផ្ទាល់ភ្នែកភ្លាមៗទេ ប៉ុន្តែវៃធ្វើបាបហើយនឹងយកចន្ទុះហ្នឹងបុកគីប បុកគ្រប់កន្លែងឡើងស្អុយ ។ កន្លែងគាត់ចូលទៅស្អុយហ្នឹង ។

រ៉ាស៊ីៈ ហើយពូយល់ថាមនុស្សដែលពូនិយាយថាបានស្លាប់ប្រហែលបីម៉ឺននាក់ហ្នឹង ថ្វីត្បិតតែមិនមែន ឌុច ជាអ្នកសម្លាប់ទាំងអស់ តើពូយល់ថាអ្នកដែលសម្លាប់ជនរងគ្រោះទាំងអស់នោះ ទទួលបញ្ជាពីណាម៉ៅដែរ?

អ៊ុនៈ ទទួលបញ្ជាពី ឌុច ផ្ទាល់ បើគ្មានបញ្ជាពី ឌុច ទេអត់មានទេ ។

រ៉ាស៊ីៈ ខុសពី ឌុច មានពីណាអនុប្រធាន ឌុច?

អ៊ុនៈ មាន ចាន់ ។

ឃិនៈ ប៉ុន ចាន់ ហ្នឹងអត់ហ៊ានបញ្ជាសម្លាប់ទេណោះ បញ្ជាសម្លាប់ហ្នឹងមានតែ ឌុច ទេ?

អ៊ុនៈ ជួនកាលមានបញ្ជាពី ចាន់ អីដែរ ។

ឃិនៈ ប៉ុន ចាន់ ហ្នឹងមិនដឹងរស់ ឬស្លាប់ទេណោះ?

អ៊ុនៈ អត់ដឹងទេ ។

រ៉ាស៊ីៈ អញ្ចឹងពេលដែលក្រោយផ្លាស់ប្តូរទៅភ្នំពេញ តើកន្លែងហ្នឹងគេយកធ្វើអីវិញ?

អ៊ុនៈ កន្លែងហ្នឹងអត់មានយកធ្វើអីទេ មនុស្សអត់ហ៊ានទៅ ។

រ៉ាស៊ីៈ ទុកចោលរហូតទៅ?

អ៊ុនៈ បាទ! ព្រៃដុះចុក ។

រ៉ាស៊ីៈ ថ្វីត្បិតតែក្នុងជំនាន់ប៉ុល ពត ក៏ដោយក៏អត់មានពីណាទៅជិតដែរ?

អ៊ុនៈ បាទ!

រ៉ាស៊ីៈ ចុះបច្ចុប្បន្ន?

អ៊ុនៈ បច្ចុប្បន្នមានគេទៅធ្វើស្រែធ្វើអីហើយអត់អីទេ ។

យិនៈ អារណ្ដៅហ្នឹងបើសិនជាយើងទៅគាស់អីយកអាគ្រាក់ទ័រ ឬអាប្រដាប់ចូកអីទៅ អាចឃើញឆ្អឹងទេ?

អ៊ុនៈ បាទ! ឃើញៗ

វ៉ាស៊ីៈ ពូអាកន្លែងសម្លាប់ហើយហ្នឹងមន្ទីរ ១៣ ហ្នឹងស្ថិតនៅចម្ងាយពីគ្នាប៉ុន្មានដែរ?

អ៊ុនៈ អាកន្លែងសម្លាប់និងកន្លែងអី?

វ៉ាស៊ីៈ អាកន្លែង ឧទាហរណ៍ថា អ្នកទោសជាប់នៅក្នុងមន្ទីរ ១៣ ហើយយកទោសម្លាប់ដូចពូថាចាក់នឹងកាំបិតអីហ្នឹង តើនៅក្នុងរណ្ដៅត្រង់ណា?

អ៊ុនៈ នៅឃ្លាតពីគ្នា ឃ្លាតពីមន្ទីរហ្នឹងបន្តិច គ្រាន់តែឆ្លងស្ទឹងទៅខាងណោះ ។

វ៉ាស៊ីៈ ហើយសព្វថ្ងៃមានបន្សល់ទុកស្លាកស្នាមអ្វីខ្លះនៅមន្ទីរ ១៣ ហ្នឹង ដែលជាភស្តុតាងដែលអាចយើងមើលទៅឃើញថា?

អ៊ុនៈ មានរណ្ដៅមានអីអញ្ចឹងដែរ ។

យិនៈ ទៅដល់ហ្នឹងអាចរកឃើញទេ?

អ៊ុនៈ ឃើញ ។

វ៉ាស៊ីៈ ចុះអាបង្គោលគ្រាក់អីនោះ?

អ៊ុនៈ កាលមុនមានកាស្សែតគេទៅថតហ្នុងម្ដងដែរ វាទឹកវាខ្លាំងពេក មិនអាចយកពត៌មានសព្វ ។

វ៉ាស៊ីៈ ហើយចុះរកងៃហ្នុងយើងរកអស់ដែរហ្នឹងអារឿងសន្តិសុខអីហ្នឹង!

អ៊ុនៈ ឥឡូវមិនដឹងយ៉ាងម៉េចផង ខ្ញុំអត់ដែលចូលយូរហើយហ្នឹង ។ ទៅពីលើកមុនហ្នឹង ព្រៃឡើងណែនហើយទឹកវាច្រើនទៀត ។

យិនៈ សូមបញ្ជាក់អាកន្លែងហ្នឹងឲ្យបានច្បាស់ថែមទៀតទៅ លោកពូនៃអាកន្លែង ឧុច នៅគ្គី អាសន្តិសុខគ្គីរបៀបផ្ទះឈើ ផ្ទះស្លឹក ឬក៏របៀបផ្ទះធ្វើពីបេតុងបីអី?

អ៊ុនៈ វានៅក្នុងអំឡុងគុកហ្នឹងដែរ ។

យិនៈ វាធ្វើពីអី?

អ៊ុនៈ សុទ្ធតែធ្វើពីឈើ ពីស្លឹក ។

យិនៈ អាកន្លែងឃុំឃាំងអ្នកទោស?

អ៊ុនៈ អាកន្លែងឃុំឃាំងអ្នកទោសនៅក្នុងដីវិញ ។

យិនៈ ក្នុងដីវិញ?

អ៊ុនៈ បាទ!

យិនៈ ទាំងអស់?

អ៊ុនៈ បាទ!

រ៉ាស៊ីៈ អញ្ចឹងចំពោះរឿងរបស់ ឌុច ទាក់ទងជាមួយ ឌុច តើគិតថារហូតមកដល់បច្ចុប្បននេះ និងត្រូវថ្ងៃអនាគត គឺត្រូវតែមានតុលាការមួយដើម្បីកាត់ទោស ឌុច ឬក៏មិនបាច់ទេ?

អ៊ីនៈ បើតាមខ្ញុំយល់ សមរម្យឲ្យមានកាត់ទោស ត្រេកអរណាស់ ។

រ៉ាស៊ីៈ អញ្ចឹងពូចង់ឲ្យមានតុលាការដែរណោះ?

អ៊ីនៈ បាទ! តែខ្ញុំយល់ថា បើកាត់ទោសតាមរបៀបអន្តរជាតិ វាមានចំរូងចំរះច្រើនណាស់ ។

រ៉ាស៊ីៈ ម៉េចបានពូនិយាយអញ្ចឹង?

អ៊ីនៈ ពីព្រោះខ្ញុំយល់ថាខ្មែរក្រហមនេះកើតឡើងដោយអន្តរជាតិញុះញង់ដែរ ហើយបើយើងយកតុលាការអន្តរជាតិទាំងអស់ ធ្វើមិនអាចទៅបានខ្ញុំខ្លាចមិនស្មោះត្រង់អី ។

រ៉ាស៊ីៈ ចុះបើសិនជាមានតុលាការមែន តើលោកពូចង់ឲ្យតុលាការហ្នឹងកាត់ទោសតែមេដឹកនាំធំៗ ឬកាត់ទោសអ្នកដែលតូចតាចក្រោមបញ្ជាដែរ?

អ៊ីនៈ ខ្ញុំថាចង់ឲ្យកាត់មេធំៗ ។

រ៉ាស៊ីៈ ហេតុអីទៅ?

អ៊ីនៈ ព្រោះខ្ញុំបានឃើញច្បាស់ក្នុងបេះដូងខ្ញុំថា បានបញ្ជាពិតប្រាកដថាបានប្រល័យពូជសាសន៍ សម្លាប់មនុស្ស ។

រ៉ាស៊ីៈ ហើយចំពោះ ឌុច មួយដែលបានសម្លាប់បងរបស់ពូ បានធ្វើបាបពូ ហើយពូបានឃើញសកម្មភាពផ្ទាល់របស់ ឌុច ហ្នឹង តើនៅពេលដែលមានតុលាការទៅ តើលោកពូចង់ឲ្យតុលាការកាត់ទោស ឌុច ហ្នឹងយ៉ាងម៉េច? ដាក់ទោសគាត់យ៉ាងម៉េច?

អ៊ីនៈ ឌុច ហ្នឹងសមតែដាក់ទោសគាត់ឲ្យអស់មួយជីវិត អត់មានថ្ងៃចេញទៅ ឲ្យគាត់រងកម្មរងលំបាកទៅតាមដែលប្រជាជនស្លាប់រាប់លានរាប់សែននាក់ តាមកំហុសគាត់ ។ នេះជាកំហុសរបស់គាត់ ។

រ៉ាស៊ីៈ ហើយបើសិនជាមានអញ្ចឹងមែន ហើយតុលាការកាត់ទោសគាត់ដាក់គុកអស់មួយជីវិតមែន តើធ្វើឲ្យអារម្មណ៍ពូហ្នឹងយ៉ាងម៉េចដែរ?

អ៊ីនៈ អារម្មណ៍ខ្ញុំត្រេកអរជាខ្លាំងបំផុត ។ រាជរដ្ឋាភិបាលប្រកាសហើយថាឈ្មោះ ឌុច បាន..។ ខ្ញុំលើកដៃទទួល.....។ មានខ្លះគេសួរខ្ញុំថាចុះបើសិនណាជាអត់សម្តេចទៅ ពួកអាហ្នឹងចូលមកវិញតើចំពោះខ្ញុំទៅយ៉ាងណា? ខ្ញុំថាមិនអាចទៅបាន ខ្ញុំមានជំនឿ ។

រ៉ាស៊ីៈ អញ្ចឹងពូយល់ថាភាពយុត្តិធម៌ត្រូវបានផ្តល់ដោយសារតុលាការកាត់ទោសខ្មែរក្រហមហ្នឹងដែរឬទេ?

អ៊ីនៈ ភាពយុត្តិធម៌ គឺខ្ញុំយល់ថាបានផ្តល់ពីតុលាការច្បាស់ ព្រោះអីការពិតទៅវាឃើញភស្តុតាងច្បាស់អត់មានអ្វីមួយដែលប្រកែកបានទេ ។

រ៉ាស៊ីៈ ចុះបើសិនជាពូបានជួប ឌុច ឥឡូវ តើពូមានគំនិតចង់សងសឹកគាត់ទេ?

អ៊ុន: ខ្ញុំអត់មានគំនុំអីចង់សងសឹកគាត់ទេ ខ្ញុំគ្រាន់តែចង់ បើសិនជាខ្ញុំមើលឃើញហើយ ប្រាប់ថាទៅជាប់គុកមួយជីវិតទៅ ដើម្បីលាងកម្មលាងពារ សឹងឲ្យជាប់គុកអង្គុយដូចខ្មោះនៅអាមេរិកាំង គេដាក់របៀបអង្គុយឲ្យអង្គុយនៅហ្នឹងហ្នង ។ ធ្វើអាប្រឡេះបត់ជើងនៅក្រោមហ្នឹងឲ្យហើយស្រេចទៅ បាយហ្នឹងរុញទៅដល់ស៊ីហ្នឹងដេកហ្នឹងទៅ ។

ភាស៊ី: បាទ! ចុះក្រោយពេលដែលបែកភ្លាមៗ តើពេលដែលឃើញ ឌុច តើពូចង់សងសឹកដែរអត់?

អ៊ុន: ខ្ញុំចង់សងសឹកដែរ ក៏ប៉ុន្តែកាលហ្នឹងវាមានដៃជើងច្រើនណាស់ខ្មែរក្រហម ខ្ញុំមិនដឹងជាខាងណាអីណី ខ្ញុំខ្លាចមានការប៉ះពាល់ ខ្ញុំក៏សំងំស៊ុខរហូត ធ្វើល្ងង់ធ្វើអីរហូត ។

ភាស៊ី: ចុះក្រោយបែក ៧៩ ពូចេញពីមន្ទីរ ៩៩ ហើយមកវិញនៅ?

អ៊ុន: បែក ៧៩ មៅ ខ្លះគេរត់ទៅព្រៃភ្នំ ខ្លះទៅអី ខ្ញុំអត់មានរត់ទៅព្រៃភ្នំទេ ខ្ញុំបបួលកម្លាំងបួនដប់នាក់រត់មៅផ្ទះ រត់សំដៅកងទ័ពវៀតណាម ។

ភាស៊ី: ពូមៅដល់ផ្ទះក្នុងឆ្នាំណាដែរ ខែណាដែរ?

អ៊ុន: មៅក្នុង ៧៩ ហ្នឹងហ្នង ថ្ងៃរំដោះ ៧ មករាហ្នឹងហ្នង ។

ភាស៊ី: ពូមៅមានឆ្លងកាត់មន្ទីរ ១៣ ហ្នឹងទៀតទេ?

អ៊ុន: អត់ទេ! ខ្ញុំមៅកាត់យើង គេឲ្យខ្ញុំទៅនៅ ៩៩ ខ្ញុំប្រុងមៅកាត់នេះ ខ្ញុំមៅអត់រួច ដល់អញ្ចឹងខ្ញុំមៅកាត់ផ្លោះលួងនេះ មៅតាមផ្លូវជាតិលេខ៤ នេះវិញ ។

ភាស៊ី: ហើយពេលដែលពូមៅវិញហ្នឹង ពូមានដឹងរឿងរ៉ាវនៅ ៧៩ និង អមលាំង ហ្នឹង តើមានអ្វីកើតឡើងទៀតទេ?

អ៊ុន: ៧៩ ខ្ញុំអត់ដឹងទេ ប៉ុនមៅដឹងរឿងថា ពួកម៉ាកខ្ញុំវាថា វើយ! កាលពីយើង ឆ្នាំដែលយើងបែកនេះ គេយកមនុស្សទោសម្លាប់ប្រហែល ២០០០០នាក់ទៀតនៅកន្លែងមន្ទីរ ១៣ ហ្នឹង ។ យកទោសម្លាប់ចោលហ្នឹងហើយបានរត់ ។

ឃិន: អូរ! ៧៩ ហើយហ្នឹង ឌុច ទៅប្រមូលបានមនុស្សប្រហែល២០០០០នាក់ទៀតយកទៅសម្លាប់នៅមន្ទីរ ១៣ ហ្នឹងទៀត?

អ៊ុន: បាទ!

ភាស៊ី: មនុស្សហ្នឹងជាអ្នកទោសមៅពីខាងណាដែរ? គេកៀរមៅពីខាងណា ឬក៏អ្នកទោសដែលនៅ?

អ៊ុន: ខ្ញុំអត់ដឹងថាកៀរមៅពីខាងណាៗទេ គ្រាន់តែពួកម៉ាកខ្ញុំដែលធ្លាប់ធ្វើការនៅមន្ទីរ ១៣ វាបានមកប្រាប់ខ្ញុំថា ឯងមៅដល់កន្លែងនេះហើយ ឥឡូវឯងកុំខឹងនឹងអញ អញធ្វើចង់អ្វែងឲ្យតឹងៗទៅ កុំឲ្យគេថាអញក្បៀរខ្មែរពួកម៉ាកអី ។ វានិយាយប្រាប់អញ្ចឹង ។ នៅមុខ ឌុច វាចងតឹង ដល់ពេលនេះទៅវាធ្វើធូរ មុជទឹកមុជអី ។ តែអត់បាយនៅតែអត់អញ្ចឹង ម៉ាពេលស៊ីតែបិណ្ណោះគត់

ភាស៊ី: ពួកម៉ាកលោកពូដែលថាជាកងការពារហ្នឹងឈ្មោះអី?

អ៊ិនៈ ឈ្មោះ វឿន ។

វ៉ាស៊ីៈ ឥឡូវគាត់នៅរស់ទេ?

អ៊ិនៈ នៅរស់ ។

យិនៈ នៅឯណា ដែលថានៅខាងកុមារមាសហ្នឹងអ្ហេះ?

អ៊ិនៈ បាទ!

វ៉ាស៊ីៈ តើពូមានអ៊ីចង់បន្ថែមទៀតទេ?

អ៊ិនៈ ខ្ញុំគ្មានអ៊ីបន្ថែមទេ ខ្ញុំគ្រាន់ថា ខ្ញុំអរគុណដែលរាជរដ្ឋាភិបាលបានសម្រេចកាត់ទោសមេដឹកនាំខ្មែរក្រហមឆាប់ៗនេះឲ្យឃើញច្បាស់ ។

វ៉ាស៊ីៈ អរគុណលោកពូច្រើន ។

យិនៈ ហើយចុងក្រោយខ្ញុំចង់បន្តបន្តិចទេ ដើម្បីជាពន្លឺសម្រាប់យើងស្រាវជ្រាវជាបន្តទៅទៀត ពីព្រោះពត៌មានដែលគាត់ផ្តល់ឲ្យមកយើងនេះវាច្បាស់ហើយ ច្រើនណាស់ហើយ ។ ប៉ុន្តែយើងឈានទៅកងការពារ ឬជនរងគ្រោះមួយចំនួនដែលខ្ញុំបានដកស្រង់ ។ ខ្ញុំចង់សួរកូនមេឃុំ ភឿង ដែលមានឈ្មោះ អាវិន ឈ្មោះ អាវី តើនៅរស់ទេ?

អ៊ិនៈ អាវិន អាវី អាហ្នឹងពួកម៉ាកខ្ញុំដែរ ។

យិនៈ ឥឡូវនៅឯណា?

អ៊ិនៈ អាវី នៅរស់ បើអាវិន ស្លាប់ហើយ ។ អាវិន ពួកម៉ាកខ្ញុំ ។ មុនដំបូងយកទៅជាប់គុកហ្នឹងខ្ញុំធានា ដល់ តាឌុច សួរអញ្ចឹងទៅ សួរថាអ្ហែងស្គាល់ អ៊ិន អត់ ។ វាថា អ៊ិន ពួកម៉ាកខ្ញុំកាលវាសួរថា វិន ពួកម៉ាក អ៊ិន ឯងមែនទេ ។ បាទ! ខ្ញុំពួកម៉ាកមែន ។ អ៊ិន ឯងហ៊ានធានាអត់? បើហ៊ានធានាអញលែង អាវិន ។ ហ៊ឺ! ខ្ញុំអត់ទាន់ហ៊ានទេតា ព្រោះអីចាប់បងប្អូនវាទាំងអស់មៅ៉ហើយ ខ្លាចលោវារត់វាបោលអី ។ ដល់មៅ៉សួរលើកទី២ទៀត ខ្ញុំសម្រេចថាហ៊ានធានា តែខ្ញុំយកជាប់ហ្នឹងខ្លួនខ្ញុំ ។

យិនៈ ឥឡូវទៅឯណា វិន ហ្នឹង?

អ៊ិនៈ អាវិន ហ្នឹងដល់ពេលនេះ ឌុច វាបញ្ជូនទៅពោធិ៍សាត់ ។

យិនៈ ចុះ វី រស់នៅឯណា?

អ៊ិនៈ វី រស់នៅ ។ កាលមុនធ្វើការទាហាន តែឥឡូវមិនដឹងនៅឯណាទេ ។

យិនៈ មួយទៀតឈ្មោះ កុំ?

អ៊ិនៈ អាប្អូនអាបងអីហ្នឹង សុទ្ធតែបងប្អូននៅខុត្តុង ។

យិនៈ បាទ! ហ្នឹងសុទ្ធតែជនរងគ្រោះហើយណោះ?

អ៊ិនៈ បាទ!

យិនៈ បងប្អូន បងអីអត់មាននៅភូមិហ្នឹងទេណោះ ដែលកូនមេឃុំ ភឿង ហ្នឹងអ្នាស?

អ៊ីនៈ បាទ! កូនមេឃុំ ភឿង អាអូន អាបង អាវី អារិន ។

យិនៈ មាននៅរស់ស្រុកហ្នឹងដែរ?

អ៊ីនៈ នៅរស់ សព្វថ្ងៃនៅរស់ ។

យិនៈ អើ! នៅភូមិអី? ឃុំអមលាំងអ្ហេះ?

អ៊ីនៈ បាទ! ភូមិតាជៅ៉ង ឃុំអមលាំង ។

យិនៈ សួររកកូនមេឃុំទៅណោះ?

អ៊ីនៈ បាទ!

យិនៈ អរគុណហើយ នេះជាចំណុចមួយល្អហើយ ។ ទី២ឈ្មោះជនរងគ្រោះដែរ ឈ្មោះ ខុម នៅរស់ដែរ? ជាប់ជាមួយអឹដែរ?

អ៊ីនៈ ខុម ណាអញ្ចេះ!

យិនៈ ចុះ ស៊ិន ជនរងគ្រោះដែរ ។

អ៊ីនៈ ស៊ិន ស្គាល់ ។

យិនៈ នៅរស់ទេ?

អ៊ីនៈ នៅរស់ ។

យិនៈ នៅឯណា?

អ៊ីនៈ នៅឃុំអមលាំង ។

យិនៈ តាង៉ែត នៅចុងស្ពាននៅរស់ទេ?

អ៊ីនៈ ស្លាប់បាត់ហើយ ។

យិនៈ មានមួយទៀតឈ្មោះ វ៉ន ហៅអាលី ពួកម៉ាកដែរអ្ហេះ? ឬក៏ ខន ហ្នឹង វ៉ន ខន ដូចគ្នា?

អ៊ីនៈ វ៉ន មាននៅនេះ ។

យិនៈ ហ្នឹងកងការពារដែរអ្ហេះ?

អ៊ីនៈ បាទ! នៅកន្លែងតា ស៊ុមនេះ ។

យិនៈ កន្លែងនគរបាល ។

អ៊ីនៈ វ៉ន នេះនៅ សំរោង ។

យិនៈ ភូមិសំរោងអ្ហេះ?

អ៊ីនៈ បាទ!

យិនៈ ឃុំ?

អ៊ីនៈ ឃុំមនោរម្យ ។

ឃិនៈ មនោរម្យ វាររៀបកុមារមាស ហ្នឹងអ្ហេះ ជាមួយគ្នា?

អ៊ីនៈ សំរោងនៅមនោរម្យហ្នឹងហ្នង ។

ឃិនៈ ថាមានម្នាក់ពួកម៉ាកល្បែងឯងដែរ ថាមាឌរាងខ្ពស់ប្រគ្រោង ។ នែ៎! អត់អីទេ អញ្ចឹងខ្ញុំបញ្ចប់ទៅចុះ បានដឹងពត៌មានច្រើនហើយណាស់ ។ អរគុណ! ។

អ៊ីនៈ បាទ!

វ៉ាស៊ីៈ តាសៅ អ្នកចាប់ពូ?

អ៊ីនៈ បាទ!

វ៉ាស៊ីៈ គាត់ឈ្មោះអី សៅ ដែរ?

អ៊ីនៈ អត់ដឹងដែរ ។ អត់ដឹងនាមត្រកូលគាត់ទេ ។

ឃិនៈ ចុះពួកម៉ាកលោកពូមួយទៀតឈ្មោះអា ថន នៅឯណា? មានជាប់ជាមួយគ្នាទេ? ឬជាជនរងគ្រោះដែរ ឬជាកងសន្តិសុខ? អត់មានស្គាល់ទេណោះ?

អ៊ីនៈ មិនមែនថាមិនស្គាល់ទេ ក្រែងលោភ្លេច ។

ឃីនៈ ចុះមួយទៀតស្មៀន ឃឿន នៅឯណា? ជនរងគ្រោះដែរ?

អ៊ីនៈ អត់ជនរងគ្រោះទេ ធ្លាប់នៅជាមួយគ្នា ។

ឃីនៈ ចុះមួយទៀតឈ្មោះ អាចៀម នៅឯណា? ជនរងគ្រោះដែរ? ចុះឈ្មោះ អាឈីវ នៅឯណាដែរ? ហ្នឹងជនរងគ្រោះដែរយ៉ាងម៉េច?

អ៊ីនៈ អត់ជនរងគ្រោះទេ ។

ឃីនៈ ចុះមួយទៀតឈ្មោះ អ៊ី សុខា អ៊ី សុខុម នៅឯណាហ្នឹង?

អ៊ីនៈ ស្មៀន ឃឿន ស្មៀន ឈិន ស្មៀន ឈៀង ស្មៀន ឈីវ ។

ឃីនៈ ពួកហ្នឹងជនរងគ្រោះដែរម៉េច?

អ៊ីនៈ អត់ទេ! អត់ជនរងគ្រោះទេ គ្រាន់តែធ្លាប់នៅជាមួយគ្នា ។ មិនមែនជាពួកម៉ាកទេ គ្រាន់តែធ្លាប់ឃើញ ។ បើ អាវិន បានពួកម៉ាក ។

ឃីនៈ ប៊ុន វិន កងការពារដែរ?

អ៊ីនៈ បាទ!

ឃីនៈ មិញប្រាប់ខ្ញុំថា វិន ហ្នឹងនៅរស់ដែរ?

អ៊ីនៈ បាទ!

ឃីនៈ នៅឯណា?

អ៊ីនៈ នៅសំរោងយើងនេះ ។

---

**ករណី មន្ទីរសន្តិសុខ ១៣ (ម-១៣)**
**សម្ភាសន៍ជាមួយ ចាន់ វឿន អាយុ៤៩ឆ្នាំ**
**ភេទប្រុស រស់នៅភូមិកុមាររមាស ឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ**
**ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៣**

**ផ្នែក "ក"**

យិនៈ លោកពូឈ្មោះអីដែរ?

វឿនៈ ចាន់ វឿន ។

យិនៈ អាយុប៉ុន្មានហើយ?

វឿនៈ ៤៩ឆ្នាំ ។

យិនៈ លោកពូមានប្រពន្ធឈ្មោះអីដែរ?

វឿនៈ ប្រពន្ធឈ្មោះពីរហើយខ្ញុំ ។ ប្រពន្ធមុនឈ្មោះ ហង់ គួច ។

យិនៈ ចុះក្រោយមោ៉?

វឿនៈ ក្រោយ សុះ យឿន ។

យិនៈ មានកូនប៉ុន្មាននាក់?

វឿនៈ ប្រពន្ធមុនកូន៥ ។

យិនៈ ក្រោយ?

វឿនៈ ក្រោយអត់មាន ។

យិនៈ ពូសព្វថ្ងៃនៅភូមិអី ឃុំអី ស្រុកអី ខេត្តអី?

វឿនៈ ខ្ញុំ នៅភូមិកុមាររមាស ឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ។

យិនៈ លោកពូ ឪពុកលោកពូឈ្មោះអីដែរ?

វឿនៈ ចាន់ ឌួង ។

យិនៈ ម្ដាយ?

វឿនៈ ពែក គោ ។

យិនៈ បងប្អូនបង្កើតពូមានប៉ុន្មាននាក់?

វឿនៈ មាន៦នាក់ ។

យិនៈ ប្រុសប៉ុន្មាន ស្រីប៉ុន្មានដែរ?

វឿនៈ មើល! ១ប៉ក់ ២ឌឿន ៣ម៉ុន ម៉ុច......

យិនៈ អរគុណ! ឥឡូវស្រួតមកដល់នេះវិញ ខ្ញុំសួរថាក្នុងសម័យប៉ុលពត សម័យខ្មែរក្រហម ពូរស់នៅទីណា នៅជាមួយអ្នកណា ហើយអាយុប៉ុន្មាន?

វឿនៈ សម័យខ្មែរក្រហម អត់ដឹងអាយុផងខ្ញុំ ។

យិនៈ ហើយចុះចលនាដែលគេឲ្យពូចូលទៅធ្វើការហ្នឹងពូអាយុប៉ុន្មាន?

វឿនៈ អត់ដឹងផង ។

យិនៈ ពូនៅជាមួយឪពុកម្តាយអ្ហេះ?

វឿនៈ អត់ទេ! ខ្ញុំនៅជាមួយទព័ ។

យិនៈ អញ្ចឹងមុនដំបូងពូនៅទព័ទេ?

វឿនៈ បាទ!

យិនៈ ហើយ អ្នកណាទៅដក?

វឿនៈ ខ្ញុំរត់ចេញពីទព័មោ៉ គេបញ្ជូនខ្ញុំទៅហ្នឹងហ្នឹង ទៅមន្ទីរ១៣ ។

យិនៈ រត់ចេញពីទព័?

វឿនៈ បាទ!

យិនៈ រត់ទៅណា?

វឿនៈ រត់មោ៉ក្រោយវិញ ។ជំនាន់ហ្នឹង រត់ពីខ្មែរក្រហមចូលមកខ្មែរក្រហម ។

យិនៈ រត់មោ៉ក្រោយនៅត្រង់ណា?

វឿនៈ នៅកុមារមោសដដែល ។ ប៉ុនគេបញ្ជូនខ្ញុំមកហាត់ហ៊ឹកហ៊ឺននៅអី តាសាយ យើងនេះ តាសាយហាណូយ ។

យិនៈ ហាត់ខាងអី?

វឿនៈ ហាត់ខាងបច្ចេកទេសខាងទព័ហ្នឹង ហើយបាន តាឌុច ហ្នឹងគេមោ៉រើសកងកម្លាំងការពារ ហើយជ្រើសយកខ្ញុំហើយនឹង ដុំ ពីរនាក់ ។

យិនៈ ប៉ុន្មាននាក់?

វឿនៈ ២ នាក់

យិនៈ ដុំ មួយដែរ?

វឿនៈ បាទ!

យិនៈ ដុំ ឥឡូវនៅឯណា?

វឿនៈ អត់ដឹងទេបង បែកគ្នា មិនដឹងឋាប់ឬ រស់ ។

យិនៈ ពេលយកហ្នឹង តើ ឌុច មាននិយាយអីជាមួយលោកពូខ្លះ?

វឿនៈ អត់និយាយអីទេ គ្រាន់ថាកងការពារសើបបានហើយ បានប៉ុន្មាន បានពីរនាក់ៗ ពីរហ្នឹងគេបញ្ជូនខ្ញុំទៅនៅបានមួយអាទិត្យ គេចាត់តាំងខ្ញុំឲ្យទៅនៅខាងសេដ្ឋកិច្ចៗ

យិនៈ សេដ្ឋកិច្ចមន្ទីរ ១៣ ហ្នឹង?

វឿនៈ បាទ! សេដ្ឋកិច្ចមន្ទីរ ១៣ ហ្នឹងឲ្យរកស្រូវរកអង្ករហូតរលាក់កងជើងហ្នុងៗ អត់បាននៅក្នុងទេ នៅក្រៅរហូតៗ ខ្ញុំចេះតែដើរៗអញ្ចឹងទៅជាមួយខ្មោចតា កយ ហ្នឹងៗ ដល់ថ្ងៃមួយគេឲ្យខ្ញុំនៅចាំកន្លែង១ ខ្ញុំឃើញពួកម៉ាកខ្ញុំបីនាក់ ខ្ញុំអង្គុយគិតហ្នង ហ៊ឺ!មិនគួរយកពួកម៉ាកខ្ញុំមកដាក់គុកអញ្ចឹងអត់កើតទេៗ រួចគេឲ្យខ្ញុំយាម១ចាំពួកម៉ាកហ្នឹងទៀត ខ្ញុំមើពីរលាក់កងជើងវិញៗ ខ្ញុំថាតោះអាពួកម៉ាក អ្អែងកាត់ប្រវ៉ាក់រត់ទៅ ចាំអញបាញ់ពីក្រោយ បាញ់ឡើងលើៗ ដល់អញ្ចឹងវាឲ្យទៅលើកទំនប់ប៉ាំងទីហ្នឹង ដល់អញ្ចឹងវាកាត់រត់ រត់បានប្រហែលម៉ាសន្ទុះ ខ្ញុំបាញ់៥គ្រាប់ឡើងលើៗ បាញ់ហើយបានពួកហ្នឹងឡើងឈុលៗ ឈុលមើវាថាមុខសញ្ញាខាងណា អាឌុច វាសួរណាស់ គេថាខាង តាវឿន មើលហៅអាវឿន មើណេះ អ្អែងទៅដកកាំភ្លើងវា ដោះខោអាវវាទុកតែខោខ្លីទៅបានហើយៗ មើដល់ដកកាំភ្លើងមែន ដោះខោអាវអស់អាលីងនៅសល់តែខោខ្លីខ្ញុំ ទៅដល់បញ្ចូលគុក គេចាក់សោរខ្ញុំនេះ គេអត់ទាន់ដាក់ជើងទេ គេនៅចងជាប់កន្លែងមន្ទីរគេ...........ព្រឹកឡើងបានគេបញ្ចូលដាក់ខ្នោះខ្ញុំៗ ហ្នឹង ឌុច ហ្នឹងណាបង សាហាវណាស់អាហ្នឹងៗ

យិនៈ បាទ! លោកពូ តើគេដាក់ខ្នោះលោកពូរយៈពេលប៉ុន្មានថ្ងៃ ប៉ុន្មានខែ?

វឿនៈ ដាក់ខ្នោះហ្នឹងបានប្រហែលម៉ាអាទិត្យទេៗ ដល់ពេលចេញធ្វើការដាក់ប្រវ៉ាក់ករ១ វាយាមផ្ទាល់ដៃវា មានអាការបត់ម៉ាដើមៗ

យិនៈ ពីណាយាម?

វឿនៈ អា ឌុច ហ្នឹងៗ

យិនៈ ហើយចុះពេលធ្វើការហ្នឹង ធ្វើតែលោកពូម្នាក់ឬក៏មានអ្នកទោសច្រើនដែរ?

វឿនៈ អ្នកទោសច្រើនដែរ ប៉ុនខ្ញុំថ្ងៃហ្នុងគេយកខ្ញុំទៅតែឯងឲ្យទៅកាប់ដីៗ

យិនៈ ទៅតែម្នាក់ឯងហ្នឹង? ហើយ ឌុច ហ្នឹងយកអាកាម៉ាដើមយាមតែម្នាក់ឯងហ្នឹង?

វឿនៈ អាការមួយ អង្រឹងមួយៗ ខ្ញុំគេដាក់ប្រវ៉ាក់ករចងភ្ជាប់ដើមឈើឲ្យកាប់ដីៗ រួច ឌុច វាយាមៗ បានប្រហែលអញ្ចឹងទៅ ខ្ញុំអត់រស់ទេ មុខតែស្លាប់ហើយខ្ញុំ អត់កើត ដល់អញ្ចឹងទៅចូលទៅក្នុងគុកវិញ ខ្ញុំគិតជាមួយ ខនៗ

យិនៈ យប់បញ្ចូលពូទៅក្នុងគុកវិញ?

វឿនៈ បាទ! បញ្ចូលក្នុងគុកវិញ ដល់ពេលអញ្ចឹងខ្ញុំគិតជាមួយ អាខនៗ អាខន ហ្នឹងវាត្រូវសាច់ក្លួយខ្ញុំផង ខ្ញុំថាអា ខន ថ្ងៃហ្នឹងអញរត់ហើយ អ្អែងធ្វើម៉េចដោះករជើងអញរត់ហើយយប់ហ្នឹងៗ អា

ខន វាថាអត់អីទេពូ ពូឯងរត់ចេះ ហើយយប់ឡើងខ្ញុំរត់មែនៗ រត់មៅៗដល់...........លូអំពៅ គាត់អស់ប្រាំដើមទៀត ខ្ញុំឃ្លានពេកៗ ពេលដាក់គុកហ្នឹងគេឲ្យហូបបបរតិចៗ ។ ដល់អញ្ចឹងក៏បានប្រហែលម៉ាអាទិត្យជាង ក៏ប្រធានភូមិគេធានាខ្ញុំថា គេហៅវឿន ឯងទៅវិញហើយ ។ ដល់ទៅវិញខ្ញុំភ័យណាស់ មុខថាងាបហើយពេលហ្នឹងអត់រស់ ។ គេថាទៅ ខ្ញុំធានា កាលហ្នឹងខ្មោច តា ហម និងតាសោម យើងនេះ ។ គាត់ថាទៅអត់អីទេ ខ្ញុំធានា ។ ទៅដល់អត់អីមែន ខ្ញុំគិតថា កាំភ្លើងខ្វីវាហ្នឹងប៉េះកណ្តាលថ្ងាស់លើវាលហ្នឹងហើយ ខ្ញុំអង្គុយនៅលើ......ហ្នឹង ។ វាថាអ្ហែងរត់ទៅអត់អីទេនៅហ្នឹងហើយ អ្ហែងនៅហ្នឹងសិនហើយ ។

ឃិនៈ គេឲ្យធ្វើអីទៀតក្រោយអាពេលដែលគេយកទៅ?

វឿនៈ បាទ! អត់មានឲ្យធ្វើអីទេ ។ ប៉ុនថាឲ្យនៅហ្នឹងហើយ ឲ្យបាននៅជាជាងកន្លះខែ បានឃើញក្រដាសចេញមៅថាឲ្យខ្ញុំចេញ ។

ឃិនៈ ឲ្យចេញ?

វឿនៈ បាទ! ឲ្យចេញហ្នឹងខ្ញុំភ័យទៀត ហ៊ឺ! មិនដឹងជាក្រដាសខៀវ ឬក្រដាសក្រហមទេ ។ បើក្រហម មុខជាងាប់ហើយ ។

ឃិនៈ ក្រដាសក្រហមបានន័យថាម៉េច អក្សរអី?

វឿនៈ បើក្រហមថាងាប់ ។

ឃិនៈ ប៉ិចក្រហមអ្ហេះ?

វឿនៈ បាទ! ប៉ិចក្រហម ។ ដល់អញ្ចឹងខ្ញុំសុំ អាហឹំ មើល ។ អាហឹំ អញសុំក្រដាសអ្ហែងមើលបន្តិច អាហឹំ ហ្នឹងក៏ឲ្យខ្ញុំមើល ។ មើលទៅឃើញខៀវទេ អ្ហេ! មានខបាយកលអីទៀតអញ្ចេះ! គេបញ្ជូនខ្ញុំមៅដល់ស្ពានអី អូរពន្ទក អូរអឺបង! ស្ពានថ្មគុបនេះ អូរ(នុបពពក) ក៏បានស្នាក់ការគេថា ឥឡូវពូឯងទៅផ្ទះទៅអត់អីទេ ។ ទេ! អត់ទុកចិត្តទេ បងជូនខ្ញុំទៅ សាលាយើងនៅកន្លែងស្រុកនេះ គាត់ធ្វើការហ្នឹង គាត់ថាទៅៗអត់អីទេ មានក្រដាសហ្នឹងហើយអត់អីទេ ក៏ខ្ញុំមៅ ។ ប៉ុនសភាពនៅក្នុងមន្ទីរហ្នឹង តាឌុច ហ្នឹងឃោរឃៅណាស់ ។ មិនត្រឹមតែអ្នកទោសទេ ដូចខ្ញុំថាអញ្ចឹងសូម្បីកងការពារដែលធ្វើការជាមួយគាត់ ដែលធ្លាប់វ៉ៃអ្នកទោសសួរចម្លើយក៏គាត់សម្លាប់ដែរ មានដូចផល ហ្នឹង មាន ប៉ុន ហ្នឹង សុទ្ធតែអ្នកដែលធ្លាប់វ៉ៃអ្នកទោសសួរចម្លើយដែរ យូរៗទៅៗជាគេវ៉ៃគាត់ចោលអស់ដែរ ។ ពេទ្យ សំ នេះអញ្ចឹងដែរ ។

ឃិនៈ ពេទ្យឈ្មោះអីដែរ?

វឿនៈ ពេទ្យ សំ ។

ឃិនៈ គាត់ខុសអី?

វឿនៈ អត់មានខុសអីទេ ដែលយូរៗទៅ ថាគាត់អីណាណីវ៉ៃគាត់ចោលបាត់ទៀតទៅ ។

យិនៈ អាហ្នឹងអ្នកដែលធ្វើការជាមួយគាត់?

វឿនៈ បាទ! អ្នកដែលធ្វើការជាមួយគាត់ ដូច ប៊ុនអីហ្នឹង ។

យិនៈ ចុះអ្នកដទៃដែលគាត់មានដែលបានសួរចម្លើយផ្ទាល់ទេ?

វឿនៈ សួរខ្ញុំអ្ហេះ?

យិនៈ ទេ! សួរអ្នកដទៃ ។

វឿនៈ សួរអ្នកដទៃ សួរដែរ ។ សួរវ៉ៃ ហើយដើរដុតទៀតណោះ អាណាមិនស្រែកដុត ស្មោកខ្មោចខ្ទីរ អស់ហើយ ។ រឿងនេះដាក់ស្ដែងពិតអញ្ចឹងហ្នង ដាក់ស្ដែងពិតអញ្ចឹងហ្នង កាចណាស់ បើថាវា ចង់បាញ់អាណាបាញ់អាហ្នឹងហើយ ។

យិនៈ ចុះពូនិយាយមុនពេលសម្ភាសន៍ថាមានឃើញ ឌុច ហ្នឹងបាញ់ផ្ទាល់ដៃប៉ុន្មាននាក់?

វឿនៈ ឃើញបាញ់ផ្ទាល់មួយ ។

យិនៈ បាញ់កាំភ្លើងខ្លីអី?

វឿនៈ បាញ់អាការ ។

យិនៈ ហ្នងអ្នកទោសឬក៏ស្អី?

វឿនៈ អ្នកទោស ។ បាញ់អ្នកទោស ខឹងសួរអត់ចេញបាញ់.............បាញ់បីគ្រាប់ ប៉ុនមិនដឹងឈ្មោះ អីខ្ញុំ មិនស្គាល់ឈ្មោះដែរណាស់ ។

វ៉ាស៊ីៈ ពូខ្ញុំចង់សួរពូសារដើមឡើងវិញបន្តិចណាពូណាស់?

វឿនៈ បាទ!

វ៉ាស៊ីៈ ពូចូលធ្វើទាហានតាំងពីឆ្នាំណា?

វឿនៈ ទាហានយើងអី ។

វ៉ាស៊ីៈ ទាហានខ្មែរក្រហមនៅមន្ទីរ ១៣?

វឿនៈ ១៩៧០ខ្ញុំនៅផ្លូវជាតិលេខ៥ ដល់ខ្ញុំវាវ៉ៃបាក់ទៅខ្ញុំខ្លាច ខ្ញុំរត់មកក្រោយវិញ ។ ដល់រត់មក ក្រោយហ្នឹង ក៏គេរើសកម្លាំងទៅនោះ ខ្ញុំអត់ដឹងទេ គេថារើសកម្លាំងពីរនាក់ហាត់របៀបទ័ សង្គ្រាមហ្នឹង ។ ហាត់ៗក៏បញ្ជូនខ្ញុំទៅក្នុងបាត់ទៅ ។

វ៉ាស៊ីៈ ទាហានដែលពូចូលហ្នឹង ទាហានលន់ ណុល ឬទាហានខាងខ្មែរក្រហម?

វឿនៈ ខាងខ្មែរក្រហម ។

វ៉ាស៊ីៈ អ្នកណាដែលជ្រើសរើសពូចូល?

វឿនៈ ជ្រើសរើស តាដុន ហាណូយ ។

វ៉ាស៊ីៈ ម៉េចបានគេហៅ តាខុន ហាណូយ?

វឿនៈ ចុះបើគាត់មកពីហាណូយ ។ ប៉ុនគាត់ហ្នឹងក៏ស្លាប់ដែរហើយ ។

ភ៉ាស៊ីៈ នៅពេលដែលពូចូលអញ្ចឹង នៅក្នុងឃុំអមលាំងយើងនេះ មានបង្កើតជាមន្ទីរសន្តិសុខអីនៅ?

វឿនៈ មាននៅហ្នុងហ្នុង មាននៅមន្ទីរ ១៣ ហ្នុង ។

ភ៉ាស៊ីៈ អញ្ចឹងមន្ទីរ ១៣ ហ្នឹងមិនមែនមានតាំងពីឆ្នាំ១៩៧២ម៉ោទេអញ្ចឹង?

វឿនៈ មិនដឹងមានពីឆ្នាំប៉ុន្មាន បើខ្ញុំចូលទៅឃើញខ្ញុំឡើង អូរ! អត់កើតទេដល់ឃើញអញ្ចឹង ភ័យខ្លួន ហ្នុង វាមិនដែលឃើញ ។

ភ៉ាស៊ីៈ ហើយនៅក្នុងឆ្នាំណាដែលពូមានប្រសាសន៍ថា ឌុច បានមកហៅពូម៉ោនៅក្នុងមន្ទីរ ១៣អ្នាស់ ដែលគេជ្រើសរើសយកតែពីរនាក់ម៉ោ?

វឿនៈ ១៩៧៣ ។ បាទ! ចាំ ៧៣ ។

ភ៉ាស៊ីៈ ហ្នឹង ឌុច ហៅម៉ោអ្ហេះ?

វឿនៈ ឌុច គេគ្រាន់តែជ្រើសរើសទេ ប៉ុនមានគេណោះអ្នករើស ។ តាខុន ហាណូយហ្នឹងអ្នករើស ។ គ្រាន់តែរើសបានហើយ ហាត់រៀនបានតែ៦ងៃ បញ្ជូនខ្ញុំទៅហ្នុង ។

ភ៉ាស៊ីៈ ពេលដែលរើសឈ្មោះពូបានហើយ គេយកពូទៅរៀនសិន?

វឿនៈ អត់ទេ! គេនៅបង្ហាត់ហ្នឹង ពួកហាណូយគេបង្ហាត់ហ្នឹង ។ ហាត់បានតែ៦ងៃ គេបញ្ជូនទៅហ្នុង ហ្នុង ។

ភ៉ាស៊ីៈ ហើយម៉េចបានគ្នាម៉ាគំនរ បែជាជ្រើសរើសតែពូហើយហ្នឹងពួកម៉ាកពូអញ្ចឹង?

វឿនៈ ខ្ញុំអត់ដឹងដែរ បើគេរើសយកតែពីរនាក់ៗ បើគេកម្លាំងនោះនៅខ្វះកម្លាំងពីរនាក់ ។

ភ៉ាស៊ីៈ អញ្ចឹងចំពោះពូ និងមិត្តភក្រ័ពូម្នាក់ទៀត បានន័យថាជាកម្លាំងមួយពិសេសក្នុងចំណោមកម្លាំង ដែលពូហាត់ជាមួយហ្នឹងមែនទេ?

វឿនៈ បាទ! ហាត់ជាមួយគ្នា ។ ហាត់ហើយចេញទៅហ្នុង ។

ភ៉ាស៊ីៈ ឥឡូវនៅពេលដែលពូចូលទៅដល់មន្ទីរ១៣ តើពូឃើញអ៊ីមុនដំបូងគេ?

វឿនៈ ទៅដល់ឃើញតែអ្នកទោសដែលគេចងរដូករណែល ខ្សែអង្រឹង ហើយខ្ញុំនេះវាមិនដែលឃើញ ខ្វះស្រាតខោស្រាតអាវអស់អញ្ចឹង ខ្ញុំឡើងចង់បាត់ព្រលឹងអស់ហើយ ។ មនុស្សវាអត់ដែលឃើញបាទ! ។ ទៅដល់ខ្ញុំដល់ហើយ តែមិនដឹងធ្វើម៉េចបើមនុស្សគេយកទៅហើយ ។ ឲ្យយកទៅទៅ បានប្រហែល២០ថ្ងៃ គេក៏ចាត់កម្លាំងខ្ញុំថា វឿន ឯងឥឡូវខ្ញុំឲ្យនៅខាងសេដ្ឋកិច្ច ដើររកអង្ករកស្រូវឲ្យអ្នកទោស ។ អាក្រណាត់អង្រឹងយើងហ្នឹង អានីឡុងយើងហ្នឹងយកទៅដូរស្រូវ ។ ដល់ដើរដូរស្រូវដូរអីទៅ យើងខ្ញុំម៉ោចូលកន្លែងម្តងៗ ឃើញតែទារុណកម្មអ្នកទោសលាន់ទ្រហោ មិនដឹងជាស្អីៗទេបងអ៊ើយបងអ៊ើយពិបាកមើលណាស់ ។

ភ៉ាស៊ីៈ ពេលដែលពូចូលទៅ តើចូលទៅជាមួយនរណាគេ?

រឿនៈ ចូលទៅជាមួយ ជុំ ហ្នឹង។ ជុំ ហើយនៅខាងក្រាំងចំបក់ ប៉ុនឥឡូវមិនដឹងទៅណាទេអត់ដែលជួបគ្នាសោះ មិនដឹងស្លាប់ ឬរស់ នៅជាប់ជាមួយ ឌុច អត់។

វ៉ាស៊ីៈ ភូមិអី?

រឿនៈ ក្រាំងចំបក់

វ៉ាស៊ីៈ ឃុំ?

រឿនៈ ឃុំអមលាំងដែរ នេះត្រង់ណេះហ្នឹង។

វ៉ាស៊ីៈ ពូទៅធ្វើជាកងការពារនៅហ្នឹងអេះ?

រឿនៈ បាទ! ទៅដល់គេឲ្យនៅកងការពារ ប៉ុនគេមិនទាន់ឲ្យយាមអ្នកទោសភ្លាមទេ ទៅដល់គេនៅផ្សាំយើងបន្តិចសិន។

វ៉ាស៊ីៈ បាទ! ឌុច ហ្នឹងមានម៉ៅប្រាប់ពូថាម៉េចទេ?

រឿនៈ ឌុច ហ្នឹងគ្រាន់ថាខ្វះកងកម្លាំងការពារ អ្អែងទៅនៅជួយការពារនោះសិនទៅ។ នៅបានប្រហែលជាងមាំអាទិត្យ បានគេចាត់តាំងខ្ញុំឲ្យមៅនៅខាងសេដ្ឋកិច្ចវិញ។ បាទ! តែខ្ញុំមួយទេ ហើយហ្នឹងតាសយ ឥឡូវគាត់ស្លាប់បាត់ហើយ។ តាសយ នៅផ្ទះ តែពីរនាក់តា សយ ហ្នឹងទេ។

វ៉ាស៊ីៈ ចុះកងការពារអ្នកទោស ក្រែងពូធ្លាប់ធ្វើដែរអេះ?

រឿនៈ ធ្វើ! គ្រាន់កម្លាំងខ្ញុំមួយគេឲ្យចេញក្រៅ គ្រាន់តែដើររកស្បៀងឲ្យអ្នកទោស។ ដូចខ្ញុំនិយាយថាមានបងប្អូននិងអ្នកជាប់ទោសអញ្ចឹង គេផ្ញើបាយ ផ្ញើនំអីអញ្ចឹងទៅ អត់ហ៊ានឲ្យ ឌុច ហ្នឹងដឹងទេយកទៅលាក់ក្នុងព្រៃចង្ក្រំបានបញ្ចេញយកទៅឲ្យអ្នកទោស។ ដូច អ៊ីន ពួកម៉ាកខ្ញុំសួរមើលចុះ។ ខ្ញុំបញ្ចេញយកឲ្យវា ថ្នាំជក់អី បាយ នំកន្ទក់ក៏ដោយ។ មានតែនំកន្ទក់ទេ ហើយតែឲ្យគេដឹងនាប់ហើយគ្មានរស់ទេ។

វ៉ាស៊ីៈ ពូខ្ញុំចង់កងការពារនៅក្នុងមន្ទីរ១៣ ហ្នឹងតើមានបែងចែកជាក្រុម បែងចែកជាវរសេនាតូច ឬកងអីទេ?

រឿនៈ មានបែងចែក។

វ៉ាស៊ីៈ បែងចែកយ៉ាងម៉េច?

រឿនៈ បែងចែកជា ១)កម្លាំងកងការពារអ្នកទោសធ្វើការពេលថ្ងៃ។ កម្លាំងទី២)ជាជនចម្រើនរបស់គេនោះ ដែស្តាំរបស់គេហ្នឹងណា។ អាហ្នឹងគេសម្រាប់មានការអី យកមនុស្សទៅសម្លាប់ត្រង់ណាត្រង់ណាអីហ្នឹង អាហ្នឹងមានកម្លាំងផ្សេងរបស់គេទៅ។ កងការពារគឺគ្រាន់តែការពារអ្នកទោសកុំឲ្យរត់ទេ។ ដូចខ្ញុំអីហ្នឹងគ្រាន់តែកងការពារធ្វើការពេលថ្ងៃអីមើលអ្នកទោសកុំឲ្យរត់ចេញទេ។

វ៉ាស៊ីៈ បើតាមខ្ញុំសម្ភាសន៍ឈ្មោះ ឌិន ដែលពូបានស្គាល់ដែរនោះ គាត់ថាគាត់នៅក្នុងកងការពារដែរ តែគាត់នៅក្នុងក្រុមមើលអ្នកទោសធ្វើការ តើគាត់និយាយហ្នឹងពិតទេលោកពូ?

វឿនៈ ខ្ញុំអ្ហេះ?

រ៉ាស៊ីៈ អត់ទេ! ពូ ឌិន ណាស់ ។

វឿនៈ ឌិន ហ្នឹងគាត់នៅកុមារ គ្រាន់តែគាត់នៅការពារអ្នកទោស ។

រ៉ាស៊ីៈ ប៉ុន្តែគាត់ថាគាត់ជាអ្នកយាមអ្នកទោសធ្វើការ?

វឿនៈ ហ្នឹងហើយគ្រាន់តែយាមអ្នកទោសពេលធ្វើការទេ ឌិន ហ្នឹងនោះ ។

រ៉ាស៊ីៈ ហើយគាត់បាននិយាយទៀតថា មានក្រុមគ្នាគាត់មួយទៀតនោះ គឺយាមអ្នកទោសពេលសួរចម្លើយ ពេលអ្នកទោសជាប់ឃុំឃាំង តើអាហ្នឹងត្រូវទេ?

វឿនៈ ត្រូវ ។

រ៉ាស៊ីៈ មានអញ្ចឹងមែនពូអ្ហេះ?

វឿនៈ មាន! មានបែងចែកកម្លាំងពីរផ្នែក ។

រ៉ាស៊ីៈ អញ្ចឹងពីរផ្នែកដែលពូនិយាយមិញថា កងការពារអ្នកទោស និងជនចម្រើន បានន័យថាក្នុងមួយៗហ្នឹងត្រូវបែងចែកជាកងផ្សេងៗទៀត?

វឿនៈ បាទ! កងផ្សេងៗពីគ្នា ។ ១) កងការពារអ្នកទោសកុំឲ្យរត់ ដូចយើងធ្វើការពេលថ្ងៃយាម ។ មួយទៀតសួរចម្លើយអ្នកទោស ក្នុងកងការពារគេដែរ ។ គេបែងចែកកម្លាំងពីរអញ្ចឹង ។

រ៉ាស៊ីៈ ចុះជនចម្រើន?

វឿនៈ ជនចម្រើន គឺដៃស្តាំងរបស់គេហ្នុង អាហ្នឹងអ្នកវៃ អ្នកធ្វើទោសសួរចម្លើយហើយ ។ អាហ្នឹងនៅលើ ឌុច ជាអ្នកបញ្ជា ។ ដូចថារូបខ្ញុំ ឬរូបអ៊ំអញ្ចឹង បើថាឲ្យវៃសួរចម្លើយ បើថាសួរមិនចេញយកបាញ់ចោល គឺ ឌុច ហ្នឹងជាអ្នកបញ្ជាហើយ ។

រ៉ាស៊ីៈ អញ្ចឹងសរុបទាំងអស់ តើកងការពារ និងជនចម្រើនមានគ្នាប៉ុន្មាននាក់ដែរក្នុងមន្ទីរ១៣ហ្នឹង?

វឿនៈ កាលដែលខ្ញុំនៅហ្នុងមានគ្នា ១៥ នាក់ ប៉ុនខ្ញុំមិនស្គាល់ឈ្មោះអស់ទេបង ស្គាល់តែ ឡុញ ស្គាល់ តែ សឿន.......... ជុំ ខ្ញុំ សយ ណិន។ ណិន យើងមួយដែរនៅ........។ អាខនខនហ្នឹងគេអ្នកហ្នឹងហើយ ។

រ៉ាស៊ីៈ ខន ដែលថានៅស្ទឹងក្បាលចិនហ្នឹងអ្ហេះ?

វឿនៈ បាទ! ហ្នឹងហើយ ។ ខន គេខាងកុមារ ប៉ុនកុមារហ្នឹង កុមារអស់ទាស់ហើយ គ្រាន់តែតាវ៉ាក៏ដាក់ដែរអាហ្នឹងនោះ ។ ខ្ញុំដឹងប៉ុណ្ណឹងណា ។

រ៉ាស៊ីៈ បាទ!

វឿនៈ ប៉ុន្តែសកម្មភាពរបស់ ឌុច ដូចខ្ញុំរៀបរាប់អញ្ចឹងថា ។

រ៉ាស៊ីៈ ហើយពូស្គាល់ពូ អ៊ីន តាំងពីពេលណាដែរ?

វឿនៈ អ៊ីន ហ្នឹងកាលដែលខ្ញុំទៅហ្នឹង ឃើញនៅហ្នុងហ្នុង ។

ឃិនៈ អ៊ីន ជាប់មុនអញ្ចឹង?

វឿនៈ បាទ! អ៊ីន ជាប់មុនៗ ខ្ញុំថាអុញ អានេះពួកម៉ាកខ្ញុំតើ ប៉ុនខ្ញុំដឹងថា ចុះបើនៅក្នុងឃុំ ជាមួយគ្នា ប៉ុនខ្ញុំអត់ហ៊ានមាត់ទេ កាលណាខ្ញុំនិយាយទៅនាំឲ្យវាត្រូវអ្នកទោសទាំងអស់គ្នា ។ ប៉ុន អ៊ីន ហ្នឹង គេសម្រាលទោសហើយ ។ មុនដំបូងគេចង គេសួរចម្លើយដែរ ឌុច ហ្នឹង ដល់ហើយគេសម្រាល ទោស អ៊ីន ពួកម៉ាកខ្ញុំហ្នឹង ហើយ អ៊ីន នឹងខ្ញុំហ្នឹងកម្សត់កម្រពីរបីដងហើយ បិះងាប់ទៀត ។ ថ្ងៃមួយខ្ញុំបបួលវាទៅដេញឈ្លូស ចាំសួរវាមើល ។ ដេញឈ្លូសទៅចំអាកន្លែងដែលគេលាក់ការ វ៉ៃមនុស្សចោល ខ្ញុំមានដឹងឯណា ដល់ខ្ញុំមិនដែលចេញក្រៅ មិនដែលឃើញគេវ៉ៃមនុស្សចោល ទៅដល់ហៅ អ៊ីន ហ្នឹងមួយ និងប៉ុន្មាននាក់ដែលដាក់ទោសស្រាល ៥-៦នាក់ដែលគេសម្រាល ទោសដូច អ៊ីន ហ្នឹង ។ នាំគ្នាដើរៗ អាឌុច ថា ចុះអាណាទៅណា?! គេថា បងវឿនៗ មើល៍ ហៅអាវឿន ម៉ោនេះមើលម៉េចទៅកន្លែងហ្នឹង ទៅដល់ហ្នុង ទៅពិនិត្យមើលខ្មោចស្លាប់ក្នុងរណ្ដៅ ខ្ញុំអត់មានដឹងថាកន្លែងវ៉ៃមនុស្សចោល ។

ឃិនៈ ក្នុងវត្តមន្ទីរ១៣ ហ្នឹង?

វឿនៈ បាទ! ក្នុងមន្ទីរ១៣ ហ្នឹង ។ ខ្ញុំហើយអា អ៊ីន ភ្ញាក់ខ្លួនព្រឺត អីយ៉ាអាអ៊ីន តាឌុច វ៉ៃមនុស្ស ចោលច្រើនម៉េះអាក្នុងរណ្ដៅហ្នឹង ។

វ៉ាស៊ីៈ ម៉េចដឹងតា ឌុច វ៉ៃ?

វឿនៈ ចុះបើកន្លែងវាហ្នឹង មានពីណាម៉ោបង បើអ្នកទោសបញ្ជូនៗម៉ោ ស្រាប់តែឃើញនៅក្នុងរណ្ដៅ ណោះ ។ ឯខ្ញុំនេះក៏វាហៅម៉ោថាម៉េច វឿន ឯងម៉េចក៏នាំអ្នកទោសទៅអញ្ចឹង ។ ខ្ញុំថា ខ្ញុំអត់ ដឹងទេបង ខ្ញុំរត់ដេញឈ្លូស ។ ចាំសួរ អ៊ីន ពួកម៉ាកខ្ញុំហ្នឹងមើល៍ ។ ហ្នឹងរឿងម្ដង រឿងម្ដងទៀត ឃ្លានបាយពេក នាំអ្នកទោសម៉ោហូបបាយនេះនៅភូមិថ្នគុបនេះ ម៉ោរករឿងខ្ញុំអីណាណី តាឌុច ហ្នឹងប្រុងបាញ់ខ្ញុំចោលទៀតណោះ កុំបាន ប៉ុន និងផល ហ្នឹងនិយាយថា គួរអនុគ្រោះឲ្យខ្ញុំម្ដង ទៅ ។ គេថាខ្ញុំហ្នឹងម៉េច ដល់យប់ហ្នឹងសកម្មភាពម៉េច អ្ហែងហ្នឹងធ្វើយ៉ាងម៉េចបានដើរទាល់យប់ អញ្ចឹង? ប៉ុនខ្ញុំនាំពួកម៉ាកខ្ញុំ ខ្ញុំឃ្លានពេកនាំដាំបាយនៅថ្នគុបនេះ សុំបាយប្រជាជនឲ្យហូប ខ្ញុំ អស់ប៉ុណ្ណឹងហើយ ។ ឌុច ហ្នឹងរករឿងចង់បាញ់ខ្ញុំចោល សួរទៅសួរពួកម៉ាកខ្ញុំទៅ ។

ឃិនៈ បាន ផល ហើយហ្នឹង ប៉ុន ហ្នឹងអង្វរ?

វឿនៈ បាទ! ផល និង ប៉ុន ថាគួរអនុគ្រោះឲ្យគាត់ម្ដងទៅ បើធ្វើម៉េចទេ កុំរកបាញ់រកអីគាត់ចោល អញ្ចឹង ។ ឌុច ថាបាញ់ចោលអាហ្នឹងអត់កើតទេ នាំអ្នកទោសរត់ ។ អាកន្លែងដេញឈ្លូសនេះក៏ ធ្ងន់ណាស់ដែរ ។

វ៉ាស៊ីៈ ពួអាកងការពារហ្នឹងមានវិន័យម៉េចដែរ គេដាក់វិន័យម៉េចដែរ?

រឿនៈ វិន័យ! ដូចខ្ញុំថាវិន័យដូចអត់មានអីតឹងទេ បើថាកងការពារ អ្នកទោសចេញទៅធ្វើការ បើដូចថាឈ្មោះខ្ញុំអញ្ចឹង ៥ ៦នាក់ឲ្យយាម គឺយាមហើយ ។ អ្នកឯងឲ្យរួចគឺទទួលខុសត្រូវហើយ ដូចខ្ញុំអញ្ចឹង ខ្ញុំលែងពួកម៉ាកខ្ញុំបីនាក់អញ្ចឹងគ្រាន់តែលែងភ្លាម មោ៉ដោះខោដោះអាវខ្ញុំអស់អាលីងដកកាំភ្លើងនៅសល់តែខោខ្លីទេបង ។

រ៉ាស៊ីៈ ពូលែងពីណាគេខ្លះ? ឈ្មោះអីខ្លះដែរ?

រឿនៈ ឈ្មោះ រត្ន័ មួយ ។ រត្ន័ នៅសំរោងនេះ ។

រ៉ាស៊ីៈ សព្វថ្ងៃនៅរស់ទេ?

រឿនៈ អត់ដែលជួបផង តាំងពីលែងមោ៉មិនដឹងជាស្លាប់ ឬរស់បីនាក់ហ្នឹង ហើយពីរនាក់នោះភ្លេចឈ្មោះហើយ ប៉ុនលែងបីថ្ងៃហ្នឹង សុទ្ធតែគ្នាខ្ញុំ បើធ្លាប់ជួបមុខគ្នា ធ្លាប់ដើរលេងជិនាន់នោះ ។

រ៉ាស៊ីៈ ចុះមេ៉ចបានជាពូមានសិទ្ធទៅដោះលែងអ្នកទោសនៅហ្នុង?

រឿនៈ ខ្ញុំអាណិត ខ្ញុំសុខចិត្តខ្ញុំចូលគុក ។ បើសុទ្ធតែពួកម៉ាកទៅហើយ ទុកដូចជាបងប្អូនបង្កើតស្រឡាញ់គ្នាកាលពីជំនាន់អាពតមោ៉ ជួបមុខគ្នានោះដល់យកមកដាក់គុកអញ្ចឹងអត់កើតទេ ។ សុខចិត្តឲ្យជាប់គុកខ្ញុំចុះ កុំឲ្យ ។

រ៉ាស៊ីៈ ហ្នឹងនៅក្នុងឆ្នាំណាដែរ?

រឿនៈ ៧៣ ហ្នឹង ។

រ៉ាស៊ីៈ ខែណាមានចាំទេ?

រឿនៈ អត់ចាំខែទេបង ។

រ៉ាស៊ីៈ ពេលដែលពូដោះលែងអ្នកទាំងបីហ្នឹង ឌុច នៅឯណាដែរ?

រឿនៈ ឌុប នៅក្នុងមន្ទីរ ។

រ៉ាស៊ីៈ ប៉ុន្តែអត់ដឹងទេ?

រឿនៈ អត់ដឹងទេ បើថាឲ្យខ្ញុំយកអ្នកទោសបីនាក់ហ្នឹងយកទៅយាមលើកទំនប់ ឲ្យខ្ញុំអង្គុយយាមហ្នឹងដល់ខ្ញុំថា វាថាអាពួកម៉ាក អាមួយថាពួកម៉ាក អាមួយថាបង ។ វាថាឲ្យខ្ញុំរត់ទៅបងអុីយមើលទៅអត់កើតទេ ។ ខ្ញុំថាតោះរត់ៗទៅ អែ្ហងនឹងអញវាអស់សាច់ឈាមគ្នា តោះអញសុខចិត្តចូលគុក ។ ខ្ញុំថាអញ្ចឹង ប៉ុនអែ្ហងរត់ អញអត់ទាន់បាញ់អែ្ហងទេ អែ្ហងរត់ឲ្យផុតសិនទៅ ។ អានោះរត់ផុតបាត់ស្រមោ៉លវាទៅក្នុងព្រៃតែហ្នង ។ អង្គុយៗទៅគ្រាន់តែបាត់ស្រមោ៉លវា ខ្ញុំបាញ់ឡើងលើ៥គ្រាប់ ប៉ុងៗៗ គ្នាវាផ្អើលឈូលមោ៉ថា អ្ហកអ្នកទោសរួចហើយ ។ គ្រាន់តែពួបាញ់ដឹងថាអ្នកទោសរួចហើយ ។ ឌុប មោ៉សួរខ្ញុំ ខ្ញុំថាបងអុីយអ្នកទោសរួចហើយ ធ្វើមេ៉ចខ្ញុំលក់មោ៉ភាំង ប៉ុនអត់ទេ ។ ខបាយកលខ្ញុំថាធ្វើមេ៉ចឲ្យពួកម៉ាករត់បានរួចចោះ ។

ឃិនៈ ប៉ុនអ្នកទោសមានដាក់ច្រវ៉ាក់ទេ?

វឿនៈ អាម្នាក់ទៀតខ្ញុំអត់ស្គាល់ទេ ។ ប៉ុនបីនាក់ ពួកម៉ាកខ្ញុំតែពីរនាក់ទេ រត្ន័ នោះមួយ ហើយមួយទៀតខ្ញុំភ្លេចបាត់ហើយ ។ ម្នាក់នោះធ្វើម៉េចដោះពីរមិនកើត ដោះបីតែម្ដងទៅ ឲ្យទៅទាំងអស់ទៅ ។

ឃិនៈ អ្នកទោសនោះមានដាក់ច្រវ៉ាក់ដែរ?

វឿនៈ ដាក់ ។ ប៉ុនពូចៅគ្រប់ដៃទាំងអស់ ។ ទៅដល់ខ្ញុំផ្ដែកកាំភ្លើងអញ្ចឹងជួយដាប់វាហ្មង ។ ដាប់ផ្ទាប់ឈើអត់ដាច់ ទាល់តែដាក់ផ្ទាប់ថ្មបានដាច់ ។ ពូចៅដាក់ប៉ិច ដាក់លើថ្ម ។ ខ្ញុំថាអាពួកម៉ាកអ្អែងធ្វើម៉េចឲ្យតែរួចទៅ អញ ចាំអញបាញ់តាមក្រោយឲ្យដើរអ្អែងចាំមើល រត់រួចឲ្យឆ្ងាយសិនទៅ ។

ភ៉ាស៊ីៈ ដល់ពេល ឌុច ដឹង ឌុច ព្រមានពូថាម៉េចខ្លះទៅ?

វឿនៈ ព្រមានដូចខ្ញុំថាអញ្ចឹង គាត់ថាអ្នកទោសរួចខាងណា ខ្ញុំថារួចខាងបង វឿន អាពួកនៅខាងក្នុងណាស់ ខ្ញុំថារួចខាងខ្ញុំហើយ ។ ឥឡូវអ្អែងទៅដកកាំភ្លើងអា វឿន ចេញ ហើយដោះខោដោះអាវវាឲ្យអស់ ហើយហៅវាមៅចូលគុក ។ បងអ៊ើយ! ទៅដល់ចូលគុកភ្លក គុកបុស្សីយើង អាគុកកន្លែងបួនជ្រុងយើងនោះ ទៅដល់ខ្សែករខ្ញុំវ៉ាប់ តែអត់ទាន់វៃទេ ។ ទោសខ្ញុំមិនដល់ថ្នាក់វៃទេ គ្រាន់តែលួចអញ្ចឹងគេចាក់សោរខ្ញុំចង់ភ្ជាប់បុស្សីអញ្ចឹង នៅហ្នឹង ។ បានម៉ាអាទិត្យ វាបណ្ដើរខ្ញុំចេញទៅធ្វើការខ្លួនវា អាការម៉ាដើមចាក់សោរខ្ញុំវ៉ាប់បណ្ដើរកាប់ដី ចងភ្ជាប់ដើមឈើអញ្ចឹង វាបន្ទាយខ្សែរឲ្យវែងអញ្ចឹងទៅឲ្យកាប់ដី ។

ឃិនៈ ចេះតែកាប់ដីទៅ?

វឿនៈ បាទ! ចេះតែកាប់ដីទៅ ឈប់អត់បានទេ ។ ឈប់វាស្រែក ម៉េច! ។

ឃិនៈ កាប់ធ្វើអីដីហ្នឹង?

វឿនៈ វាចេះតែឲ្យកាប់ទៅ

ភ៉ាស៊ីៈ ហើយច្រវ៉ាក់ហ្នឹងឃ្លាតពីដើមឈើប៉ុន្មាន ចម្ងាយណាច្រវ៉ាក់?

វឿនៈ ខ្សែអង្រឹងទេ មិនមែនច្រវ៉ាក់ទេ ។ ខ្សែអង្រឹងទាក់ករ ។ ទោះជារត់ក៏រត់អត់រួចទេ បាញ់សាប់ឥឡូវ បើវានៅយោលអង្រឹងអញ្ចឹង វាបែរកាណុងចំខ្ញុំអញ្ចឹង ។

ភ៉ាស៊ីៈ ហ្នឹងពូស្គាល់ឈ្មោះទេ?

វឿនៈ ពីណា?

ភ៉ាស៊ីៈ អ្នកយោលអង្រឹងយាមពូហ្នឹង?

វឿនៈ ឌុច មេគេតែហ្មងហ្នឹង ។ វាយាមផ្ទាល់ខ្លួនវា ។ វាចងអង្រឹងជាប់ដើមកណ្ដាលទៀត ខ្ញុំស្គាល់ច្បាស់ណាស់ ។ អត់ឆាកទេ នៅចាំមើលហ្មង ។ បើសិនជាវាយាមខុសបន្តិចក៏ខ្ញុំអាចកាត់ខ្សែរត់ដែរពេលហ្នឹងនោះ ប៉ុនវាផ្ទាល់ហើយកាំភ្លើងម៉ាដើម ។

ឃិនៈ ឥឡូវអញ្ចេះណាស់ ខ្ញុំសុំសួរបន្តិច មន្ទីរសួរចម្លើយដែលមាននៅក្នុងហ្នឹងទាំងអស់មានប៉ុន្មាន?

វឿនៈ កន្លែងសួរចម្លើយមានម៉ាកន្លែង ប៉ុនវាគ្រាន់បែងចែករបស់វាបីកន្លែងៈ ១) ឌុច ។ ២) ចាន់ យើងថា ចាន់ខ្ជន់នោះណា៎ អាហ្នឹងមួយក៏ដូច ឌុច ដែលវាស្មើគ្នាអត់មានអាណាខ្សែម៉ាខាងទេ អាហ្នឹងមេចំហើយ ហើយម៉ៅមាន ប៉ុន ដែលថាវ៉ៃចោលហ្នឹង ។ ប៉ុន ម៉ៅបាន ផល ។ មានតែបួនហ្នឹងទេ ។

យិនៈ មិនមែន៧ ៨កន្លែងទេណោះ?

វឿនៈ ប៉ុនកន្លែងសួរចម្លើយមានតែ ផល និងនេះហ្នឹងអត់អីទេ ។ ប៉ុន្តែ ឌុច ហើយនឹង ចាន់ អត់បានទេ វ៉ៃហើរជើង ចងសុទ្ធតែព្យួរជើង ។ នេះខ្ញុំឃើញដាក់ស្ដែងហ្នុង ។

យិនៈ គុកដែលដាក់អ្នកទោស ដែលបងសរុបទៅមើលឃើញប៉ុន្មាន គុកក្នុងដី?

វឿនៈ គុកក្នុងដីមាន៤

រ៉ាស៊ីៈ ហើយក្នុងម៉ាកន្លែងប៉ុន្មាននាក់?

វឿនៈ នៅជិតៗគ្នាអញ្ចឹង ហែរគ្នាអញ្ចឹងហ្នុង ពីម៉ាកន្លែងៗអញ្ចឹងហ្នុង ហើយអារណ្ដៅមួយធំ អាហ្នឹងសម្រាប់អ្នកទោសដែលយកពីឆ្ងាយៗម៉ៅ ឬមួយយកពីណាពីណីម៉ៅច្រើន វាយកទៅដាក់អារណ្ដៅធំ ។ នៅពេលសួរចម្លើយហើយបានយកមកដាក់អាតូចៗនេះ ។

យិនៈ រណ្ដៅធំហ្នឹងវានៅក្នុងដីជម្រៅប៉ុន្មាន?

វឿនៈ ជម្រៅប្រហែលជា ៣-៤ម៉ែត្រ ។

យិនៈ ដាក់ពេញទៅ?

វឿនៈ អត់ពេញទេបង ។ ដាក់តាមចំនួនបានប៉ុន្មានដាក់ប៉ុណ្ណឹង ។

យិនៈ ហើយសួរចម្លើយនៅត្រង់ណា?

វឿនៈ ចេញពីរណ្ដៅម៉ៅ យកមកសួរចម្លើយឯក្រៅណោះ ។

យិនៈ អញ្ចឹងអាដាក់ចូលហ្នឹងជណ្ដើរ ឬក៏យោង?

វឿនៈ ជីកដីធ្វើជណ្ដើរដែរ ។ ដល់ពេលខ្លះទៅបានគេដាក់ជណ្ដើរអាស៊ីចុះ ។

យិនៈ ចុះបងពេលដែលទឹកឡើងជិនទន់ហើយ ទៅលិចអ្នកទោសងាប់អស់ហ្នឹង មានឃើញផ្ទាល់ភ្នែកឆ្នាំណាទេ?

វឿនៈ ឃើញ ប៉ុនអត់បានចាំឆ្នាំ ប៉ុនងាប់អ្នកទោសអស់ច្រើនណាស់ ។ វាទឹកជន់ម៉ៅ យប់អត់ដឹងម៉ៅភឹបៗអញ្ចឹង កងការពារ ខ្ញុំក៏នៅនោះដែរ ។

យិនៈ មានអ្នកទោសរួចខ្លះទេ?

វឿនៈ អ្នកទោសរួចខ្លះ ងាប់ច្រើន ។ ងាប់វាជាប់នៅដោះមិនបាន ។ ឯអ្នកកងការពារនោះ អាខ្លះឡើងចុងឈើ ។ ហ្នឹងអ្នកទោសស្លាប់ថ្ងៃហ្នុងក៏ច្រើនដែរ ។

យិនៈ អាកងការពារម៉េចក៏វាឡើងចុងឈើវាខ្លាចលិចទឹកងាប់?

វឿនៈ ខ្លាចសាប់ ព្រោះអាអ្នកទោសវាជាប់ខ្នោះម៉េចទៅហ៊ានដោះ ។ ដោះខ្លាចគេថាអី ។

ឃិនៈ អូរបើគ្មានបញ្ហាអត់ហ៊ានដោះទេ?

វឿនៈ បាទ! តែដល់ទឹកលិចហើយ ចេះតែឡើងយកតែរួចខ្លួនទៅ ។

ភ៉ាស៊ីៈ ហើយចុះពេលហ្នឹង ឌុច នៅឯណាដែរទៅ?

វឿនៈ ឌុច នៅហ្នុងដែរ ។ ឌុច ក៏ឡើងចុងឈើដែរ ។

ឃិនៈ បើអញ្ចឹងលិចទាំងកន្លែង ឌុច អីទាំងអស់?

វឿនៈ ចុះបើជាប់គ្នាអញ្ចេះ ។ ជាប់ទាំងអស់ កន្លែងអ្នកទោសអញ្ចឹង កន្លែង ឌុច នៅហ្នឹងទៅហើយ អត់មានទៅណា ។ វានៅជាមួយអ្នកទោស ។

ភ៉ាស៊ីៈ ពូអាចគូរដាក់ក្រដាស់បន្តិចបានទេពូ ខ្ញុំចង់ឲ្យពូគូរ ឧទាហរណ៍ថាកន្លែងមន្ទីរធំវានៅត្រង់ណា ហើយអាមន្ទីរ ឌុច ត្រង់ណា ហើយមន្ទីរ ចាន់ ត្រង់ណា?

វឿនៈ អត់ទេ! ជាប់គ្នាហ្នឹង ។

( វឿន បានគូរបញ្ជាក់ពីទីតាំងមន្ទីរ-១៣ដាក់ក្រដាស)

ឃិនៈ អានេះផ្លូវចូលពីអាយអ្ហេះ?

វឿនៈ ក្នុងរបងគុកអញ្ចឹងដែរ........ កន្លែងវាអត់មានផ្ទះអីទេ ចង់អង្រឹងដេកអីទេ ។

ឃិនៈ ចុះបើមានភ្ញៀវម៉ៅ តើ ឌុច ហ្នឹងទៅណា?

វឿនៈ ឌុច វាមានផ្ទះវានៅក្នុងដី ។

ឃិនៈ ឌុច វាមានផ្ទះនៅក្នុងដី!

វឿនៈ បាទ! ផ្ទះនៅក្នុងដី អាមួយចូលទៅក្នុងមាត់ស្ទឹងអញ្ចេះនេះ ។ ដីវាដីអស់ទាស់ហើយវាចាក់ បាន អីភ្ញៀវចូលរួច ។ វាធ្វើអញ្ចឹងទៅឆ្ងាយមាត់ស្ទឹងណោះ ។ ហ្នុងផ្ទះវាហើយក្នុងដីហ្នុង ។

ភ៉ាស៊ីៈ អញ្ចឹងពូអានេះ មន្ទីរ ឌុច?

វឿនៈ បាទ!

ភ៉ាស៊ីៈ អាហ្នឹងនៅខាងកើត លិច ត្បូង?

វឿនៈ នៅខាងលិច ។ មាត់ស្ទឹង ។

ភ៉ាស៊ីៈ អានេះជើង ខាងណោះ អានេះត្បូង ។ ចុះអាបន្ទាប់ពីនេះម៉ៅនេះ?

វឿនៈ អាហ្នឹងអ្នកទោស ។ រណ្ដៅជាប់គ្នារហូត ។

ភ៉ាស៊ីៈ ចុះមន្ទីររបស់ ចាន់ នោះ?

វឿនៈ ជាមួយគ្នាហ្នឹង បើគេចង់សួរអ្នកទោស មានបញ្ហាពី ឌុច ហ្នឹងឲ្យយកពីរណ្ដៅណាក៏បានដែរ ឈ្មោះណាក៏បានដែរ ។

ភ៉ាស៊ីៈ យកទៅសួរចម្លើយនៅត្រង់ណា?

រឿន៖ សួរចម្លើយ គ្រាន់តែយកពីរណ្តៅមៅសួរ នៅលើគោក ៗ អត់មានកន្លែងទេ ៗ

ពាំស៊ី៖ អានេះជារណ្តៅហើយណោះបង?

រឿន៖ បាទ! ហ្នឹងហើយ ៗ

ពាំស៊ី៖ អញ្ចឹងអាកន្លែងនេះជាកន្លែងសួរចម្លើយ?

រឿន៖ បាទ! កន្លែងសួរចម្លើយ ៗ ឧទាហរណ៍ថាចង់សួរឈ្មោះនោះមួយ ឲ្យកងការពារហ្នឹងចាក់សោរ យកមៅ ឲ្យវាសួរទៅ ៗ

ពាំស៊ី៖ អញ្ចឹងកន្លែងសួរចម្លើយនៅខាងត្បូងអ្ហេះ?

រឿន៖ បាទ! នៅកៀនជាំបូកខាងត្បូង ៗ

ពាំស៊ី៖ ហើយចុះត្រពាំងប្រាបនោះនៅត្រង់ណាដែរ?

រឿន៖ ត្រពាំងប្រាប់នៅខាងជើងណោះទេ រួចមន្ទីរវ៉ានៅមាត់ស្ទឹងណោះទេ ៗ

យិន៖ រួចពុថាខាងមាត់ស្ទឹងខាងជើងម៉ាជួរនេះក៏មានដែរ ហើយមាត់ស្ទឹងខាងត្បូងក៏មានដែរ?

រឿន៖ អត់ទេ! មានតែម៉ាកន្លែងទេ ៗ

យិន៖ នៅខាងត្បូងមាត់ស្ទឹងអ្ហាស់?

រឿន៖ បាទ!

យិន៖ ចុះអាកន្លែងវ៉ៃចោលនៅត្រង់ណា អណ្តូងជ្រៅៗ?

រឿន៖ អាកន្លែងខ្ញុំប្រាប់បងឯង អាកន្លែងខ្ញុំដេញឈូសជួបហ្នឹង ខាងត្បូងស្ទឹងណោះ ៗ សួរពួកម៉ាកខ្ញុំទៅដឹងហើយ មៅដេញឈូស ៗ មៅដល់ហ្នឹងបាញ់ចាប........ប៉ិននៅក្នុងមន្ទីរហ្នឹងតែមួយទេ អត់មានបែងចែកអីទេ ឌុច ក៏ហ្នឹង ចាន់ ក៏ហ្នឹង ប៉ុន ក៏ហ្នឹង ហើយអីមួយទៀតនោះ ផល ក៏ហ្នឹងដែរ ៗ

យិន៖ ចុះថា មាសៗ ដៃដល់ណាស់នោ?

រឿន៖ មាស ហ្នឹងហើយដៃ របស់គេជាមួយ ឌុច ៗ ប៉ិន មាស ហ្នឹងស្លាប់បាត់ហើយ ៗ

យិន៖ មាស ផល ប៉ុន!

រឿន៖ ផល ប៉ុន ហ្នឹងអត់អីទេ ខ្ញុំចាត់ទុកថាល្អហ្មង ៗ

យិន៖ អញ្ចឹងបានដល់ក្រោយម៉ោ ឌុច ត្រូវវ៉ៃពីរនាក់ហ្នឹងចោល!

រឿន៖ បាទ! ល្អណាស់ អ្នកទោសមិនដែលត្រូវម៉ាំរំពាត់ទេ គ្រាន់តែសួរតែមាត់ៗទេ មិនដែលដៃជើងដល់ទេ ៗ

ពាំស៊ី៖ គេសួរថាម៉េចខ្លះទៅ?

រឿន៖ គេសួរតាមរឿងរ៉ាវគេ ៗ

យិន៖ យ៉ាងម៉េចក៏មិនវ៉ៃដែរណោះ?

រឿនៈ អត់វ៉ៃទេ ។ ប៉ុន និង ផល អត់ដាច់ខាតមិនដែលវ៉ៃ ទៅសួរកន្លែងណាក៏អត់ឃើញវ៉ៃដែរ តែ បើគា ឌុច សួរហ្នុងដឹងហើយបង ។

ឃិនៈ ចុះពីរនាក់ហ្នឹងមានដឹងថាកំហុសអីបានជាគេយកគាត់ទៅវ៉ៃចោល?

រឿនៈ ខ្ញុំអត់ដឹងដែរ ស្រាប់តែយកគ្នាទៅវ៉ៃចោលបាត់ទៅ ។

ភាសុីៈ នៅឆ្នាំណាដែរវ៉ៃហ្នឹង?

រឿនៈ នៅឆ្នាំ ៧៣ ។

ឃិនៈ ឥឡូវខ្ញុំសុំសួរចំណុចចុងក្រោយមួយ ចំនួនរណ្ដាំពូបាននិយាយហើយ កន្លែងសម្លាប់អី ខ្ញុំចង់ សួរប្រភេទអ្នកទោសដែលគេយកមកដាក់ហ្នឹង តើមើលពូសង្កេតឃើញមានអ្នកទោសច្រើនជា របៀបទាហាន កម្មាភិបាលខ្មែរក្រហម ឬក៏ស្អីណាខ្លះដែលពូដឹងពូស្គាល់ មើល៍សូមរៀបរាប់ត្រង់ បន្តិចមើល?

រឿនៈ ខ្ញុំវាមិនសូវបាននៅហ្នឹងជាប់ផង កាលនោះខ្ញុំមៅ៉ មៅ៉ទៅជួនកាលឃើញច្រើន ជួនកាលឃើញ តិច ។

ឃិនៈ អ្នកហ្នឹងស្លៀកពាក់របៀបម៉េច មានស្រី មានប្រុសអីដែរទេ?

រឿនៈ មានតាំងពីកូនក្មេងដែរ ។

ឃិនៈ ស្លៀកពាក់ មានស្លៀកខ្មៅដែរអី?

រឿនៈ មានស្លៀកពាក់អាវទាហាន ។

ឃិនៈ ឆ្នាំណា?

រឿនៈ ៧៣ហ្នឹង ។

ឃិនៈ អូរមុនបែកហើយអាហ្នឹង ជាទាហាន ដែលជាឈ្លើយសឹកហើយអាហ្នឹង?

រឿនៈ បាទ! ដឹងអី ។

ឃិនៈ ទាហានលន់ ណុលហ្នឹង?

រឿនៈ បាទ! ជួនកាលជាប្រជាជនយើងហ្នឹងដែរ ។

ឃិនៈ ប្រជាជនយើងជនបទ មូលដ្ឋានហ្នឹង?

រឿនៈ បាទ! មូលដ្ឋាននេះនៅម្ដុំនេះ ដូចខ្ញុំថាដែលគេយកអីៗទៅឲ្យបងប្អូនគេហ្នុង ។

ឃិនៈ អូរ! យល់ហើយ ។ ដូចក្មួយអីនគរបាលថាឪពុកគាត់ធ្វើស្មៀនអីហ្នឹង ស្មៀនសាលាស្រុក ។

រឿនៈ ហើយ រត្ន័ ហ្នឹងក៏យកទៅដែរ ។ ប៉ុនគ្រាន់តែខ្ញុំអត់បានមៅ៉ទេ យកបងទៅហ្នឹង ។

ភាសុីៈ នៅក្នុងរយៈពេលដែលពូចូលទៅធ្វើការនៅហ្នឹង ហើយក្រោយមៅ៉ពូបានជាប់គុកនៅហ្នឹង តើពូ មានដឹងថា ឌុច បានសម្លាប់មនុស្សប៉ុន្មាននាក់ ឬក៏ធ្វើទារុណកម្មមនុស្សប៉ុន្មាននាក់?

រឿនៈ ខ្ញុំអត់បានដឹងតែហ្នុង កាលហ្នឹងខ្ញុំដឹងតែប៉ុណ្ណឹង ។

ភាស៊ី៖ បាទ! អានេះខ្ញុំចង់រយៈពេលដែលពូធ្វើការនៅហ្នឹង នៅក្នុងអំឡុងឆ្នាំ ៧៣ ហ្នឹងអ្នកស្អាស់ តើពូបាន ឃើញ ឌុច ធ្វើទារុណកម្មដោយផ្ទាល់ភ្នែកពូប៉ុន្មានដង ហើយធ្លាប់ឃើញសម្លាប់ប៉ុន្មានដងដែរ?

រឿន៖ អារឿងធ្វើទារុណកម្មនោះវា រាល់តែថ្ងៃរាល់យប់ ។

យិន៖ សឹងតែគ្រប់គ្នាសោះហើយ ។

រឿន៖ បាទ! ហើយអ្នកទោសទាំងប៉ុន្មានដាក់ទាំងអស់ ។ រឿងសម្លាប់ខ្ញុំឃើញតែម្នាក់ទេដែលបាញ់ម្នាក់ ដែលចងបង្គោលនោះ ខ្ញុំឃើញផ្ទាល់ភ្នែក ។ អារឿងដែលគេយកទោសសម្លាប់គេមិនឲ្យពួកខ្ញុំដឹងទេ ទាល់បក្ខជនគេដែលធ្លាប់ធ្វើការជាប់នឹងគេនោះ ។

យិន៖ អ្នកដែលគេហៅជនចម្រើនគេនោះ?

រឿន៖ ហ្នឹងហើយ ជនចម្រើនគេនោះ អាហ្នឹងបានដឹង ។ ម៉ាត្រឹមកងការពារពួកខ្ញុំនេះ គេអត់ឲ្យដឹងទេ ខ្លាចបែកការណ៍កន្លែងគេ ។

យិន៖ ពូអញ្ចេះ! ខ្ញុំចង់ឲ្យពូប្រាប់ឈ្មោះដែលថានៅក្នុងជនចម្រើននោះមានស្គាល់ឈ្មោះអីខ្លះ?

រឿន៖ ក្នុងជនចម្រើនហ្នឹងមានឈ្មោះ សឿង នោះមួយ ។

យិន៖ នៅរស់ទេ?

រឿន៖ នៅរស់ទេ ។

យិន៖ នៅឯណា?

រឿន៖ នៅភូមិគោក នេះ ។ សឿន ហើយនឹង ចេវ ។

យិន៖ ចេវ ហ្នឹងនៅឯណាដែរ?

រឿន៖ ចេវ ហ្នឹងស្លាប់បាត់ហើយ ។

យិន៖ ចុះ ណិន?

រឿន៖ ហ្នឹងហើយ ណិន ហ្នឹងមួយនៅទំនាប (ភូមិទំនាប) ។

យិន៖ ប៉ុន្តែជនចម្រើនដែរណោះ?

រឿន៖ ជនចម្រើនដែរ ។

ភាស៊ី៖ មានឈ្មោះអីទៀតពូ?

រឿន៖ ខន យើងអាខនក្រញាញ់នេះ

## ផ្នែក «១»

យិន៖ ៨ឆ្នាំ ១០ឆ្នាំ ១២ឆ្នាំ វៃដែរ?

រឿន៖ ហ្នឹងហើយ ។

យិន៖ ថា តាឌុច ហ្នឹងច្រើនប្រើក្មេងឲ្យវៃ មែនទេ មានឃើញផ្ទាល់ភ្នែកដែរ?

វឿនៈ អត់ដែលឃើញដែរ ។

ឃិនៈ ច្រើនប្រើក្មេងហ្នឹងឲ្យវ៉ៃ ប៉ុនអាក្មេងហ្នុងវ៉ៃមិនស្លាប់ទេ! វ៉ៃអនអញ្ចឹងទៅ បានមានឈ្មោះនេះ អាណិន, ស៊ីន, ខន បន្ថែម ។ មានអញ្ចឹងដែរទេ?

វឿនៈ ហ្នឹងហើយ មាន ។ ត្រឹមកងការពារខ្ញុំនេះមិនដឹងរឿងអីទេ..................ខ្ញុំឃើញប៉ុណ្ណឹង ។

ភ័ស៊ីៈ ចុះនៅក្នុងឆ្នាំ១៩៧៣ហ្នឹង ពូបានដឹងថាមានជនចំរើនហ្នឹងមានប្អូនទាក់ហ្នឹងអ្ហែះ?

វឿនៈ បាទ!

ភ័ស៊ីៈ ចុះកងការពារ តើមនុស្សដែលស្ថិតក្នុងកងការពារ....

វឿនៈ ខ្ញុំស្គាល់គេអត់អស់ទេ ស្គាល់តែប៉ុន្មាននាក់ទេ ។

ភ័ស៊ីៈ បាទ! ហើយមនុស្សដែលនៅក្នុងជនចំរើនហ្នឹងមានវ័យខុសគ្នាដែរអ្ហែះ?

វឿនៈ បាទ! មានចាស់ មានក្មេង ។

ភ័ស៊ីៈ ចុះនៅក្នុងកងការពារនេះ?

វឿនៈ កងការពារគេដាក់សុទ្ធតែកុមារទេ ។

ភ័ស៊ីៈ ជនចំរើននេះបាន..

វឿនៈ ជនចំរើននេះបានមានលាយចាស់ លាយក្មេងដែរ ។

ភ័ស៊ីៈ ចុះអ្នកដែលនៅក្រោមបង្គាប់តា ឌុច ដូចជា ប៉ុន ផល ចាន់ អាហ្នឹងគេហៅជនអីវិញ?

វឿនៈ ហ្នឹងគេហៅម៉េចទេ ដូចថាដៃស្តាំរបស់គេទៅណា ។ អត់ពី ឌុច ទៅគេមៅជំនួស ឌុច ។ អត់អី ឌុច ទៅមាន ចាន់ ។ អត់ពី ចាន់ ទៅមាន មាស ហ្នឹងហើយ ។

ភ័ស៊ីៈ មាន ប៉ុន មានអីដែរ?

វឿនៈ ប៉ុន ផល អីហ្នឹង ។ ផល គេសម្លាប់ចោល ។

ភ័ស៊ីៈ មូលហេតុអីបានជាគេសម្លាប់ចោល?

វឿនៈ មូលហេតុដែលមៅពីធ្វើការ ខ្វាចបែកការណ៍បានសម្លាប់ចោលទៅ ។ ផល ហើយនឹង ប៉ុន ហ្នឹង ស្លូតណាស់ ។

ឃិនៈ ហើយពួកហ្នឹងមិនមែនអ្នកដៃដល់សម្លាប់មនុស្សទេ?

វឿនៈ អត់ទេ គេគ្រាន់តែឲ្យសួរចម្លើយទេ អត់ហ៊ានវ៉ៃ អត់ហ៊ានមាត់ធំផង ។ វាបញ្ជាឲ្យអាបក្ខជនរបស់វាយកទៅសម្លាប់ គឺយកទៅហើយ ។

ឃិនៈ បើអញ្ចឹង ខ្ញុំថា ផល ហ្នឹងបែបជាមនុស្សដែលមានមនោសញ្ចេតនា មិនកាច ។

វឿនៈ បាទ! ផល ហើយនឹង ប៉ុន ហ្នឹងអត់ដែលឃើញសម្លាប់បងប្អូនណាទេ គ្រាន់តែសួរចម្លើយមិនដែលឃើញវ៉ៃទេ ។ និយាយនំៗហើយ ។ បើថា ឌុច និង ចាន់ អត់បានទេបង ដូចគ្នា ។

ភ័ស៊ីៈ បាទ!

វឿនៈ ចាន់ និង ឌុច គឺជាប៉ុនគ្នា ។

រ៉ាស៊ីៈ តើពូយល់ថាម៉េចដែរចំពោះការគ្រប់គ្រងរបស់ ឌុច នៅមន្ទីរ១៣ ហ្នឹង ហើយមានការសម្លាប់មនុស្សអស់រាប់សិបនាក់អញ្ចឹង តើលោកពូយល់ថាការគ្រប់គ្រងរបស់ ឌុច ហ្នឹង ជាការគ្រប់គ្រងបែបយ៉ាងម៉េច?

វឿនៈ ដល់ខ្ញុំឃើញគាត់ធ្វើអញ្ចឹងណា ខ្ញុំអត់ចង់ហ៊ានមើលទៀតទេ ឃើញគាត់ឃោរឃៅអញ្ចឹពេក ។

រ៉ាស៊ីៈ អញ្ចឹងពូយល់ថា តាឌុច ហ្នឹងជាមនុស្សឃោរឃៅ?

វឿនៈ បាទ!

រ៉ាស៊ីៈ មានចំណុចត្រង់ណាខ្លះដែលបញ្ជាក់ថាគាត់ជាមនុស្សឃោរឃៅ?

វឿនៈ ឃោរឃៅត្រង់ថាវ៉ៃមនុស្ស ហើយសួរចម្លើយ វ៉ៃដុតគ្នាហើយសម្លាប់អញ្ចឹងមិនថាឃោរឃៅម៉េច! វាឃើញជាក់ស្តែងនឹងភ្នែក ។

ឃិនៈ ហើយពូឃើញរាល់ថ្ងៃអញ្ចឹងហ្នង?

វឿនៈ រាល់ថ្ងៃហ្នឹង ។ ប្រចាំថ្ងៃជាប់ ។

រ៉ាស៊ីៈ អញ្ចឹងមនុស្សដែលបានមៅជាប់នៅក្នុងមន្ទីរ១៣ ហ្នឹងខ្ញុំយល់ថាមិនមែនជា ឌុច ជាអ្នកសម្លាប់ទាំងអស់ទេមែនទេ?

វឿនៈ មិនមែនទាំងអស់ទេ ប៉ុនគ្រាន់មានបញ្ជាពីគាត់ ។ បើអត់បញ្ជាមិនមែនមានមនុស្សងាប់ទេ ។

រ៉ាស៊ីៈ អញ្ចឹងបានន័យថាអ្នកដែលនៅក្រោមបង្គាប់របស់ តាឌុច ហ្នឹងពិតជាបានទទួលបញ្ជាពីតា ឌុច ហ្នឹង?

វឿនៈ បាទ! គាត់មិនបានសម្លាប់ដោយផ្ទាល់ដៃ ប៉ុនគាត់បញ្ជាកូនទាហានដៃស្តាំរបស់គាត់ហ្នឹង ។

រ៉ាស៊ីៈ អញ្ចឹងពូយល់ថា បើសិនជាការមានការរកខុស រកត្រូវ រកភាពយុត្តិធម៌ តើទោសកំហុសទាំងអស់ហ្នឹងត្រូវធ្លាក់ទៅលើអ្នកណា នៅក្នុងមន្ទីរ១៣ហ្នឹង?

វឿនៈ ធ្លាក់លើតា ឌុច ព្រោះមន្ទីរនេះជាមន្ទីររបស់ តាឌុច ។ មនុស្សបើថាចង់ឲ្យស្លាប់ៗដោយសារតាឌុច ចង់ឲ្យរស់ៗក៏ដោយសារ តាឌុច ដែរ គឺនៅលើ តាឌុច ទាំងអស់ ។

រ៉ាស៊ីៈ បាទ! អញ្ចឹងពូចង់ឲ្យមានតុលាការកាត់ទោសគាត់ទេ?

វឿនៈ ចង់ ។

រ៉ាស៊ីៈ ដោយសារមូលហេតុប៉ុន្មានយ៉ាងរបស់ពូបានចង់ឲ្យមានតុលាការ?

វឿនៈ ចង់ឲ្យមានព្រោះគាត់សម្លាប់គេច្រើនពេក ។ ចង់ឲ្យតុលាការកាត់ទោសគាត់ ព្រោះដោយសារតែគាត់ហ្នឹង មិនមែនអស់មនុស្សតិចទេ ។

ព៉ស៊ីៈ បើសិនជាមានតុលាការមែន តើពូចង់ឲ្យតុលាការកាត់ទោសគាត់តាមរបៀប ឬកំលក្ខណៈយ៉ាងម៉េច? ចង់ឲ្យគាត់ទទួលទោសយ៉ាងម៉េចពីតុលាការ ដើម្បីឲ្យសមនឹងភាពយុត្តិធម៌ សមនឹងភាពការចង់បានយុត្តិធម៌របស់ប្រជាជន?

វឿនៈ ខ្ញុំចង់ឲ្យតុលាការកាត់ទោសគាត់តាមផ្លូវច្បាប់ ។

ព៉ស៊ីៈ បាទ! តាមផ្លូវច្បាប់ ប៉ុន្តែនៅក្នុងចិត្តរបស់ពូ នៅក្នុងអារម្មណ៍របស់ពូ ដែលពូយល់ថា ឌុច ហ្នឹងជាមនុស្សឃោរឃៅ ជាមនុស្សសាហាវ តើពូចង់ដាក់ទោសគាត់យ៉ាងម៉េច?

វឿនៈ ចង់ឲ្យគាត់ជាប់គុកមួយជីវិតគាត់តែម្តង ព្រោះគាត់ហ្នឹងធ្វើបាបគេណាស់ មិនត្រឹមតែគេ រហូតដល់ខ្ញុំ រហូតដល់គេស្អប់ខ្ញុំនេះទៀតពល់ថ្ងៃ ។

ព៉ស៊ីៈ គាត់ចាប់ពូដាក់គុកអញ្ចឹងពូខឹងគាត់ទេ?

វឿនៈ ខឹង ប៉ុនមិនដឹងធ្វើម៉េចគេទេ ។

ព៉ស៊ីៈ ចុះឥឡូវនៅខឹងទៀតទេ?

វឿនៈ ឥឡូវនៅតែខឹងអញ្ចឹង ។ ឃើញសឹង្គតែសុំហើយ បំណាច់តែដាក់គុកខ្ញុំហើយ យកខ្ញុំទៅហើយធ្វើបាបធ្វើទោសខ្ញុំទៀត ។

ព៉ស៊ីៈ ចុះប្រសិនបើឥឡូវពូបានជួបគាត់ តើពូហ៊ានធ្វើបាបគាត់ទេ?

វឿនៈ ហ៊ាន ។ ឲ្យតែឲ្យគឺដាក់ទាល់តែងាប់ឥឡូវ ធ្វើបាបខ្ញុំ ធ្វើបាបពួកម៉ាកបងប្អូនខ្ញុំគគោកគដី ហើយខ្ញុំ ម៉េចហ៊ានទៅតវ៉ានឹងគេ ។

ព៉ស៊ីៈ ចុះបើសិនជាមានតុលាការហើយ តុលាការហ្នឹងកាត់ទោសគាត់ អារម្មណ៍របស់ពូអស់ចិត្តទេ គំនុំទាំងប៉ុន្មានបានរសាយទេ?

វឿនៈ អស់ចិត្ត ឲ្យតែតុលាការកាត់ទោសគាត់ ខ្ញុំអស់ចិត្តហើយ ។ ពល់ថៃនេះឲ្យទៅជួប ហើយអន្តការថាអ្នែងហ៊ានទេម្នាក់ហ្នឹងធ្លាប់ធ្វើបាបអ្អែង អ្អែងនៅហ្នឹងដែលស្គាល់មុខទេ ថាស្គាល់ឲ្យតែឲ្យដាក់ឥឡូវហើយខ្ញុំនេះ តាមខឹងនេះ វាពេកទៅហើយ ។

ព៉ស៊ីៈ ពូមានអីចង់បន្ថែមជាងហ្នឹងទៀតទេ ពីមន្ទីរ១៣ ដែលខ្ញុំអត់ទាន់បានសួរ?

វឿនៈ អត់ទេ! បើខ្ញុំ នៅមិនសូវបានជាប់................ ។

ព៉ស៊ីៈ នៅឆ្នាំណាដែលពូចេញពីមន្ទីរ១៣ហ្នឹង?

វឿនៈ ចូល ៧៣ ហ្នឹងអត់ទាន់បានមួយឆ្នាំផង ខ្ញុំរត់ចេញវិញទេ ។

ព៉ស៊ីៈ មិនមែនគេដោះលែងទេអ្ហេះ?

វឿនៈ អត់ដោះទេ ខ្ញុំលែងអ្នកទោសបីនាក់នោះ ។

ព៉ស៊ីៈ ដល់លែងអ្នកទោសហើយ ពូជាប់ទោសវិញ?

វឿនៈ ជាប់គុក ។

រ៉ាស៊ីៈ ជាប់គុកបានប៉ុន្មានខែបានគេបញ្ជូនទៅវិញ?

វឿនៈ រត់ហើយគេបញ្ជូនខ្ញុំទៅវិញទៅ ។ បញ្ជូនទៅវិញ បានខ្មោចតាហម និងសោម ទៅយកខ្ញុំវិញ ។ ទៅយកមៅមៅនៅសហករណ៍ឯណោះវិញ កុំអីខ្ញុំងាប់ហ្នឹងបាត់ហើយ

**ប្រធានឃុំអមលាំង**ៈ មន្ទីរហ្នឹងអត់មានសួរនៅវែងប៉ុន្មានទេ ព្រោះខ្ញុំនៅនេះដែរ មន្ទីរហ្នឹងនៅរយៈពេលខ្លី ព្រោះ ឌុច ហ្នឹងគាត់ឆៅណាស់ មនុស្សគាត់សាហាវណាស់ ។

វឿនៈ អ្នកធ្វើការជាមួយវាឲ្យតែខុសសុទ្ធតែងាប់ហើយ គ្រាន់តែខ្ញុំហ្នឹងកុំរត់ចេញហើយ កុំប្រធានភូមធានាក៏ខ្ញុំងាប់ដែរ ប៉ុនបានគាត់ ។ អត់ស្រាយច្រវ៉ាក់ទេ ទោះទឹកលិចម៉េចក៏អត់មិនដោះអ្នកទោសដែរ ម៉េចនឹងហ៊ានដោះបើគេអត់បញ្ជាផង ខ្លាចងាប់ដែរ ។ ទឹកលិចបន្តិចម្តងៗ កងការពារឡើងចុងឈើអស់ទៅហើយ ។ អ្នកទោសគ្នានៅវាលនៅក្នុងរណ្តៅហ្នឹង ។ ................................ .......... (វឿន ជជែកជាមួយអធិការរងប៉ូលីសស្រុកថ្កូង) ។ ហ្នុងហើយៗ សុទ្ធតែអ្នកទោសនាំទៅកាប់នៅកន្លែងដីស្រែខាងជើងនោះវាលអស់ហើយ ហើយអាទំនប់ត្រពាំងទឹងខ្ញុំលើកនោះឥឡូវបាក់អស់ហើយ ។ នោះហើយដែលខ្ញុំលែងអ្នកទោសនៅទំនប់ត្រពាំងទឹងនោះហើយ ។

រ៉ាស៊ីៈ ទំនប់អីគេ?

វឿនៈ គេហៅទំនប់ត្រពាំងទឹង ប៉ុនដាក់ទំនប់អ្នកទោសក៏ត្រូវដែរ ប៉ុនគេហៅទំនប់ត្រពាំងទឹងអញ្ចឹង ។

រ៉ាស៊ីៈ ទំនប់ហ្នឹងនៅត្រង់ណាអញ្ចេះ ខ្ញុំទៅដូចអត់?

ឃិនៈ អាហ្នឹងកន្លែងសម្លាប់អ្ហេះ?

វឿនៈ អត់ទេ! កន្លែងចេញធ្វើការ ។ កន្លែងធ្វើការកាប់ដី លើកទំនប់ហ្នុងហើយ ។

រ៉ាស៊ីៈ នៅជិតត្រពាំងប្រាបហ្នឹងដែរទេអ្ហេះ?

វឿនៈ បាទ! ហ្នុងហើយ ខាងជើងបន្តិច ។

ឃិនៈ ហើយចម្ការគេនៅក្បែរៗខាងនេះ?

វឿនៈ ចម្ការគេនៅស្រែជញ្ជូន................

ឃិនៈ វាលខ្ពស់ៗហ្នឹងអី?

វឿនៈ បាទ! វាលដីខ្ពស់ ដីខ្សាច់ហ្នឹង ។

ឃិនៈ ដាំដំឡូងល្អណាស់មើលទៅ!

វឿនៈ បាទ! ដំឡូងប៉ុនៗកំភួនជើង ។

ឃិន ប៉ុនអត់ឲ្យអ្នកទោសហូបទេអញ្ចឹង?

វឿនៈ គ្រាន់កងការពារដើរទៅបង្ហើបលួចម៉ាមើមបាន ហើយលុបដីទៅវិញទៅ ។ បើលួចញឹកញាប់គេសង្ស័យរករឿងដែរលែងហ៊ាន ។

រ៉ាស៊ីៈ ពេលហ្នុងហូបបាយប៉ុប្បុបរ?

វឿនៈ ឌុច ហូបបាយ តែកងការពារហូបបបរ ។ គ្រាន់អ្នកទោសហូបបាយនឹងចាន អ្នកទោសហូបបាយនឹងបំពង់ទឹកត្នោតយើងហ្នឹង ។ ដាក់បបរ ។

យិនៈ ប៉ុនបបរដូចគ្នា?

វឿនៈ បបរដូចគ្នា លាយជាមួយបាយ លាយឆ្នាំងតូចមួយ មានប្រពន្ធ តាចាន់ ជាអ្នកធ្វើសេដ្ឋកិច្ចហើយកាលនោះ ។

រ៉ាស៊ីៈ ចុះ តាឌុច នោះ?

វឿនៈ ហ្នឹងហើយដាំឲ្យតា ឌុច និងប្តីគេ បីនាក់ហ្នឹងទេ ។

រ៉ាស៊ីៈ ប៉ុន ផល អីម៉េចដែរ?

វឿនៈ ប៉ុន ផល អីបាយដែរ ប៉ុនដល់ហើយហ្នឹងបាត់ឈ្មោះទៅ យកទៅសម្លាប់តាំងពីនេះបាត់ហើយអត់បាននៅប៉ុន្មានផង ។ មិនដឹងបញ្ជូនពីណាមៅ ផល ហើយនឹងប៉ុន ហ្នឹង ។ ឃើញបានប្រហែលកន្លះខែចុះស្រាប់តែបាត់អត់ដឹងទៅណា ខ្ញុំអត់ដឹងថាគេសម្លាប់ផង ឥឡូវបានឮគេថា ប៉ុនហើយនឹង ផល គេយកទៅវៃចោលបាត់ហើយ ។ ខ្ញុំចេញបាត់ហើយមានដឹងណា ពេលដែលខ្ញុំមៅខ្ញុំនៅហ្នឹងឡើយទេ ។

រ៉ាស៊ីៈ អញ្ជើញអរគុណពូច្រើនពូ!

វឿនៈ បាទ!

យិនៈ សូមអរគុណណាស់!ក្នុងការសម្ភាសន៍លោកពូរយៈប៉ុន្មានម៉ោងនេះ គឺបានទទួលពត៌មានល្អដល់ខ្ញុំណាស់ ។ សូមអរគុណ ។

វឿនៈ បាទ!

---

## ករណី មន្ទីរសន្តិសុខ ១៣ (ម-១៣)
## សម្ភាសន៍ជាមួយ ចាន់ ខន អាយុ៤៧ឆ្នាំ
## ភេទប្រុស រស់នៅភូមិក្បាលចិន (ភូមិទេពភិរម្យ ឃុំក្បាលចិន ស្រុកថ្ពង ខេត្តកំពង់ស្ពឺ
## ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៣

**ផ្នែក «ក»**

យិនៈ អញ្ជើញជិបហ៊ានជំបូង ខ្ញុំសុំអនុញ្ញាតិសុំស្គាល់លោកប្អូនឈ្មោះអីដែរ?

ខនៈ ខ្ញុំឈ្មោះ ខន ។

យិនៈ ស្អី ខនដែរ?

ខនៈ ចាន់ ខន ។

ឃិនៈ អាយុប៉ុន្មានហើយលោកប្អូនបច្ចុប្បន្នឥឡូវនេះ?

ខនៈ ៤៧ឆ្នាំ

ឃិនៈ ប្អូនមានប្រពន្ធនៅ?

ខនៈ មានហើយ ។

ឃិនៈ ប្រពន្ធឈ្មោះអីដែរ?

ខនៈ ភ៉ន់

ឃិនៈ សព្វថ្ងៃមានកូនចៅប៉ុន្មាននាក់ហើយ?

ខនៈ កូន៦ ។

ឃិនៈ ប្រុសប៉ុន្មានស្រីប៉ុន្មាន?

ខនៈ ប្រុស២ ស្រី៤ ។

ឃិនៈ កូនប្អូន កូនពៅផុតអាយុប៉ុន្មានហើយ?

ខនៈ ៧ឆ្នាំ ។

ឃិនៈ ចុះបងគេ?

ខនៈ បងគេ ១៦ឆ្នាំហើយ ។

ឃិនៈ ហើយប្អូនសព្វថ្ងៃរស់នៅភូមិអី ឃុំអី ស្រុកអី ខេត្តអី?

ខនៈ នៅភូមិក្បាលចិន ។

ឃិនៈ ទេឥឡូវនេះ សួរឥឡូវសិន?

ខនៈ ឥឡូវនេះ នៅទេពកិរម្យ ។

ឃិនៈ ភូមិហ្នឹងភូមិអី?

ខនៈ ទេពកិរម្យ ។

ឃិនៈ អញ្ចឹងមិនមែនភូមិក្បាលចិនទេអញ្ចឹង?

ខនៈ អាខ្លះគេហៅអញ្ចឹង ។

ឃិនៈ អូរ! គេហៅពីរ ។

ខនៈ បាទ!

ឃិនៈ ប៉ុនដល់ឃុំ ឃុំអី?

ខនៈ ឃុំវាលពន់ ។

ឃិនៈ ស្រុកថ្មីណោះ?

ខនៈ បាទ!

យិនៈ ចុះសម័យខ្មែរក្រហម ប្អូននៅជាមួយឪពុកម្ដាយនៅក្នុងភូមិណា ឃុំណា ពី៧០-៧៥?

ខនៈ ឆ្នាំ ៧០ ខ្ញុំនៅអមលាំង ។

យិនៈ គេហៅភូមិអី?

ខនៈ តានាប ។

យិនៈ ឪពុកម្ដាយនៅត្រង់ហ្នុងដែរណោះ?

ខនៈ បាទ!

យិនៈ អញ្ចឹងពេលដែលគេហៅប្អូនចូលក្នុងកងសន្តិសុខម-១៣ ហៅមន្ទីរសន្តិសុខ ១៣ ហ្នឹង គេទៅហៅពីផ្ទះម៉ោឬយ៉ាងម៉េច?

ខនៈ ប្រធានភូមិគេបញ្ជូនមោឃុំ ។ ឃុំគេបញ្ជូនម៉ោទៀតមៅ ។

យិនៈ គេមានបញ្ជូនប្អូនទៅហាត់រៀនត្រង់ណាទេ មុននឹងយកទៅកន្លែងនោះ?

ខនៈ អត់ទេ!

យិនៈ យកទៅ ប្រគល់បញ្ជូនទៅ ម-១៣ ហ្នឹងហ្មង?

ខនៈ បាទ! បញ្ជូនទៅហ្នុងហ្មង ។

យិនៈ អញ្ចឹងដំបូងប្អូនបានទៅជួបពីណានៅកន្លែងម-១៣ហ្នឹង?

ខនៈ ទេមិនដឹងជាពីណាៗទេ ភ្លេចឈ្មោះអស់ហើយ ២០-៣០ឆ្នាំហើយ ។

យិនៈ អើ! ហើយនៅក្នុងហ្នុងក្រោយមៅគេមានបង្ហាត់បង្រៀនអីប្អូនទេ?

ខនៈ អត់ទេ! អត់មានបង្ហាត់អីទេ យកទៅដល់ឲ្យនៅអង្គុយយាមអ្នកទោសហ្នឹងហ្មង ។

យិនៈ មានប្រគល់កាំភ្លើងអីឲ្យទេ?

ខនៈ មាន

យិនៈ ប្អូនមានស្គាល់មេៗដែលប្អូននៅយូរ រយៈពេលប៉ុន្មានឆ្នាំឥឡូវទៅហ្នុងពីណាទល់ឆ្នាំណា?

ខនៈ ៧៣-៧៥ ។

យិនៈ ពីរឆ្នាំ ប្អូនអាចស្គាល់មេប្រធានសន្តិសុខ អនុប្រធានសន្តិសុខឈ្មោះអី?

ខនៈ មេគេ តាឌុច ហ្នឹងហ្មង ។

យិនៈ ចុះអនុ?

ខនៈ អនុ តាចាន់ ។

យិនៈ ចាន់ ហ្នឹងសព្វថ្ងៃនៅឯណាប្អូនមានដឹងទេ?

ខនៈ អត់ដឹងទេ បើបែកគ្នាតាំងពី៧៥ មៅរហូតហ្មង ។

យិនៈ ចាន់ តែមួយទេអ្ហេះ ឬក៏មានពីណាជាអនុទៀត?

ខនៈ មិនដឹងពីណាៗទេ បើមានគគោកគដី ។

យិនៈ មានស្គាល់ឈ្មោះ ប៊ុន ទេ?

ខនៈ មានៗ

យិនៈ ផល?

ខនៈ មាន! ផល ហ្នឹងគេវៃចោលបាត់ហើយ ។

យិនៈ ផល វៃចោលដែរ?

ខនៈ បាទ!

យិនៈ ចុះ ប៊ុន?

ខនៈ ប៊ុន អត់ដឹងផង ដល់បែកភ្នំពេញមៅ ។

យិនៈ អញ្ចឹងអ្ហេះ?

ខនៈ បាទ!

យិនៈ មានស្គាល់ពីណាទៀត? តាមាស អីស្គាល់ទេ?

ខនៈ ស្គាល់ ។ តាមាស ស្រុកនៅអមលាំងដែរ ។

យិនៈ នៅរស់ទេ?

ខនៈ ងាប់អស់ហើយ ។

យិនៈ អញ្ចឹងប្អូននៅទីនោះ ប្អូនបានដឹងថា ឌុច ហ្នឹងជាប្រធានគេមែនទេ?

ខនៈ បាទ!

យិនៈ ឌុច ដែលបានជួប និយាយផ្ទាល់អី ប្រជុំអីបង្ហាត់បង្រៀនប្អូនអី ណែនាំអីផ្ទាល់មាត់អីយ៉ាងម៉េច ទេ គាត់មានប្រសាសន៍អីយ៉ាងម៉េច គាត់ដែលនិយាយយ៉ាងម៉េចខ្លះ តាឌុច ហ្នឹង?

ខនៈ អត់ គ្រាន់តែយកទៅដល់ណែនាំថា ឲ្យការពារ ។

យិនៈ ឲ្យការពារអ្នកទោស?

ខនៈ បាទ!

រ៉ាស៊ីៈ កាលចូលហ្នឹងពូអាយុប៉ុន្មានកាលហ្នឹង?

ខនៈ ១៨ឆ្នាំ ។

រ៉ាស៊ីៈ ហើយម៉េចបានជាគេមៅហៅពូទៅវិញ? គេប្រាប់ថាម៉េចដែរ?

ខនៈ បើនៅក្នុងរបបគេ ។

យិនៈ គេមៅប្រាប់ពូថាម៉េច?

ខនៈ បើគេយកទៅ គេយកទៅ៣០-៤០នាក់ណោះ ដល់គេកាត់ឈ្មោះមៅបានប៉ុន្មាននាក់ចូលមៅ ហ្នឹង ។ គេបញ្ជូនទៅវៃលន់ ណុលអស់ទៅ នៅសល់ខ្ញុំតូចៗ គេបញ្ជូនមៅហ្នឹង ។

យិនៈ អូរ! អញ្ចឹងបញ្ជូនទៅទ័ពមាំចំនួន ៣០-៤០នាក់ ហើយចុះចូលមៅដល់មន្ទីរនេះប៉ុន្មាននាក់?

ខនៈ កាលហ្នឹងមិនដឹងចូលម៉ៅប៉ុន្មាននាក់នៅឃុំអមលាំងហ្នឹង ម៉ៅច្រើន?

ឃិនៈ មន្ទីរ ១៣ ហ្នឹង?

ខនៈ បាទ! ម៉ៅប្អូនដប់នាក់ តែមិនដឹងជាអាណាអាណី វាភ្លេចវង្វេងគ្នាអស់ហើយ ។

ឃិនៈ អញ្ចឹងប្អូនអត់មានចាំឈ្មោះណាមួយទេណោះ?

ខនៈ នៅចាំខ្លះដែរ ប៉ុនស្លាប់អស់ហើយ មិនដឹងជាអាណានៅណាអីណា នៅរស់តែខ្ញុំហ្នឹងមួយហ្នឹង ។

ឃិនៈ ចំពោះពួកសន្តិសុខហ្នឹង?

ខនៈ បាទ! មិនដឹងគេនៅឯណាអីណាទៀតណាស់ ។

ឃិនៈ អ្នកទៅជាមួយហ្នឹងអត់មានអ្នកណានៅជាមួយទេ?

ខនៈ អត់មានទេ ស្លាប់អស់បាត់ហើយ ។

វ៉ាស៊ីៈ ពូនៅឆ្នាំ ៧៣ ដែលពូទៅដល់មន្ទីរ ១៣ ហ្នឹង ពូទៅដល់ឃើញអ្នកទោសហ្មង ឬក៏អត់ទាន់មាន អ្នកទោសទេ?

ខនៈ ទៅឃើញអ្នកទោសហ្មង នៅគគោកគដីហ្នឹង ។

វ៉ាស៊ីៈ ពូឃើញអ្នកទោសហ្នឹង តើស្ថិតក្នុងសភាពយ៉ាងម៉េចដែរ អ្នកទោសហ្នឹងអ្ហាស់?

ខនៈ ស្ថិតនៅជារបៀបគេដាក់ខ្នោះហ្នឹងអ្ហាស់ ។

វ៉ាស៊ីៈ ខ្នោះនៅលើដី ឬនៅក្រោមដី?

ខនៈ ដំបូងមិនទាន់ B-52 ទម្លាក់នៅលើដីទេ ។ ដល់ B-52 ទម្លាក់បានជីកទម្លាក់ចូលទៅក្នុងដី ។

វ៉ាស៊ីៈ អូរអញ្ចឹងបានន័យថា យករណ្តៅ B-52 ហ្នឹងធ្វើរណ្តៅដាក់ហ្មង?

ខនៈ អត់ទេ! ជីកថែមទៀត ខ្លាចអា B-52 ទម្លាក់ត្រូវ ។

ឃិនៈ អាបេទម្លាក់ហ្នឹងឆ្នាំណាលោកប្អូន?

ខនៈ ឆ្នាំ ៧៣ ហ្នឹង B-52 ទម្លាក់ ។

វ៉ាស៊ីៈ ហើយមានទម្លាក់ចំទេ?

ខនៈ អត់មានចំទេ ៗ ។

វ៉ាស៊ីៈ អញ្ចឹងជីកដាក់អ្នកទោសក្នុងដីហ្នឹងគឺដើម្បីបន្លំកុំឲ្យកប៉ាល់ហោះមើលម៉ៅឃើញថាជាជំរុំរបស់ ឌុច អញ្ចឹងអ្ហេះ?

ខនៈ បាទ!

វ៉ាស៊ីៈ ហើយពូដែលឃើញកប៉ាល់ហោះម៉ៅទម្លាក់ទេ?

ខនៈ កប៉ាល់ហោះម៉ៅគគោកគដី តែអត់ដែលទម្លាក់ត្រូវទេ ។

ឃិនៈ ក្បែរៗហ្នឹង?

ខនៈ បាទ! ឆ្ងាយៗ ។

ភ៉ាស៊ីៈ ពេលដែលទម្លាក់ហ្នឹង ឌុច នៅហ្នឹងដែរ?

ខនៈ នៅហ្នឹង ។ បើវាមេនៅហ្នឹងហើយ ។

ភ៉ាស៊ីៈ ពូនៅជាប់ជាមួយ ឌុច ហ្នឹងអ្ហេះ?

ខនៈ អត់ទេ! ខ្ញុំកងការពារ ។

ភ៉ាស៊ីៈ អញ្ចឹងខ្ញុំចង់ឲ្យពូរៀបរាប់ ពីកងការពារ តើ ឌុច ហ្នឹងបានបែងចែកជាប៉ុន្មានក្រុម កងការពារអ្នកទោស ឬកងការពារអ្នកទោសទៅធ្វើការ ឬកងការពារសួរចម្លើយ អីយ៉ាងម៉េច ខ្ញុំចង់ឲ្យពូជួយរៀបរាប់ឲ្យខ្ញុំបន្តិចមើលពូ?

ខនៈ គឺពិបាកតាមដានណាស់ គេធំៗគេអ្នកសួរចម្លើយទៅ យើងតូចៗនេះយាមអ្នកទោសដែលគេដាក់ហ្នឹង ។ ដល់ធំទៅមានសមត្ថភាពទៅ គេឲ្យទៅយាមការពារកន្លែងក្រៅវង្វង់ហ្នឹង ។ ដល់តូចៗគេខ្លាចអ្នកទោសវៃហ្នឹងនៅខាងក្នុងទៅណាស់ ។ យាមនៅខាងក្នុងអ្នកទោសដែលជាប់ហ្នឹង ព្រោះអ្នកទោសថ្ងៃឡើងវាចេញទៅធ្វើការ ហ្នឹងគេយកធំៗជាអ្នកបណ្តើរទៅ ។

ឃិនៈ មានកាំភ្លើងដែរ?

ខនៈ កាំភ្លើងមាន ។

ឃិនៈ ដល់អ្នកទោសធ្វើការមានកាំភ្លើងនៅយាមជុំវិញទៅ?

ខនៈ បាទ!

ភ៉ាស៊ីៈ កងការពារអ្នកទោសដូចពូអញ្ចឹងមានដែលបាន មានសិទ្ធិធ្វើទារុណកម្មដល់អ្នកទោសទេ?

ខនៈ អត់ទេ! គេមានវិន័យគេត្រឹមត្រូវដែរ ។

ភ៉ាស៊ីៈ មានវិន័យគេដែរ?

ខនៈ បាទ!

ភ៉ាស៊ីៈ វិន័យគេមានបែងជាម៉េចខ្លះទៅ?

ខនៈ វិន័យគេ ហាមឃាត់យើងអត់វៃ ជេរគេទេណា លុះត្រាតែគេអ្នកសួរចម្លើយហ្នឹងបានគេមានសិទ្ធិវាយដំ ។ យើងអ្នកការពារមានសិទ្ធិតែការពារកុំឲ្យគេរត់ទេ ។ បើរត់យើងមានសិទ្ធិឲ្យបាញ់

ភ៉ាស៊ីៈ មានអ្នកទោសដែលលួចរត់ទេ?

ខនៈ រត់រាល់តែលើក ។

ភ៉ាស៊ីៈ ពូមានដែលតាមចាប់បានមកវិញទេ?

ខនៈ អត់! តែរត់ រត់រួចហើយ អត់ដែលចាប់បានមកវិញទេ ។

ឃិនៈ ចុះថាពេលធ្វើមានដាក់ច្រវ៉ាក់ដាក់អី ម៉េចក៏មានរត់មានអី?

ខនៈ អាហ្នឹងអ្នកដែលអត់ដាក់ច្រវ៉ាក់នោះ អ្នកដែលថាទោសស្រាលនោះ ។ ដូចថាវាទុកចិត្តទៅ រត់ទៅ ហើយអ្នកដែលគ្នាធ្ងន់ៗហ្នឹង អាហ្នឹងគេដាក់ច្រវ៉ាក់ករទៅ ។

រ៉ាស៊ីៈ  បើតាមពូដឹងអ្នកទោសដែលបានមកដាប់នៅហ្នឹង ច្រើនធ្វើអីខុស?

ខនៈ  ទេ! មិនដឹងទេ បើឃើញតែចាប់មកមិនដឹងពីណាពីណាទេ អាខ្លះឈ្លើយសឹកទៅ អាខ្លះប្រជាជនយើងក្នុងភូមិអញ្ចឹងទៅ ។ ឃើញតែបញ្ជូនរាល់តែថ្ងៃរាល់តែខែទៅ ។

ឃិនៈ  មានស្រីមានប្រុសទេ?

ខនៈ  មានគ្រប់! ស្រីក៏មាន ប្រុសក៏មាន ។

ឃិនៈ  មានក្មេងទេ?

ខនៈ  ក្មេងក៏មានដែរ ចាស់ក៏មាន ។

ឃិនៈ  មានយកទៅដែរក្មេង?

ខនៈ  បាទ! ក្មេងប៉ុនៗណឹង ទៅដល់ហ្នឹងគេបញ្ជូនឡើងទៅ ។

ឃិនៈ  ឡើងទៅណា?

ខនៈ  បញ្ជូនឡើងទៅលើអញ្ចឹងទៅ មិនដឹងទៅណា ។ អត់ឲ្យនៅហ្នឹងទេ ។

រ៉ាស៊ីៈ  ពូក្នុងមួយថ្ងៃពូយាមអ្នកទោសប៉ុន្មានម៉ោង?

ខនៈ  យាមពីរម៉ោង ។

រ៉ាស៊ីៈ  មួយថ្ងៃយាមតែពីរម៉ោងទេ?

ខនៈ  បាទ!

រ៉ាស៊ីៈ  ហើយចុះចប់ពីម៉ោងពូទៅ?

ខនៈ  ចប់ហើយ គេទៀតទៅ ។

រ៉ាស៊ីៈ  កងការពារដូចគ្នាដែរ?

ខនៈ  បាទ! យើងដូរគ្នា

រ៉ាស៊ីៈ  ពូយាមពីម៉ោងប៉ុន្មានដល់ម៉ោងប៉ុន្មាន?

ខនៈ  វាអត់ទៀងដែរ ជួនកាលម៉ោងយើងត្រូវយាមពីម៉ោង៧ព្រឹកឡើងដល់ម៉ោង៨ ៩អញ្ចឹងយើងឈប់ទៅ សម្រាករហូតបានស្អែកឡើងដល់ម៉ោងយើងយាមទៀត ។

ឃិនៈ  ពេលពូសម្រាកហ្នឹង ពូសម្រាកនៅឯណា?

ខនៈ  ទៅសម្រាកនៅឆ្ងាយពីដីគុក ប្រហែលពី១០-២០នាក់ ។

រ៉ាស៊ីៈ  មានរោងមួយនៅហ្នុងទៅ?

ខនៈ  បាទ! រោងអ្នកកងការពារផ្សេងទៅ រោងគេអ្នកសួរចម្លើយផ្សេងទៅ ។ មេគេនៅផ្សេងទៅ ។ ដល់ពេលទៅបាយបានយើងបាយរួម បាយជាមួយគ្នា ។

រ៉ាស៊ីៈ  ពីណាគេអ្នកកាន់រោងបាយពូ?

ខនៈ អ្នកទោសស្រាលៗជាអ្នកកាន់រោងហ្នឹង យើងកងការពារហ្នឹងអត់មានទៅប្រឫកប្រឫស់ទេ ។ នៅអ្នកទោសដែលជាប់ទេ ។

វ៉ាស៊ីៈ ចុះ តាឌុច ដែលធ្វើទារុណកម្មដោយផ្ទាល់ដៃគាត់ទេទៅលើអ្នកទោស?

ខនៈ ទេ! ពិបាកណាស់ ព្រោះខ្ញុំវានៅតូចដែរណាស់ ។

យិនៈ មានដែលឃើញផ្ទាល់ភ្នែកទេ?

ខនៈ អត់ហ៊ានទៅប្រឫកប្រឫស់ជាមួយផង ។

យិនៈ កន្លែង ឌុច ហើយហ្នឹងកន្លែងប្អូនឯងចម្ងាយប៉ុន្មានពីគ្នា?

ខនៈ ដាច់ឆ្ងាយពីគ្នា ។ ប្រហែលពីហ្នឹងទៅផ្ទះប្អូនអាជ្ញូវបែកមុខនោះ ហើយយប់ឡើងយើងមានដើរទៅណា ដុតមៅ៉ងយើងយាមទៅកន្លែងវិញទៅ គេអត់ឲ្យដើរចេញក្រៅទេ អត់ឲ្យដើរពីកន្លែងមួយទៅកន្លែងមួយទេ ។

វ៉ាស៊ីៈ ពូមានប្រសាសន៍មិញថា កងការពារគេឲ្យនៅមា៉រោង អ្នកសួរចម្លើយគេឲ្យនៅមា៉រោង ហើយប្រធានគេនៅមា៉រោង?

ខនៈ បាទ! គេនៅផ្សេងៗគ្នា អញ្ចឹងហើយបានជាយើងចប់ការងារយើងទៅរោងយើងទៅ ។

វ៉ាស៊ីៈ មា៉រោងពូមានគ្នាប៉ុន្មាននាក់ដែរ?

ខនៈ ១០នាក់ជាង ។

វ៉ាស៊ីៈ កងការពារហ្នឹង១០នាក់ជាងអ្ហេះ?

ខនៈ បាទ!

វ៉ាស៊ីៈ ហើយអាយុច្រើនជាងគេប៉ុន្មាន?

ខនៈ ក្តាប់អត់បានទេ ។

វ៉ាស៊ីៈ ប្រហែលប៉ុន្មាន?

យិនៈ មិនមានអ្នកចំណាស់ចាស់ជាងអីទេ?

ខនៈ មានច្រើនដែរណាស់ ។

យិនៈ ហើយអ្នកដែលចំណាស់ហ្នឹងច្រើនមេៗម៉េច?

ខនៈ បាទ! ច្រើនមេៗ ។ក្មេងៗតូចអញ្ចឹងទៅ ហើយខ្ញុំទៅតាំងពីប៉ុណ្ណេះម៉េះ(អាយុប្រហែល១០ឆ្នាំ)

វ៉ាស៊ីៈ កាលហ្នុងពីណាគេប្រធានពូមា៉កងការពារទាំងអស់?

ខនៈ អត់មានពីណាគេប្រធានទេ វាកងការពារហ្នឹងក្រោមការគ្រប់គ្រងរបស់គេហ្នឹងបណ្តោយ ។

យិនៈ ហើយលោកប្អូនគ្រប់គ្រងអ្នកទោសប៉ុន្មាននាក់?

ខនៈ អត់ទេ! នៅយាមហ្នុង ដូចថានៅក្នុងគុកហ្នឹងនៅយាមទាំងអស់ហ្នុង ។ អ្នកទោសនៅមា៉រយ យើងនៅយាមទាំង១០០ហ្នឹងទៅ ពីរនាក់ហ្នឹង ។

យិនៈ គ្នាពីរនាក់អ្ហេះ?

ខនៈ បាទ! យាមម្តងពីរនាក់ៗ យាមតែឯងមើលម៉េចឃើញអស់ បើមនុស្សវាច្រើនៗ យាមដើរហូតអត់មានអង្គុយយាមទេៗ

រ៉ាស៊ីៈ យើងដើរនៅលើអញ្ចឹង អ្នកទោសនៅខាងក្រោមនោះទៅ?

ខនៈ បាទ!អ្នកទោសនៅក្រោមៗ

រ៉ាស៊ីៈ អ្នកទោសមានដែលស្រែកឲ្យជួយឲ្យអីទេ?

ខនៈ ថ្មីមិនស្រែក ប៉ុនគ្មាននរណាហ៊ានជួយៗ

យិនៈ អាហ្នឹងពេលណា ពេលដែលស្រែកហ្នឹង ពេលវៃប្តអី?

ខនៈ បាទ! ពេលដែលវៃអីហ្នឹងស្រែកទៅ ស្រែកឲ្យជួយ ប៉ុននរណាហ៊ានជួយ គ្រាន់តែបានឮៗ

យិនៈ ចុះរបៀបដាក់គុកនៅក្នុងដី តើដាក់របៀបម៉េចប្អូនមានអើតមើលតើដាក់ឲ្យដេកម៉េចក្នុងដីហ្នឹង?

ខនៈ ដាក់ឲ្យដេកអញ្ចឹងលើក្តារៗ

យិនៈ ហើយដេកលើក្តារ?

ខនៈ បាទ!

យិនៈ ហើយក្បាលចេញខាង ជើងចូលគ្នា?

ខនៈ បាទ! ជើងចូលគ្នាៗ

យិនៈ ហើយមានរុញខ្នោះអញ្ចេះម៉េច?

ខនៈ បាទ! រុញខ្នោះ រុញទៅរុញមៅៗ ម៉ាខ្នោះ១០នាក់អីអញ្ចឹងមៅៗ

រ៉ាស៊ីៈ ឮសួរថាមានទឹកឡើងមៅស្លាប់អ្នកទោសអស់ច្រើនណាស់មែនទេ នៅឆ្នាំណា?

ខនៈ នៅឆ្នាំ១៩៧៤ៗ កាលហ្នឹងលិចមែនៗ

យិនៈ លិចមែន?

ខនៈ បាទ!

យិនៈ ឃើញដែរ?

ខនៈ ខ្ញុំនៅហ្នឹងដែរ ប៉ីសងាប់ដែរៗ

យិនៈ ចុះគេថាអញ្ចេះ ពេលដែលទឹកលិចហ្នឹងកងការពារទាំងអស់ឡើងដើមឈើ ទាំងតា ឌុច ហ្នឹងអីក៏ឡើងដើមឈើមែនទេ?

ខនៈ បាទ!ហ្នឹងហើយៗ

យិនៈ ចុះបើមិនឡើង?

ខនៈ បើមិនឡើងលិចងាប់ខ្លួនឯងដែរៗ

យិនៈ បើអញ្ចឹងទឹកហ្នឹងធំណាស់អញ្ចឹង?

ខនៈ ទឹកលិចអស់អាលីង លិចដល់ព្រៃទួលណាណោះ ។
ឆ្លើយៈ រួចចុះអ្នកទោសមាំជំនាន់ហ្នឹងលិចងាប់អស់ហើយអញ្ចឹង?
ខនៈ អ្នកទោសងាប់ខ្លះ រស់ខ្លះពេលដែលចាក់សោធាន់ ។ ឧទាហរណ៍អ្នកដែលស្រាល១ គេទៅចាក់យកមៅណាស់! អ្នកធ្ងន់នៅក្នុងហ្នុងទៅ ។
យិនៈ នៅក្នុងរណ្ដៅជ្រៅអាណាចូលទៅចាក់ឲ្យ!
ខនៈ បាទ! អត់ហ៊ានទៅ ខ្លាចងាប់ដែរហ្នឹង ។
រ៉ាស៊ីៈ ជម្រៅប្រហែលប៉ុន្មានដែរ?
ខនៈ ប្រហែល ៣ ម៉ែត្រ ។
យិនៈ ហើយក្នុងមាំរណ្ដៅដែលគុកហ្នឹងដាក់បានប៉ុន្មាននាក់?
ខនៈ ដាក់បាន៨០ ៧០ នាក់អីណោះ ។
យិនៈ ប៉ុន្មានរណ្ដៅគុកហ្នឹង?
ខនៈ មិនដឹងប៉ុន្មានទេពីរបីរណ្ដៅណោះ ។
យិនៈ បុិនពួកហ្នឹងមិនស្ថិតស្ថេរទេ នៅតែវៃចោលហើយបានដាក់ទៀតអ្ហះ?
ខនៈ បាទ! ចេញចូល១ហ្នឹង ។
យិនៈ មិនថានៅស្ថិតស្ថេររហូតទេ?
ខនៈ អត់ជាប់រហូតទេ ។
រ៉ាស៊ីៈ មាំរយៈសួរចម្លើយវៃចោលហើយ បាន?
ខនៈ បាទ! ដល់អញ្ចឹងទៅមិនដឹងជាគេយកទៅឯណា វៃចោលមិនដឹង យកទៅណាមិនដឹងណាស់ វាចេះតែបាត់អស់ទៅ ឃើញគេយកទៅដាក់ទៀតទៅ ។ ដាក់តាំងខ្សែ១ ។
យិនៈ ប្អូនឃើញកន្លែងតា ឌុច សួរចម្លើយនៅត្រង់ណា?
ខនៈ នៅក្បែរគុកហ្នឹង ។
យិនៈ មានអីជាសម្គាល់ទេ?
ខនៈ អត់មានទេ ។ ជំនាន់ហ្នុងមានអី មានតែតុមួយ ។
យិនៈ តុមួយហើយមានប្រក់ដូបូលទេ?
ខនៈ មានផ្ទះគាត់នៅហ្នុង ។
យិនៈ ជាពេន?
ខនៈ បាទ! ជាពេនគាត់នៅហ្នឹងហើយមានតុមួយ កៅអីមួយ អង្រឹងមួយចងនៅហ្នឹង ។
រ៉ាស៊ីៈ ព្នសួរថាកាលហ្នឹងគាត់មានកូនពីរនាក់ដែរលោកពូអ្ហះ?
ខនៈ កាលហ្នឹងគាត់អត់ទាន់មានប្រពន្ធទេ ។

រ៉ាស៊ីៈ  អត់ទាន់មានប្រពន្ធទេ?

ខនៈ  បាទ! ប្រពន្ធទើបតែបាននៅចប់ហើយនេះទេ ស្រឡាញ់យាយ រ៉ុម គាត់ដេរនៅអមលាំងនេះ ។

ឃិនៈ  ចប់ឆ្នាំណា? ចប់ ៧៩ ហ្នឹង គាត់ទើបតែយក៧៩ហ្នឹងទេ?

ខនៈ  បាទ! កាលពីនៅវៃហ្នឹងអត់ទាន់ ។

រ៉ាស៊ីៈ  អត់ទាន់មានប្រពន្ធ ហើយដល់ពេល ៧៩ហ្នឹង បានគាត់ស្រឡាញ់ហើយការហ្នឹងអ្ហេះ?

ខនៈ  អត់ដឹងផង ។ ដល់នេះហើយបានឮថាបានយាយ រ៉ុម ហ្នឹង ព្រោះកាលពីមុនមៅ គាត់ស្រឡាញ់យាយ រ៉ុម ហ្នឹង ដល់ចប់ហ្នឹងឮថាបានយាយ រ៉ុម ហ្នឹងទៅ ។

ឃិនៈ  ចុះថាមានកូនពីរនាក់មែនទេ?

ខនៈ  កូនអត់ដឹងផង ។ ដូចខ្ញុំជំរាបបងឯងអញ្ចឹងថា ដល់ពេល៧៩ ហ្នឹងខ្ញុំជាប់សមាសភាពទៅ គេដកខ្ញុំឲ្យមៅនៅកងចល័ត ។ បើអត់ជាប់កងចល័តនៅរហូតហ្នឹង ប្រហែលអត់បានចូលស្រុកផង មិនដឹងធ្លាក់ណាធ្លាក់ណីអស់បាត់ហើយ ។

ឆ្លើយៈ កាលហ្នុងបើសិនជានៅរហូត ប្រហែលជាបាននៅ ប្រសិទ្ធ(មន្ទីរសន្តិសុខភ្នំប្រសិទ្ធ) បាត់ហើយ

ខនៈ  នៅប្រសិទ្ធិអី នៅភ្នំពេញណោះ នៅទួលស្លែងណោះ មិនមែនគុកធម្មតាណាពួកខ្ញុំនេះនោះ ។

រ៉ាស៊ីៈ  អញ្ចឹងបានជា ឌុច ផ្លាស់ពីនេះទៅទៅកាន់នៅហ្នុង ។

ខនៈ  បាទ!

ឃិនៈ  អញ្ចឹងលោកប្អូនឯងមិនដែលឃើញ ឌុច ហ្នឹងសួរចម្លើយ វៃមនុស្សផ្ទាល់អី ដូចអុជចន្ទុះអុជអីដូចដែលតា អ៊ុន និយាយហ្នឹងទេ?

ខនៈ  អត់ដែលឃើញទេ ព្រោះអី បើសិនជាអ្នកទោស ហ្នឹងគេឃើញខ្លួនគេណា ព្រោះគេយកទៅធ្វើទារុណកម្មអី ។ បើកងការពារ ប្រសិនបើបងឯងសួរចម្លើយអញ្ចឹង គ្រាន់តែស្តាប់ឮហ្នឹងគេមិនឲ្យយើងស្តាប់ផងខ្លាចបែកការណ៍ ។

ឃិនៈ  កន្លែងសួរចម្លើយមានប៉ុន្មានកន្លែង?

ខនៈ  មានច្រើនណាស់ ។ អញ្ចឹងមេៗគេសួរទាំងអស់ ទាំងតា ឌុច ទាំង ប៉ុន ទាំង ចាន់ មាស អីហ្នឹង គេសួរទាំងអស់ ។

ឃិនៈ  ដល អីហ្នឹង?

ខនៈ  បាទ! គេសួរតាមថ្នាក់គេអញ្ចឹងទៅ ។

ឃិនៈ  អញ្ចឹងដល់ពេលដែលសួរហើយភារកិច្ចគេអ្នកដែលវៃ អ្នកសួរហ្នឹងទៅវៃ ឬក៏មានអ្នកវៃផ្សេង?

ខនៈ  គេអ្នកសួរហ្នឹង ។

ឃិនៈ  អញ្ចឹងអ្ហេះ?

ខន: គេវែងប្រចំធាក់តែខ្លួនគេហ្នឹង យើងកងការពារអត់មានសិទ្ធិទៅជិតទេ គ្រាន់ទៅយាមអីហ្នឹង គេអត់យើងទៅប៉ះពាល់ដែរ ។

យិន: ចុះខុបមាថាសួរហើយត្រូវកម្ទេចចោល អ្នកណាអ្នកកម្ទេច? មានក្រុមកម្ទេចផ្សេងឬម៉េច?

ខន: ពួកសួរចម្លើយហ្នឹង គេវិនិច្ឆ័យខ្លួនគេហ្នឹង ដោះស្រាយអីខ្លួនគេហ្នឹងទៅ ។ ឯកងការពារនេះជាគ្រាន់បានត្រឹមតែយាមទេ គ្មានសិទ្ធិអីទៅ..... ។

យិន: គ្រាន់តែបានយាមទេ អត់មានទៅបាញ់ទៅវៃអី ។

ខន: បាទ! អត់មានសិទ្ធិទៅវៃគេទេ ត្បិតថានៅក្នុងសង្គមហ្នឹងមែន ប៉ុនអត់មានវៃទេ ។ បើថាយកទៅវៃចោលៗហ្នឹង ។

យិន: អញ្ចឹងអេ្ហះ.?

ខន: បាទ!

យិន: គេបញ្ជាមៅថាឲ្យយកទៅវៃចោលអាហ្នឹងបានមាន?

ខន: បាទ!

យិន: ថាឲ្យនៅទៅវៃតែហ្នឹង?

ខន: មិនឲ្យនៅក្នុងគុកអីយើងចេះតែដើរទៅ ដូចយើងរាល់ថ្ងៃដឹកស៊ីស្រវ៉ឹងអីទៅវៃប៉ាតណាប៉ាតណី ជាប់គុកខ្លួនឯងឥឡូវហ្នឹង ។ ដូចតា ផល ហ្នឹងដែលគេវៃចោលរឿងអញ្ចឹងណាស់ ។

ក៉ាស៊ី: រឿងម៉េច?

ខន: រឿងអំណាចអញ្ចឹងណាស់ ។ គាត់សីលធម៌ផង ហើយអាងអំណាចគាត់ធំផង ។

យិន: អើ! ផល ហ្នឹងមួយ?

ខន: បាទ!

យិន: ហើយ ប៉ុន ដែរអេ្ហះ?

ខន: តា ប៉ុន អត់ដឹងផង ។

យិន: ប៉ុន ពូថាតា ឌុច វៃចោលដែរ!

ខន: ហ្នឹងសុទ្ធតែដៃគូ គេហើយណា ។ តា ផល ហ្នឹងពួកម៉ាកហ្នឹង ។

យិន: តា មាស នោះផង ដៃដល់ដែរ?

ខន: ហ្នឹង សុទ្ធតែខ្សែគេហើយ ។

ក៉ាស៊ី: ពូថាសួរចម្លើយគេសួរតាមថ្នាក់ម៉េច ខ្ញុំអត់ទាន់យល់?

ខន: សួរតាម ដូចថាទោសធ្ងន់ទៅ មេគេសួរទៅ ។ ដូចទោសល្មមៗ គេបន្ទាប់ៗគេសួរទៅណា អាហ្នឹងតាមថ្នាក់គេ ។

ក៉ាស៊ី: ហើយ ចុះអ្នកទោសស្រាលអត់ដែលសួរទេណោះ?

ខនៈ ទោសស្រាល គេយកទៅដាក់ធម្មតា គ្រាន់តែសួរដូចយើងកត់កំណត់ហេតុ ដឹងពីជីវប្រវត្តិហ្នឹង

ភាស៊ីៈ ហើយទាំងអ្នកទោសចូល អ្នកទោសចេញគេមានដែលកត់ឈ្មោះក្នុងបញ្ជីអីគេទេ?

ខនៈ គេមានតែកត់ដូចយើងដែរ ។

ភាស៊ីៈ ប្រសិនបើមាននៅសល់បញ្ជីហ្នឹងល្អហ្មង! ។

យិនៈ មានបញ្ជីកត់ត្រាដែរណោះ?

ខនៈ បាទ! មាន

ភាស៊ីៈ អ្នកណាអ្នកកត់ត្រាលោកពូ?

ខនៈ សុទ្ធតែគ្នាគេហ្នឹងហើយ ។

យិនៈ ក្រោយមកពីណាយកទៅណាទេណោះ? មានពីណាអ្នកគ្រប់គ្រង?

ខនៈ ទេ! មិនដឹងពីណាទេ ។ ព្រោះអីខ្ញុំតាំងពីចប់សង្គ្រាមមក ខ្ញុំមិនដែលបានច្របូកច្របល់ជាមួយទេ

យិនៈ ១៧ មេសា គឺយើងចប់តែហ្នឹង?

ខនៈ បាទ! ចប់សព្វគ្រប់ហ្នឹង ។

យិនៈ មានដឹងថាប្រភេទអ្នកទោសថាមានកម្មាភិបាលគ្នាគេ មានយកទៅដាក់ហ្នឹងដែរទេ?

ខនៈ ជីមិនមាន ។

យិនៈ ថ្នាក់អីដែរ ថ្នាក់ស្រុក ថ្នាក់អីដែរ?

ខនៈ ថ្នាក់ស្រុកក៏មាន កងពលក៏មាន វរៈសេនាតូចក៏មាន ។

យិនៈ គេយកមកហ្នឹង យកមករបៀបម៉េច? មានចងដៃមកពីនាយ មានកាំភ្លើងខ្ញីអីមកទេ?

ខនៈ យកមកអត់មានកាំភ្លើងទេ មានតែដាក់ខ្នោះហើយស្រេចហ្នឹង ។

យិនៈ ហើយម៉េចដឹងថាជានៈកងពល ថ្នាក់វរៈសេនា?

ខនៈ យកមកដល់ហ្នឹងសួរទៅ ។

យិនៈ អាហ្នឹងចំពោះកម្មាភិបាលខ្មែរក្រហម?

ខនៈ បាទ!

យិនៈ ឯសម័យល្បើយសឹកទាហានលន់ ណុល ក៏មានអ្នកមានបណ្ដាសក្ដិទៅដែរណោះ?

ខនៈ មាន ។

យិនៈ ចុះមានពត៌មានមួយខ្ញុំចង់បញ្ជាក់បន្ថែម ថាមានកម្មាភិបាលមកពីហាណូយមានទៅជាប់នៅហ្នឹងដែរ?

ខនៈ មាន គគោកគជី មិនដឹងពីណាៗទេ ។ មនុស្សឲ្យតែជួបសុទ្ធតែស៊ី និយាយមួយម៉ាត់អញ្ចឹងហ្នឹង

ភាស៊ីៈ គុកហ្នឹងគេហៅគុកអីមួយទៀតលោកពូ?

ខនៈ ខ្ញុំអត់ស្គាល់ផង ខ្ញុំស្គាល់តែគុកកន្លែងខ្ញុំនៅហ្នឹងហ្នឹង ។

ភាសុីៈ មន្ទីរ ១៣ ហ្នឹងហ្នុងអ្ហេះ?

ខនៈ បាទ!

យិនៈ មានស្គាល់សាខាអីណាទៀតទេ?

ខនៈ អត់ ។

យិនៈ ចុះប្អូនថា ភ្នំប្រសិទ្ធិ មានមួយទៀតក្រែងសាខាហ្នឹងដែរអ្ហេះ?

ខនៈ ទេ! ខ្ញុំអត់ដឹងផង ។

យិនៈ ៩៩ អីអត់ដឹងទេ?

ខនៈ អត់ដឹងទេ ។

ភាសុីៈ ពូរស់នៅក្នុងមន្ទីរ១៣ ហ្នឹងពីឆ្នាំ ៧៣-៧៥ ហើយពូយល់ថា ឌុច ជាមនុស្សយ៉ាងម៉េចដែរ?

ខនៈ មិនដឹងយល់ថាម៉េចដែរ បើឃើញតែអញ្ចឹងទៅហើយ ។

ភាសុីៈ គាត់ជាមនុស្សស្លូត ឬជាមនុស្សកាច?

ខនៈ អាកប្បកិរិយាធម្មតា ដូចតែគេដូចតែឯងដែរ ។

យិនៈ មាននិយាយលេងសើចទេ?

ខនៈ មាននិយាយលេងសើច ។

យិនៈ មានដែលឃើញ ឌុច ហ្នឹងទាញកាំភ្លើងបាញ់ពីណាមួយផ្ទាល់ដៃទេ?

ខនៈ ឃើញ ចេះឃើញហើយ ប៉ុនមិនដឹងថាម៉េច ។

យិនៈ ទេ! និយាយថាឃើញមែនអ្ហេះ បាញ់តែប្រភេទមនុស្សយ៉ាងម៉េច របៀបយ៉ាងម៉េច បានគាត់បាញ់ផ្ទាល់ដៃ?

ខនៈ អ្នកទោសហ្នឹង ដូចខ្ញុំជម្រាបអញ្ចឹងខ្ញុំវាមិនទៅតាមដានទាន់ មិនដឹងជាទោសរបៀបម៉េច ដូចយើងសន្មតឡូវវាស្រួលវិនិច្ឆ័យណាស់ ដឹងថាទោសអញ្ចេះទោសអញ្ចុះ ។ កាលហ្នឹងមិនដឹងជាទោសស្អីៗផង ។

យិនៈ គាត់ចង់បាញ់ គឺបាញ់ហ្នុង?

ខនៈ បាទ! ពេញបាញ់ហ្នឹង បាញ់កុសមុខយើងហ្នុងណាស់ ឲ្យសែងយកទៅកប់ទៅ ។

ភាសុីៈ ពូធ្លាប់បានឃើញផ្ទាល់ប៉ុន្មានដងដែរពូ?

ខនៈ វាឃើញ វាចេះតែឃើញហើយ ប៉ុនវាមិនដឹងជាប៉ុន្មានៗ ។

ភាសុីៈ វាច្រើនដងអ្ហេះ?

ខនៈ បាទ! ហើយវាយូរឆ្នាំពេក ។

ភាសុីៈ បើត្រឹមម៉ាដងពីរដងអីពូចាំហើយ!

ខនៈ បាទ!

ឃិនៈ បើអញ្ចឹងបានន័យថា គាត់ហ្នឹងជាមនុស្សសាហាវហើយ បើចង់បាញ់ ក៏បាញ់ ចង់អីៗហ្នឹង?

ខនៈ ចុះបើមេធំត្រឹមគាត់ហ្នឹងហើយ ។

ឃិនៈ ពត៌មានពី អ៊ីន គាត់និយាយថា ឌុច ហ្នឹងគាត់ថា មើលអ្នែងយកអានោះទៅវៃ យកក្ដាម ។

ខនៈ បាទ! អញ្ចឹងមែនហ្នឹង ទៅលាក់ស្អីបើអញ្ចឹងមែន ។

ឃិនៈ អើ! ជួនកាលគ្នាកំពុងកាប់ចម្ការ អ្នែងយកបីនាក់ឈ្មោះនេះៗ យកទៅបាញ់ទៅ ។

ខនៈ សូម្បីកងការពារក៏ដោយ ឲ្យតែធ្វើខុសក៏គេដាក់គុកដែរ ។

ឃិនៈ ឈ្មោះ វឿន ហ្នឹងដែលថាឲ្យអ្នកទោសរត់រួចបីនាក់ប្អូនមានដឹងទេ?

ខនៈ ហ្នឹងហើយ ជីមិនដឹង ។

ឃិនៈ ហើយយកមកដាក់ច្រវ៉ាក់ទេ?

ខនៈ បាទ! ដាក់ច្រវ៉ាក់ ។

ឃិនៈ ហើយឲ្យកាប់ដី ហើយ ឌុច ហ្នឹងមានកាំភ្លើងអាការមួយនៅអង្រឹងចាំតែភ្ជង់ទេ ។

ខនៈ កុំតែចង់ ៧៩ ហ្នឹង អាវឿន ហ្នឹងក៏ងាប់ដែរ ទៅសួរវាម៉ាសារទៀតទៅ ក្រែងលោខ្ញុំចេះតែថា ។

ឃិនៈ បើអញ្ចឹងថាមានពួកម៉ាកណាលែង វឿន ហ្នឹង ដោះឡោះឲ្យ វឿន ហ្នឹងរត់ តែធាតុពិតបែបចប់ទេមើលទៅ?

ខនៈ វាចប់សង្គ្រាមទេ ចប់យើង៧៩ មៅមានធ្វើអីចេញ គឺសេចក្ដីប្រកាសលែងឲ្យប៉ះពាល់មនុស្សបាត់ហើយ ។

វ៉ាស៊ីៈ សេចក្ដីប្រកាសពីណាមៅដែរ?

ខនៈ ចុះគ្រាន់តែចប់សង្គ្រាម គឺគេប្រកាសអ្នកទោសឲ្យចេញពីគុកទាំងអស់អត់ឲ្យមាននៅសល់ទេ ។ បញ្ចេញទៅមូលដ្ឋានទាំងអស់ ដូចថាប្អូនឯងនៅភូមិណាបញ្ជូនទៅភូមិហ្នឹងទៅ ធ្វើតែឈ្មោះឲ្យទៅអាពេលចប់ ៧៩ ហ្នឹង ។

វ៉ាស៊ីៈ ចុះនៅពេលដែលគុកហ្នឹងគេរំសាយទៅ មានអ្នកទោសនៅហ្នឹងដែរ?

ខនៈ អ្នកទោស នៅពេលចប់សង្គ្រាមហ្នឹងមានអ្នកទោសគគោកគដីហ្នឹង ។

ឃិនៈ អត់ទាន់វៃចោលអស់ទេអញ្ចឹង?

ខនៈ អត់ទេ! អ្នកទោសនៅរាប់រយដដែល ។

ឃិនៈ អើ! អញ្ចឹងប្អូនឯងឃើញគេដោះលែងផ្ទាល់ទេ?

ខនៈ ជីមិនឃើញ ។

ឃិនៈ ដោះថ្ងៃប្រកាសហ្នឹង?

ខនៈ បាទ! គ្រាន់តែប្រកាសថ្ងៃ១៧ មេសា ហ្នឹងទទួលបានជ័យជំនះ យើងរំដោះបានទីក្រុងភ្នំពេញហើយ បានប្រហែលមាំថ្ងៃហើយ គេដោះលែងអ្នកទោសទាំងអស់ ។

យិនៈ អាហ្នឹងទាំងអ្នកទោសក្រោមដីអីដែរ?

ខនៈ បាទ! ត្រង់ណាក៏ដោយ ទោសប៉ុនណាក៏ដោយដោះទាំងអស់ ។

ក៉ាស៊ីៈ ឌុច ហ្នឹងជាអ្នកដោះផ្ទាល់ដៃជាមួយកងការពារ?

ខនៈ មិនមែន តាឌុច ហ្នឹងគាត់ជាអ្នកដោះទេ ឲ្យកូនចៅអ្នកដោះ ។ គាត់អ្នកបញ្ជាមោំ ។

យិនៈ មានបញ្ជាពីលើមោំ?

ខនៈ បាទ! គាត់ឃើញមោំប្រជុំហ្នឹងបាត់មោំ ស្រាប់តែទៅវិញនិយាយថា យើងទទួលបានជ័យជំនះហើយ យើងរៀបចំទៅនៅភ្នំពេញ ហើយត្រូវដោះលែងអ្នកទោសឲ្យអស់ ។

ឆ្លើយៈ អញ្ចឹងអត់មានយកអ្នកទោសហ្នឹងទៅភ្នំពេញទេ?

ខនៈ អត់មានយកទៅម្នាក់ទេ ។ កងការពារក៏វារើសយកតែអ្នកដែលមានសមាសភាពល្អ អ្នកដែលជាប់សមាសភាពគេរំសាយឲ្យទៅនៅកងចល័ត ។

យិនៈ ទេ! អាមួយចំណុចទៀតនេះ អ៊ីន និយាយថាមាំចំនួនគេឲ្យទៅនៅខេត្តពោធិ៍សាត់ ក្រែងដោះនឹងដោះបញ្ជូនទៅខេត្តពោធិ៍សាត់ទេអី?

ខនៈ បញ្ជូនកាលពីយើងមិនទាន់ចប់តើ ។

យិនៈ អត់មានបញ្ជូនកូនមេឃុំឈ្មោះ វឿន ឈ្មោះ វិនអី បញ្ជូនទៅពោធិ៍សាត់ ហើយ អ៊ីន ហ្នឹង គេសួរថា តើអ្ហែងចង់នៅក្នុងស្រុក ឬចង់នៅក្រៅស្រុក គាត់ថាចង់នៅឯរាប់រស់ក្នុងស្រុក ក៏បញ្ជូនទៅ ៩៩ នេះ ។

ខនៈ បាទ!

ក៉ាស៊ីៈ អញ្ចឹងពូអីមានសង្ឃឹមថាបានទៅភ្នំពេញដែរហើយ ប៉ុន្តែដោយសារមាន?

ខនៈ ចុះបើចប់សង្គ្រាមហើយ ថាតស៊ូដើម្បីទទួលលទ្ធផល ដល់ពេលចង់សង្គ្រាមទៅ គេថាឪពុកម្តាយយើងជាប់សមាសភាពអញ្ចេះ គឺចប់ត្រឹមហ្នឹងទៅ ។

យិនៈ ប៉ុនមានមាំចំនួនទៅតាមគាត់អ្ហែះ ទៅទួលស្លែងហ្នឹង?

ខនៈ ទៅច្រើន ។

ក៉ាស៊ីៈ ទៅដូចអ្នកធំៗ ដូចតា ចាន់ ប៉ុន មាស អីហ្នឹងទៅជាមួយគាត់ដែរអ្ហែះ?

ខនៈ ទៅទាំងអស់ ។ អត់តែតា ផល ទេ ។

យិនៈ តាផល បានគេវៃចោល ។

ខនៈ បាទ! គេវៃចោល ។

ក៉ាស៊ីៈ អ្នកណាអ្នកសម្លាប់ ផល ហ្នឹងពូ?

ខនៈ ទេ! កាលហ្នុងមិនដឹងពីណា មិនហួសបក្ខពួកគ្នាគេហ្នុងទេ ពូថាឲ្យទៅរៀនៗស្រាប់តែបាត់ខ្លួនរហូត ។

យិនៈ មិនមែនវៃនៅហ្នឹងទេអញ្ចឹង?

ខនៈ បាទ! មិនមែនវៃនៅគុកហ្នឹងទេ តែមិនដឹងវៃឯណា ថាបញ្ជូនទៅរៀន ។ សូម្បីកងការពារនៅហ្នឹងក៏ដោយ តែធ្វើខុស ពូថាបញ្ជូនទៅរៀនហើយ គឺចប់ហើយ ។ តែថាបញ្ជូនទៅរៀន កុំសង្ឃឹមនោះ មុខតែចប់ហើយអត់មានបានស្គាល់ស្រុកស្គាល់ទេសវិញទេ ។

យិនៈ អ្នកទោសដែលហូបចុកគេឲ្យហូបអីដែរ?

ខនៈ បបរ ។

យិនៈ ចុះដំឡូងដែលដាំបានច្រើនណាស់នោះ គេយកទៅឯណាទៅ?

ខនៈ អត់ ។

យិនៈ អត់ឲ្យហូបទេណោះ?

ខនៈ អត់ ។ កងការពារគេ ។

យិនៈ អូរកងការពារមានសិទ្ធអាចគាស់ហូបដែរណោះ?

ខនៈ អត់ទេ! គេគាស់លាយបាយឲ្យ ។ បាយមាំចានៗ ។

យិនៈ ហ្នឹងកងការពារមានសិទ្ធិហូបបាយ?

ខនៈ បាទ! ប៉ុនលាយដំឡូង ហើយបានតែមាំចានទេ ។

យិនៈ មិនថែមទេអញ្ចឹង?

ខនៈ អត់ទេ! ដួសរាបអញ្ចឹង គ្រប់នៅហ្នឹងស្រេច ។

យិនៈ សម្លរអីធម្មតា?

ខនៈ សម្លរ បើយើងទៅធ្វើការឆ្ងាយមៅទាន់ គេដួសទុកមាំចានៗ ដូចយើងនៅក្រុមធ្វើការរាល់ថ្ងៃ ។ តែមាំចាន ចប់ហើយ ។

យិនៈ ឯអ្នកទោសគឺបបររាវប៉ុកអញ្ចឹងហ្នង?

ខនៈ បាទ!

ភាស៊ីៈ ពូចុះបើសិនជាឥឡូវ ពូបានជួប ឌុច ពូស្គាល់គាត់ដែរ?

ខនៈ ទេ! ពិបាកថាណាស់ បែកយូរហើយតាំងពី ៧៩មកទល់ឥឡូវ ច្រើនណាស់ជិត៣០ឆ្នាំហើយ បើខ្ញុំបែកទៅទ្រើសជាងនេះបន្តិច ។

ភាស៊ីៈ ហើយចុះបើសិនជាពូរំឭកពីរឿងរ៉ាវកាលនៅមន្ទីរ១៣អីប្រហែលជាគាត់អាចនៅចាំបានទេណោះ

ខនៈ ពីណា តាឌុច អេះ?

ភាស៊ីៈ បាទ!

ខនៈ  គាត់អ្នកដឹកនាំហើយ គាត់និយាយមិនចាំបានម៉េច ។

រ៉ាស៊ីៈ  ពូយល់ថាគាត់ជាមនុស្សម្នាក់ដែលមានកំហុស ឬជាមនុស្សដែលស្អាតស្អំ?

ខនៈ  ពិបាកថាណាស់ប្អូនអ៊ើយ ។ វានៅក្នុងសង្គមមនុស្សវាអញ្ចឹងហើយ ។ ឥឡូវថាគាត់អ្នកស្អាតស្អំទៅ ក៏ថាមិនកើត បើគាត់ធ្វើនៅហ្នឹងហើយ ។

រ៉ាស៊ីៈ  ហើយពូជឿទេ ជឿពាក្យដែលគេថា ឌុច បានសម្លាប់មនុស្សរស់រាប់រយរាប់ពាន់នាក់?

ខនៈ  បើមិនជឿម៉េច បើខ្ញុំនៅជាមួយខ្ញុំឃើញ ដូចខ្ញុំថាអញ្ចឹងហើយ ។

រ៉ាស៊ីៈ  ហើយយើងសព្វថ្ងៃនេះ សូម្បីតែសម្លាប់ម្នាក់ ក៏យើងត្រូវតុលាការកាត់ទោសឲ្យជាប់គុកពី១៥ឆ្នាំ ឬ២០ឆ្នាំអីអញ្ចឹងដែរ ហើយចុះទំរាំគាត់បានសម្លាប់មនុស្សរស់រាប់រយរាប់ពាន់នាក់ បើសិនជាមានតុលាការទៅ តើពូយល់ថា ពូគិតក្នុងចិត្តខ្លួនឯងថា តុលាការនឹងកាត់ទោសគាត់របៀបយ៉ាងម៉េច?

ខនៈ  មិនដឹងម៉េចដែរ បើមិនដែលឃើញតុលាការផង ។

រ៉ាស៊ីៈ  ពូចង់ឲ្យតុលាការកាត់ទោសគាត់ទេ?

ខនៈ  ចេះតែចង់ហើយ ។

រ៉ាស៊ីៈ  ដើម្បីអីទៅ?

ខនៈ  ដើម្បីប្រជាជនយើង ។

រ៉ាស៊ីៈ  ដើម្បីភាពយុត្តិធម៌របស់ប្រជាជនអ្ហេះ?

ខនៈ  បាទ! ដើម្បីភាពយុត្តិធម៌របស់ប្រជាជន

រ៉ាស៊ីៈ  ហើយទោសកំហុសរបស់គាត់ គួរតែ ប្រសិនបើពូយល់ ពូស្មានមោ៉ ពូធ្លាប់ដឹងរឿងរ៉ាវរបស់គាត់ពីមុនមោ៉ គឺថាគាត់ហ្នឹងសមនឹងទទួលទោសរបៀបម៉េចដែរ?

ខនៈ  សមហ្នឹងកាត់ទោសប្រហារជីវិត ។

រ៉ាស៊ីៈ  ពូមានអីចង់បន្ថែមទៀតទេពូ?

ខនៈ  អត់មានអីទេ ។

ឃិនៈ  មានចង់បញ្ជាក់អីដែលចងចាំនៅក្នុងហ្នុងដែលមិនអាចបំភ្លេចបាន ចង់បញ្ជាក់ជូនក្នុងកាសែ្សតក្នុងពត៌មានទេ?

ខនៈ  ខ្ញុំអត់ទេ ។

ឃិនៈ  នែ ខ្ញុំចង់សួរមោ៉ចំណុចតូចទៀតទេណាស់?

ខនៈ  បាទ!

ឃិនៈ  រាល់ការសម្លាប់មនុស្សនៅកន្លែងហ្នឹង បើគ្មានបញ្ជាពី ឌុច តើអ្នកណាមានសិទ្ធិសម្លាប់អ្នកទោសបានទេ ។

ខនៈ អត់ទេ ។

ឃិនៈ អញ្ចឹងទាំងអស់ គិតសុំយោបល់ពី ឌុច ទាំងអស់?

ខនៈ បាទ!

ឃិនៈ ឬក៏មានបញ្ជាពី ឌុច អញ្ចឹងហ្នូង?

ខនៈ បាទ! ចេញបទបញ្ជាអញ្ចឹងហ្នូង ។

វ៉ាស៊ីៈ ឧបមាថា ឥឡូវ ផល សួរចម្លើយ ដល់សួរចម្លើយហើយត្រូវរាយការប្រាប់ ឌុច ថាអានេះ វាឆ្លើយថាអញ្ចេះៗ ។ ទុក ឬកម្ទេច អាហ្នឹងវាសួរអញ្ចឹង ។

ខនៈ មិនចាំបាច់សួរ គេមានសំណុំរឿងអញ្ចឹង យកសំណុំរឿងមកឲ្យ ។

ឃិនៈ អូរយកមកមើលសិន?

ខនៈ បាទ!

ឃិនៈ ហើយចុះ ឌុច មានចារថាម៉េចទេ? ថាលើសំណុំរឿង ប៊ិចអីដែរ?

ខនៈ សំណុំរឿងហ្នឹង ដល់យកទៅគឺចប់នៅហ្នឹងហ្នូង មិនដឹងទៅដល់ណាទៀត ស្រាប់តែឃើញមនុស្ស គេយកទៅកម្ទេចចោលអញ្ចឹងទៅណា ។

ឃិនៈ អញ្ចឹងបានន័យថាសួរហើយមិនអាចទុកទេអញ្ចឹង? សួរហើយសម្លាប់ៗអញ្ចឹងហ្នូង?

ខនៈ សួរហើយអ្នកដែលគេត្រូវសម្លាប់គឺសម្លាប់អញ្ចឹងហ្នូង ។

វ៉ាស៊ីៈ ប៉ុនតែយកសំណុំរឿងយកមកឲ្យ ឌុច ទេ?

ខនៈ បាទ!

វ៉ាស៊ីៈ ប៉ុន្តែ ឌុច ក៏ជាអ្នកដែលសួរចម្លើយផ្ទាល់ដែរ?

ខនៈ សួរ ។

ឃិនៈ តាមថានៈដូចប្អូនថាអញ្ចឹង? នរណាទាហានសក្ត៩ ឬអីអញ្ចឹងយកឲ្យ ឌុច ហើយអាហ្នឹង?

ខនៈ បាទ! អាហ្នឹងមេគេ ឌុច ហើយ ។

វ៉ាស៊ីៈ អរគុណពូរច្រើនណា៎! ។

ខនៈ បាទ!

ឃិនៈ ហើយអត់មានដែលផ្ទាល់ដៃអីមួយទេអ្ហេះ? មានដែលគេប្រើឲ្យដាក់ខ្លះទេ? ឬមួយបាញ់អ្នកទោសដែលរត់?

ខនៈ បាញ់អ្នកដែលរត់ណាស់ ។ ដល់គេរត់រួច គេមិនដាក់គុកខ្លួនយើង អញ្ចឹងទាល់តែបាញ់ ។

ឃិនៈ បាញ់ហ្នឹងឲ្យត្រូវ ឬខុស?

ខនៈ បាញ់ឲ្យត្រូវទៅណា ។

ឃិនៈ រួច វឿន កាលដែលគាត់ដោះបីនាក់នេះ គាត់បាញ់ឡើងលើទេ បាញ់៥គ្រាប់ឡើងលើ?

ខនៈ គ្មានទេ! វាដេកទេ ដេកនត់ហ្នឹង អ្នកទោសលួចកាត់ខ្សែនៅករ ហ្នឹងរត់ទៅ ។

ឃិនៈ ហើយថាអាពីរនាក់ហ្នឹងពួកម៉ាកគាត់ ប៉ុនស្គាល់តែឈ្មោះមួយ?

វ៉ាស៊ីៈ ប៉ុន ឌុច ដាក់ទារុណកម្មគាត់ដែរហ្នឹង!

ឃិនៈ ដាក់ទារុណកម្មនៅសល់តែខោខ្លីដាក់ច្រវ៉ាក់ករមែនទេ ។

ខនៈ ឲ្យតែមានរត់រួចមួយ គឺយើងត្រូវទទួលខ្លួនយើងអញ្ចឹង ។

វ៉ាស៊ីៈ អញ្ចឹងប្អូនអត់មានសិទ្ធិសួរចម្លើយអីទេណោះ?

ខនៈ អត់ដែលបានទេ ។

ឃិនៈ ប៉ុនឥឡូវ អ្នកទោសដែលសួរចម្លើយហើយ ហើយគេបញ្ជាថាប្អូនឯងយកបាញ់ចោល តើអាចហ៊ានយកទៅបាញ់ចោលទេ?

ខនៈ បើគេបញ្ជាហើយត្រូវតែបាញ់អញ្ចឹងហ្មង អត់បាញ់ទាល់តែគេធ្វើយើង ។

ឃិនៈ ប៉ុនគេអត់ដែលបញ្ជាឲ្យយើងតូចតាចអីយកទៅបាញ់ទេណោះ?

ខនៈ អត់ទេ! គេបញ្ជាតែគេអ្នកធំៗទេ ។

ឃិនៈ ប្អូនមានដែលបានឃើញគេសម្លាប់ដោយផ្ទាល់ភ្នែកទេ? បាញ់ដោយគ្រាប់កាំភ្លើង ចាក់នឹងទំពុះទុង ឬក៏វ៉ៃហ្នឹងបំពង់ឬស្សី?

ខនៈ អត់ដែលឃើញ ទៅដាក់ស្តែងឃើញគេ..........

ឃិនៈ អូរអាពេលសម្លាប់គេមិនឲ្យយើងដឹងទេណោះ?

ខនៈ មានសម្លាប់នៅក្នុងគុកនេះណា៎ គេយកទៅណាទៅណី ។

ឃិនៈ ចុះមានគេនិយាយថា ប្អូនឯងមានកុមារមួយ ម្នាក់ទាញចុងម្ខាង មួយទាញទៅអញ្ចេះៗ ចំពុះទុងចាក់ខ្ទាច់ៗ ។ តែម៉ាខ្ទាច់ទេ សម្លាប់មួតពីរបីនាក់អីណោះ ។ មានដែលដឹងអារឿងហ្នឹងទេ?

ខនៈ អត់ទេ ។ ខ្ញុំអត់ដែលទៅឃើញទេ ។

វ៉ាស៊ីៈ មិនដែលឃើញអាហ្នឹងទេណោះ?

ខនៈ បាទ!

វ៉ាស៊ីៈ ដូចពូគាត់ថាអញ្ចឹង គាត់ការពារ គឺនៅតែការពារទេ ។

ឃិនៈ ប៉ុន វឿន គាត់និយាយថា បាននាំ ឌិន នាំអីណាអ្នកទោសស្រាលៗទៅដើរចាប់ឈ្លូល ក្តាន់ អីម៉េច ទៅជួបកន្លែងវាសម្លាប់ហ្នឹង អាករណីហ្នឹងបែបមានរបស់គាត់មែន ។

ខនៈ អត់ទេ! អារឿងកន្លែងហ្នឹង ដើរទៅជួបដូចតែគ្នាហ្នឹង ។

ឃិនៈ ទៅដល់មិនដឹងគេវ៉ៃពីអង្កាល ឃើញតែខ្មោច ។

ខនៈ ឃើញតែខ្មោច ឃើញតែរណ្តៅ ។ អត់ខុះទេកន្លែងអញ្ចឹងៗ យើងមិនបានទៅធ្វើផ្ទាល់ដៃ ។

ភាសុីៈ បាទ! ទេគ្រាន់តែបានចំណុចសំខាន់គឺត្រង់ថា បានន័យថា ឌុច នៅត្រង់ហ្នឹងមែនៗ ឌុច បញ្ជា ឌុច សម្លាប់ ឌុច វ៉ៃអីៗ មានគ្នាពីរបីនាក់បាននិយាយអញ្ចឹងហើយ

---

## ករណី មន្ទីរសន្តិសុខ ១៣ (ម-១៣)

## សម្ភាសន៍ជាមួយៈ

## ១)ញ៉ឹក ពេញ អាយុ៤៧ឆ្នាំ រស់នៅ ភូមិថ្មគុប ឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ

## ២) ឆន លឹម អាយុ៣៨ឆ្នាំ ជាប្រធានភូមិថ្មគុប ឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ

## ៣) ម៉ិញ សាត អាយុ៤៥ឆ្នាំ ជាអធិការរងស្រុកថ្ពង ខេត្តកំពង់ស្ពឺ

## ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៣

### ផ្នែក "ក"

### សម្ភាសន៍ជាមួយ ញ៉ឹក ពេញ អាយុ៤៧ឆ្នាំ

យិនៈ អញ្ចឹងខ្ញុំ ហើយពូយើងធ្វើដំណើរចេញពីភូមិម៉ោដល់ទីនេះ ចម្ងាយប្រហែលប៉ុន្មាន?

ពេញៈ ប្រហែលជិតពីរគីឡូហើយៗ

យិនៈ ដំបូងខ្ញុំចង់ស្គាល់ឈ្មោះលោកពូ តើលោកពូឈ្មោះអីដែរ?

ពេញៈ ពេញ

យិនៈ ត្រកូលអីដែរ?

ពេញៈ ញ៉ឹកៗ

យិនៈ ញ៉ឹក ពេញ?

ពេញៈ បាទ!

យិនៈ អាយុប៉ុន្មានហើយ?

ពេញៈ អាយុ៤៧ឆ្នាំ

យិនៈ ពូមានស្រុកកំណើតនៅភូមិអីឃុំអី?

ពេញៈ ភូមិថ្មគុប ឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ

យិនៈ ពូមានប្រពន្ធឈ្មោះអីដែរ?

ពេញៈ សឿនៗ

យិនៈ មានកូនចៅប៉ុន្មាននាក់?

ពេញៈ ៨នាក់ ។

ឃិនៈ សម័យខ្មែរក្រហមលោកពូនៅឯណា?

ពេញៈ ខ្ញុំនៅធ្វើទំនប់៣មល្បា ។

ឃិនៈ លោកពូពេលនោះមានគ្រួសារហើយនៅ?

ពេញៈ នៅទេ ។ នៅជាយុទ្ធជន ។

ឃិនៈ លោកពូកន្លែងដែលយើងមកឈរនេះ គេហៅកន្លែងអី កន្លែងក្នុងព្រៃនេះ សម័យខ្មែរក្រហម គេហៅអីកន្លែងហ្នឹង?

ពេញៈ មន្ទីរ១៣ ។

ឃិនៈ មន្ទីរ១៣ ហ្នឹងអ្នកណាប្រធានកន្លែងហ្នឹង?

ពេញៈ ខ្ញុំអត់ដឹងដែរ ប៉ុនខ្ញុំស្គាល់តែមេគេ ឌុច តែហ្នឹង ។

ឃិនៈ ហើយ បន្ទាប់ពីតា ឌុច មកពីណា? អនុគេហ្នឹងណាស់?

ពេញៈ មិនដឹងពីណាទេ ។ មានឈ្មោះតា ចាន់ មួយទៀត ។

ឃិនៈ អញ្ចឹងស្គាល់ពីរនាក់?

ពេញៈ បាទ!

ឃិនៈ អញ្ចឹងក្រៅពីហ្នឹង ពួកឈ្លប ឬកងការពារកន្លែងហ្នឹងលោកពូមានស្គាល់ខ្លះទេ?

ពេញៈ អត់ទេ! អត់មានស្គាល់ទេ ។

ឃិនៈ អញ្ចឹងពូដឹងថាប្រវត្តកន្លែងហ្នឹង បុរំបុរាណគេហៅអី?

ពេញៈ គេហៅត្រពាំងប្រាប ។ នេះត្រពាំងនេះ ។

ឃិនៈ អញ្ចឹងលោកពូដឹងថាមន្ទីរ ១៣ហ្នឹងគេបង្កើតពីឆ្នាំណា? កសាងពីឆ្នាំណាដល់ឆ្នាំណា?

ពេញៈ ទើប ៧៥ ហ្នឹងដែរទេ ។

ឃិនៈ ៧៥ ហ្នឹងគេរំសាយចោលម៉េច?

ពេញៈ គេជ័យជំនះពីភ្នំពេញ ព្រោះអីភ្នំពេញគេដាច់មក ។

ឃិនៈ គេបង្កើតមុន ៧៥ ឬក្រោយ ៧៥ ?

ពេញៈ មុន ៧៥ ។

ឃិនៈ ហើយចុះដល់ឆ្នាំ៧៥ គេរំសាយមែនទេ?

ពេញៈ បាទ! គេរំសាយចេញ ។

ឃិនៈ ឥឡូវរណ្តៅដែលធំជាងគេដែលយើងមកដល់ហ្នឹង អាហ្នឹងរណ្តៅស្អីអាហ្នឹង?

ពេញៈ រណ្តៅគុក ។

ឃិនៈ អញ្ចឹងគុកវាដាក់ក្នុងដីហ្នឹង?

ពេញៈ បាទ! មនុស្សដាក់ក្នុងដីហ្នឹង ។

ឃិនៈ ដាក់របៀបម៉េចដែរលោកពូអាចនិយាយបន្តិចមើល៍?

ពេញៈ ខ្ញុំឮតែគេថាដែរទេ ខ្មោះអីនៅក្នុងហ្នឹង យកមនុស្សអីដាក់ក្នុងហ្នឹង ។

ឃិនៈ ចុះឆ្នាំណាដែលពូឃើញថាមានគេមៅគាស់មាសគាស់អីហ្នឹង?

ពេញៈ ៧៩ ម៉ោពីរត់យួនវិញ ។

ឃិនៈ អញ្ចឹងមានគេមៅជីកគាស់ឡើង ហើយឆ្អឹងគេយកទៅណា?

ពេញៈ ឆ្អឹងឃើញតែនៅក្នុងហ្នឹង ហើយខ្ចះរគាត់រគាយនៅហ្នឹង ។

ឃិនៈ ក្រៅរណ្តៅធំហ្នឹងមួយ តើលោកពូអាចស្មានមើល៍ថារណ្តៅទាំងអស់ដែលពូឃើញមានប៉ុន្មាន?

ពេញៈ ខ្ញុំអត់បានរាប់ដែរ ទាល់តែដើរមើល ។

ឃិនៈ អញ្ចឹងបានន័យថាពេលនេះយើងបានមៅឈរដល់កន្លែងហ្នឹងហើយ ត្រពាំងប្រាប ដែលគេហៅថាមន្ទីរ ១៣មាន ឌុច ជាប្រធាន ។ អញ្ចឹងពូដឹងថានៅទីនេះយើងអាចដឹងប្រវត្តិ ឌុច តើមានឮគេនិយាយថា ឌុច ហ្នឹងបានសម្លាប់មនុស្សផ្ទាល់ដៃ ធ្វើបាបយ៉ាងម៉េចៗអីដឹងទេ ។

ពេញៈ ខ្ញុំមិនបានដឹងដែរ ព្រោះខ្ញុំអត់បាននៅក្នុងហ្នឹងដែរ ។

ឃិនៈ អញ្ចឹងគ្រាន់តែពូហើយនឹងខ្ញុំបាននាំមកបង្ហាញថា ទីនេះជាត្រពាំងប្រាប ហើយជាមន្ទីរ១៣ របស់ ឌុច ដែលជាប្រធាន ។

ពេញៈ គាត់ជាមេគេ ។

ឃិនៈ ឌុច ហ្នឹងមុខមាត់ដូចម្តេច មានដែលឃើញទេ?

ពេញៈ គាត់ហ្នឹងរាងស្តើង ហើយទាបល្មមដែរទេ ហើយស ។

ឃិនៈ ហើយមុខមាត់អាចថាជា កាច ដែរទេ?

ពេញៈ មិនដឹងដែរទេ! ប៉ុនប្រហែលជាកាចហើយមើលទៅ ។

ឃិនៈ អញ្ចឹងពូអាចសន្និដ្ឋានមើលតាមពត៌មាន អ្នកដែលមៅស្លាប់នៅទីនេះប្រហែលប៉ុន្មាន?

ពេញៈ ខ្ញុំអត់ដឹងដែរ ។

ឃិនៈ អញ្ចឹងបានហើយ គ្រាន់ថាខ្ញុំសម្ភាសន៍នេះ គ្រាន់ថាពូបានជួយនាំខ្ញុំម៉ោដល់កន្លែងហ្នឹង ទីតាំងហ្នឹង អូរនេះគេហៅអូរស្អី?

ពេញៈ ស៊ឹងទេ ។

ឃិនៈ គេហៅស៊ឹងអី?

ពេញៈ ស៊ឹងក្រាំងពន្លៃ ។

ឃិនៈ អញ្ចឹងនៅជុំវិញត្រពាំងប្រាបហ្នឹងមានអូរមែនទេ ស៊ឹងពទ្ធ័ជុំវិញហ្នឹងប្តុយ៉ាងម៉េច?

ពេញៈ ស៊ឹងហ្នឹងធ្លាក់ទៅដល់អន្លង់ជ្រៃ ។

ឃិនៈ អញ្ចឹងរណ្តៅដែលដាក់អ្នកទោសនោះ នៅហែរតាមស៊ីងហ្នឹងមែនទេ?

ពេញៈ នៅត្រង់ហ្នឹង ត្រង់នោះទេ ។

ឃិនៈ បាទ! អរគុណហើយ ខ្ញុំចង់បញ្ជាក់ថាយើងបានទៅដល់ទីនេះ ហើយទៅទីនេះមានលោកអធិការរងស្រុកថ្ពងផង ហើយមានលោកមេភូមិថ្មគុបផង ។ អញ្ចឹងអរគុណពូដែលពូបានផ្តល់ពត៌មានអម្បាញ់មិញនេះណាស់!

ពេញៈ បាទ!

---

## កិច្ចសម្ភាសន៍ជាមួយមេភូមិថ្មគុបឈ្មោះ ឆន លីម

ឃិនៈ លោកពូឈ្មោះអីដែរ?

លីមៈ ខ្ញុំឈ្មោះ ឆន លីម ។

ឃិនៈ លោកមេភូមិអាយុប៉ុន្មានហើយ?

លីមៈ ៣៨ឆ្នាំ ។

ឃិនៈ លោកមេភូមិធ្វើមេភូមិតាំងពីឆ្នាំណាទៅ?

លីមៈ ខ្ញុំអនុប្រធានភូមិទេ គឺតាំងពីឆ្នាំ ៩៥ ទៅ ។

ឃិនៈ អូរយូរហើយ តាំងពី ៩៥ ទៅដល់២០០៣ វា៨ឆ្នាំហើយ ។ ឥឡូវលោកមេភូមិបាននាំខ្ញុំទៅដល់កន្លែងហ្នឹង តើកន្លែងហ្នឹងឈ្មោះអី?

លីមៈ ហ្នឹងគេហៅត្រពាំងប្រាប ឬហៅមន្ទីរ ១៣ របស់ ឌុច ។

ឃិនៈ មន្ទីរ ១៣ ហ្នឹងបង្កើតពីឆ្នាំណា លោកមេភូមិអាចដឹងទេ?

លីមៈ ខ្ញុំអត់សូវដឹងដែរ ។

ឃិនៈ ប៉ុនថាមន្ទីរ ១៣ បង្កើតនៅហ្នឹង លោកមេភូមិនៅឯណាសម័យហ្នឹង?

លីមៈ សម័យហ្នឹង ខ្ញុំនៅនេះណោះ នៅឯកៀនស្វាយណោះទេ ។

ឃិនៈ អញ្ចឹងឆ្នាំណាដែលលោកមេភូមិទៅដល់កន្លែងហ្នឹង?

លីមៈ ខ្ញុំទៅនៅស្រុកនេះត្រឹមឆ្នាំ ៨៩ ។

ឃិនៈ តាំងពីទៅពីនោះទៅ លោកមេភូមិមានដែលអញ្ជើញទៅទីនេះទេ?

លីមៈ ដែល ។

ឃិនៈ ទៅទីនេះមានការអីដែរ ចូលទៅទីកន្លែងនេះ?

លីមៈ ទៅដើរលេងតាមស៊ីង ។

ឃិនៈ អញ្ចឹងលោកបានឃើញអីខ្លះ ពេលដែលលោកចូលទៅទួលត្រពាំងប្រាបនេះ?

លីមៈ ខ្ញុំបានឃើញមានមន្ទីរគុក មានរណ្ដៅ មានក្បាលខ្មោចក្បាលអីដែរ ។

យិនៈ មានបន្សល់ជាឆ្អឹងខ្មោច មានរណ្ដៅ?

លីមៈ បាទ!

យិនៈ ហើយចុះគុកហ្នឹងលោកបានឃើញអីខ្លះ នៅកន្លែងគុកហ្នឹងមានឃើញនៅសេសសល់អីខ្លះ?

លីមៈ សេសសល់តែចំរឹងឈើគុកហ្នឹង វាដាក់គុកនៅក្នុងដីហ្នឹង ប៉ុនដីវាបាក់អស់ទៅឥឡូវហ្នឹង ។ លុបទៅវានៅសល់តែឈើចំរឹងឈើហ្នឹង ។

យិនៈ ហើយលោកមេភូមិបានឃើញផ្ទាល់ ហើយបានសួរអ្នកស្រុកថា មន្ទីរ១៣ ដែលមាន ឌុច ជាប្រធានគ្រប់គ្រងកន្លែងហ្នឹង ហើយពេលនេះលោកមេភូមិបាននាំក្រុមស្រាវជ្រាវខ្ញុំមកដល់ទីនេះ អញ្ចឹងបញ្ជាក់ថាកន្លែងនេះជាមន្ទីរ១៣ សម័យខ្មែរក្រហមពិតប្រាកដមែនណាស់ ។ សូមអរគុណ

លីមៈ បាទ!

---

**សម្ភាសន៍ជាមួយ ម៉ិញ សាត អាយុ៤៥ឆ្នាំ ជាអធិការរងស្រុកថ្ពង**

យិនៈ សុំទោសលោកអធិការរងដែលបានរួមដំណើរជាមួយក្រុមស្រាវជ្រាវឯកសារកម្ពុជាស្វែងរកការពិតនេះ លោកឈ្មោះអីដែរទាន?

សាតៈ ខ្ញុំបាទឈ្មោះ ម៉ិញ សាត ។

យិនៈ អាយុប៉ុន្មានហើយ?

សាតៈ អាយុ៤៥ឆ្នាំ ។

យិនៈ លោកធ្វើអធិការរង ធ្វើប៉ូលីសនៅស្រុកថ្ពងតាំងពីឆ្នាំណា?

សាតៈ ខ្ញុំបាទធ្វើការតាំងពីឆ្នាំ ១៩៨០ ។

យិនៈ អូរយូរហើយ ។ អញ្ចឹងលោកមកកាន់ស្រុកថ្ពងហ្នឹង តើលោកធ្លាប់បានតំបន់ហ្នឹង កន្លែងហ្នឹងដែលលោកមកជាមួយខ្ញុំកន្លែងហ្នឹង តើលោកធ្លាប់បានថាកន្លែងហ្នឹងជាកន្លែងស្អី លោកដឹងទេ?

សាតៈ បាទ! កន្លែងហ្នឹងគឺជាទីតាំងពីជំនាន់ប៉ុលពត គឺកន្លែងគុកដែលមានមេគ្រប់គ្រងឈ្មោះ ឌុច ។

យិនៈ មន្ទីរសន្តិសុខរបស់ពួកខ្មែរក្រហមហ្នឹង ហើយមេដឹកនាំគេឈ្មោះ ឌុច ។

សាតៈ បាទ!

យិនៈ លោកមានដឹងថាប្រភេទជនរងគ្រោះ ដែលយើងធ្លាប់ក្រោយមក តើអ្នកណា ហើយមានកំហុសអី ហើយនាំពីណាមកខ្លះយកមកដាក់កន្លែងហ្នឹង?

សាតៈ ខ្ញុំបាទបានស្រាវជ្រាវតាមរយៈប្រជាពលរដ្ឋ គឺគាត់បានរៀបរាប់ការណ៍គឺ សំបូរទៅដោយប្រជាពលរដ្ឋដែលជម្លៀសកាលពីឆ្នាំ ៧៥ ។

ឃិនៈ អ្នកបែកពីទីក្រុង ហើយក្រោយៗមៅទៀត?

សាតៈ ហើយបន្ទាប់មៅទៀតគឺថាយើងសំបូរទៅដោយខាងបូពារ ។

ឃិនៈ អូរខាងភូមិភាគបូព៌ា យកមកដាក់ត្រង់ហ្នឹងដែរ?

សាតៈ បាទ! យកមកដាក់ដែរ ។

ឃិនៈ អញ្ចឹងប្រភេទជនរងគ្រោះនេះ បើនិយាយថាពួកបូព៌ា គឺមិនមែនជាស៊ីវិលទេ ឬមួយក៏មានទព័មានអីដែរ?

សាតៈ បើតាមពិនិត្យទៅគឺថាមានទព័មានអីដែរ ។

ឃិនៈ បាទ! ហ្នឹងពួកបូព៌ា?

សាតៈ បាទ!

ឃិនៈ ឯសម័យ៧៥ អាហ្នឹងចំរុះ ហ្នឹងមានទាហានមានអីអញ្ចឹង ។ អញ្ចឹងលោកដឹងថា អ្នកដែលបានមៅជាប់នៅទីនេះ តើអាចថាក្តាប់ស្ថិតិ ឬផែនការ ដែលយើងមានដែលបានស្រាវជ្រាវឬចុះស្ថិតិមើល តើវាអាចស្លាប់អស់ប្រហែលប៉ុន្មាននាក់ទៀតនៅកន្លែងនេះ? យើងប៉ាន់ស្មានទៅ?

សាតៈ យើងប៉ាន់ស្មានទៅ នៅតំបន់នេះគឺមានរណ្តៅពីបីទៅបួនរណ្តៅដែរគឺនៅក្នុងតំបន់នេះ ។ អញ្ចឹងនៅក្នុងមារណ្តៅវាអាចថា ១០០ ចុះ ។

ឃិនៈ បាទ! វាច្រើនរណ្តៅ ហើយរណ្តៅធំៗណាស់ ។

សាតៈ បាទ!

ឃិនៈ ប្រភពព័ត៌មានដែលថាអ្នកទោស តើដាក់របៀបម៉េចដែរ វាមានជាអាគារ ជារោង ឬក៏វាដាក់របៀបម៉េច ជនរងគ្រោះដែលគ្នាជាប់ៗនៅកន្លែងហ្នឹង?

សាតៈ បាទ! តាមកាលដែលវាដាក់កន្លែងនោះ គឺវាច្រើនតែដាក់ខ្នោះជាប់ ហើយវាយកមកតម្រៀប

ឃិនៈ ក្នុងរណ្តៅ ក្នុងដីទៅវិញ?

សាតៈ ក្នុងរណ្តៅដី ។

ឃិនៈ បើអញ្ចឹងមានប្រក់ដំបូលអីដែរ?

សាតៈ រណ្តៅនោះគឺថាអត់ទេ រណ្តៅវាជីកគឺថាអត់មានដំបូលប្រក់ទេ ព្រោះថាទីតាំងដែលវាសម្រាកនោះ បានធ្វើដំបូលជរក ។

ឃិនៈ ចុះបើសិនណាជាមានភ្លៀងវិញ តើវាយ៉ាងម៉េចទៅ គ្នាជនរងគ្រោះហ្នឹងវាយ៉ាងម៉េចទៅវិញទៅ

សាតៈ ដល់ភ្លៀងមៅ វាតាមដំណើរអញ្ចឹង ទឹកវាអាចជន់តាំងពីលើមៅ គឺថាចូលក្នុងរណ្តៅហ្នឹង ។

ឃិនៈ បើអញ្ចឹងអ្នករងគ្រោះទីនេះ មកដល់ពេលនេះ តើលោកអាចស្រាវជ្រាវដឹងថាអ្នកណាអ្នកគ្រប់គ្រងកន្លែងហ្នឹងខ្លះ? មេៗ អនុប្រធានអី ឬពួកកងការពារអី តើលោកមានក្តាប់បានទេ អ្នកដែលនៅសេសសល់?

សាតៈ ខ្ញុំស្គាល់តែមេដឹកនាំ..............

ឃិនៈ អញ្ចឹងណោះ មិនបានក្តាប់បានអ្នកដែលនៅក្រោមៗទេណោះ?

សាតៈ ដូចឈ្លបអីហ្នឹង ។

ឃិនៈ ប៉ុនគ្រាន់ថាលោកបានជូនដំណើរក្រុមស្រាវជ្រាវរបស់យើងខ្ញុំមោដល់កន្លែងហ្នឹង យើងបានឃើញទាំងអស់គ្នាពិតប្រាកដហើយ យើងឃើញរណ្តៅនេះ រណ្តៅអម្បាញ់មិុញនេះ យើងថតនេះ យើងឃើញថារណ្តៅនេះមិនមែនតិចទេ យើងមើលទំហំរណ្តៅ មាត់រណ្តៅនេះប្រហែលជា១០ម៉ែត្រជងក្បាលលើ សមាមាត្រវាខាងលើនេះ គេហៅថាបរិមាត្រវានេះប្រហែលជា ១០ម៉ែត្រ បើអញ្ចឹងក្នុងហ្នឹងមិនមែនធម្មតាទេ ដាក់ច្រើនណាស់ ។ នៅមានរណ្តៅដែលបងប្អូនឃើញនៅតាមនេះ ហើយបើពូ អុីន គាត់និយាយថា គ្រាន់តែដាក់តាមហ្នឹងហើយទឹកវាឡើងចូលងាប់អស់ច្រើនណាស់ ។ អញ្ចឹងយើងខ្ញុំអរគុណលោកអធិការវងហើយ ដែលលោកបានជូនដំណើរក្រុមស្រាវជ្រាវយើងខ្ញុំបានមោឃើញទីនេះ ហើយយើងខ្ញុំបន្តពិនិត្យតទៅទៀតថាធនណាស់ធ្វើម៉េចដើម្បីឲ្យឃើញបង្គោលឃើញអីជាក់ស្តែងថែមទៀត ។ នៅចុងបញ្ចប់នេះខ្ញុំចង់សួរយោបល់លោកចុងក្រោយដែរ លោកចាប់អារម្មណ៍ថាម៉េចដែរដែលលោកមោឃើញអញ្ចឹងតើលោកមានអារម្មណ៍យ៉ាងណាដែរ?

សាតៈ ខ្ញុំបាទមោដល់តំបន់នេះ ឃើញទិដ្ឋភាពរួម កាលយើងសម័យនោះមានអារម្មណ៍ ឲ្យតែថត គឺនឹកដល់បងប្អូនយើងដែលពលីជីវិតដោយទទួលទារុណកម្មយ៉ាងខ្លោចផ្សារ នឹងព្រៃផ្សៃបំផុត ហើយនៅពេលនេះដែរ ដោយក្រុមស្រាវជ្រាវពីភ្នំពេញ ខ្ញុំអបអរសាទរដោយបាននាំកម្លាំងជូនមកដល់តំបន់នេះ ដើម្បីពិនិត្យជាក់ស្តែង ។

ឃិនៈ បាទ! អរគុណហើយ ប្រសិនបើយើងមើលថាអ្នកដែលមោដល់អស់ទាំងហ្នឹង អ្នកមោជាប់ហ្នឹងហើយបើមើលសភាពអញ្ចឹង ប៉ុស្សំអញ្ចឹងគ្មានភាពសង្ឃឹមទេ អស់សង្ឃឹម មិនអាចថារស់ទេ ។ គ្រាន់តែទិសដៅតំបន់ ក៏មិនដឹងរត់ទៅណាផង ។ អានេះវាជាភាពមួយខ្លោចផ្សារណាស់ហើយសម្ងាត់ ។ ចំណែកឯប្រជារាស្ត្រអីគ្មាននរណាមានសិទ្ធិមោដល់អស់ទាំងនេះទេ មិនអញ្ចឹង នេះយើងមើលណាស់ មិនតិចគីឡូទេ ជាងម៉ាគីឡូមោពីភូមិមោ ព្រៃសុទ្ធ ។ អញ្ចឹងវាស្ងាត់ណាស់ហើយយើងអស់សង្ឃឹមហើយ ។ សូមអរគុណ! ចុងក្រោយខ្ញុំសុំសួរម៉ាម៉ាត់ទៀតអំពីបញ្ហាការបង្កើតតុលាការអន្តរជាតិ បូករួមហ្នឹងរាជរដ្ឋាភិបាលយើងដែលកាត់ទោសមេដឹកនាំខ្មែរក្រហមក្នុងទិសដៅខាងមុខដ៏ខ្លីនេះ តើលោកយល់យ៉ាងម៉េចដែរអំពីបញ្ហានេះ?

សាតៈ បាទ! ខ្ញុំចំពោះការបង្កើតតុលាការដើម្បីវិនិច្ឆ័យចំពោះពួកមេដឹកនាំប្រល័យពូជសាសន៍ គឺថាយើងខ្ញុំមានជំនឿជឿជាក់ និងសង្ឃឹមលើផ្លូវច្បាប់ដើម្បីវែកមុខ និងបកអាក្រាត្រវិនិច្ឆ័យទៅលើពួកក្បត់ដែលប្រល័យពូជសាសន៍នៅលើទឹកដីប្រទេសកម្ពុជា ។

ឃិនៈ បាទ! សុំអរគុណ ។

សាតៈ បាទ!

ឃិនៈ រន្ធុំហ្នឹងវាហួសហ្នឹងទៀត ។ វានៅសល់តែដើមឈើដែលក្រាញជាប់ ។ អញ្ចឹងបង្គោលនៅដែរ អូរបើអញ្ចឹងមែនៗ តាមរបាយការណ៍ដែលពូ អ៊ុន និយាយហ្នឹងគឺត្រឹមត្រូវរបស់គាត់ថា រណ្ដៅដែលដាក់គុកហ្នឹងគឺនៅហែរតាមមាត់ទឹកហ្នឹង ដល់ទឹកឡើងអញ្ចឹងវាចូលលិចអ្នកទោសងាប់អស់ច្រើនណាស់ ។ ដល់ហើយទៅមានតាណាទេ ឈ្មោះ តាស៊ុំ ឬតាអីស្ងួរពត៌មានទីតា អ៊ុន ហ្នឹងថា តាឯង តើ ឌុច មានរាយការណ៍អីទេ ដែលស្លាប់អ្នកទោសអស់ច្រើនណាស់ហ្នឹង ហើយ អ៊ុន នោះអត់ហ៊ានរាយការណ៍ទេ ខ្លាចគេសម្លាប់គាត់ ។ ហ៊ានរាយម៉េច បើ តាឌុច វាធំជាងគេ ។

អូរបង្គោល! មកដាក់អែមាត់ទឹកហ្នឹងហ្នុងណោះ ។ បង្គោលនៅ បង្គោលគ្រាក់នៅមែន អត់ទៅណាទេ ។ អូរនេះបង្គោលដែរ ។ បើអញ្ចឹងរន្ធុំនេះសុទ្ធតែនេះទាំងអស់

សាតៈ សុទ្ធកន្លែងដាក់ខ្នោះហើយនេះ ។

ឃិនៈ ត្រូវហើយៗ តាអ៊ុន គាត់និយាយត្រូវថាទឹកឡើងមោ៉ចូលងាប់អស់ ។ នេះមិនមែននៅៗគេមោ៉ជីកលេងទេគឺសុទ្ធតែបង្គោលគ្រាក់របស់វា ។

សាតៈ ឫស្សីទាំងនេះទើបតែដុះក្រោយទេ ។

ឃិនៈ បាទ! យើងឃើញនេះទើបតែដុះក្រោយទេ ពីមុនវាត្រាយអស់ហើយ ។

---

**ករណី មន្ទីរសន្តិសុខ ១៣ (ម-១៣)**

**សម្ភាសន៍ជាមួយ កែវ កាន់ ហៅ យក្ស អាយុ៦០ឆ្នាំ**

**ភេទប្រុស រស់នៅភូមិស្នួល ឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ**

**ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៣**

**ផ្នែក "ក"**

ឃិនៈ អ៊ំឈ្មោះអី?

កាន់ៈ កាន់ ។

ឃិនៈ ត្រកូលអី ជីតាឈ្មោះអី?

កាន់ៈ មាស ។ ឪពុកខ្ញុំឈ្មោះ កែវ ។

ឃិនៈ កែវ កាន់ អេ្ហះ?

កាន់៖ បាទ!

ឃិន៖ អាយុប៉ុន្មានហើយ?

កាន់៖ អាយុ៦០

ឃិន៖ អ៊ំមានកូនចៅប៉ុន្មាននាក់?

កាន់៖ មានបីនាក់ ។

ឃិន៖ ហើយអ៊ំរស់នៅសព្វថ្ងៃក្នុងភូមិឃុំអីដែរ?

កាន់៖ ភូមិស្នួល ឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ។

ឃិន៖ ហើយក្នុងសម័យខ្មែរក្រហមពីឆ្នាំ១៩៧០-៧៥ គេឲ្យអ៊ំធ្វើអីដែរ?

កាន់៖ ធ្វើស្រែរហូត ។

ឃិន៖ ចុះពី៧៥-៧៩?

កាន់៖ អត់មានធ្វើអីដែរ ។ ធ្វើស្រែរហូត ។

ឃិន៖ អញ្ចឹងអ៊ំស្គាល់ប្រធានភូមិឈ្មោះអី រដ្ឋអំណាចភូមិ សហករណ៍ឈ្មោះអី?

កាន់៖ សេន ។

ឃិន៖ ហ្នឹងគាត់ស្អី រដ្ឋអំណាចភូមិអ្ហេះ?

កាន់៖ បាទ!

ឃិន៖ ហើយចុះប្រធានសហករណ៍?

កាន់៖ ប្រធានសហករណ៍ណាអញ្ចេះ អត់មានផង ។

ឃិន៖ ចុះមានហូបបាយរួមអីត្រង់ណាទេ?

កាន់៖ រួមឯណោះ ។

ឆ្លើយ៖ គាត់និយាយពីបច្ចុប្បន្ននេះទេ ឈ្មោះ សេន ហ្នឹងប្រធានភូមិឥឡូវនេះទេ ។

ឃិន៖ ចង់និយាយពីប្រធានភូមិសម័យខ្មែរក្រហមមិនមែននិយាយឥឡូវទេណាស់អ៊ំមានចាំទេរដ្ឋអំណាចភូមិសម័យខ្មែរក្រហម?

កាន់៖ ដូចអត់ទេ! មានឈ្មោះខ្មោច តាព្រីង នោះដែរ ។

ឃិន៖ ចុះមេឃុំសម័យខ្មែរក្រហម សម័យដែលអ៊ំធ្វើការ?

កាន់៖ គាត់ស្លាប់អស់ហើយ ។

ឃិន៖ ឈ្មោះអី?

កាន់៖ តាគង់ ។

ឃិន៖ មុនដំបូងខ្ញុំបានសួរអ៊ំថា សម័យនោះគេចាត់តាំងឲ្យអ៊ំធ្វើអី?

កាន់៖ ខាងធ្វើឈ្លប ។

ឃិនៈ មាននាទីអីដែរ?

កាន់ៈ នាទីគឺគ្រាន់តែដើរពិនិត្យភូមិនាយអាយប៉ុណ្ណោះឯង ។

ឃិនៈ ដើរគ្រប់ភូមិអញ្ចឹង?

កាន់ៈ បាទ!

ឃិនៈ ដើរពិនិត្យមើលរបៀបម៉េច?

កាន់ៈ ពិនិត្យរកមើលតើមាននរណាលួចលាក់អី បានស៊ីស៊ីបន្តិចបន្តួចអីហ្នឹង ។

ឃិនៈ ចុះបើពិនិត្យឃើញថាមានគេដាំបាយហូប ឬគេលួចស្រូវអង្ករ លួចបេះផ្លែឈើហូប តើអ៊ំធ្វើម៉េចដែរ រាយការណ៍ ឬក៏ចាប់?

កាន់ៈ អត់ទេ ខ្ញុំអត់ហ៊ានចាប់នឹងគេទេ ។

ឃិនៈ ឧបមាថាឥឡូវមោដល់ក្រោមផ្ទះហ្នឹង ដឹងថាផ្ទះហ្នឹងគេជុំនុំគ្នា គេហូបបាយ តើអ៊ំទៅធ្វើម៉េចដែរ

កាន់ៈ អត់មានធ្វើម៉េចទេ គេហូបៗទៅ គេម៉េចៗទៅ ។

ឃិនៈ គ្រាន់តែឲ្យដឹង?

កាន់ៈ បាទ!

ឃិនៈ ចុះមានរាយការណ៍ប្រាប់ទៅប្រធានឈ្លបអីទេ?

កាន់ៈ ជីមិនរាយ ។

ឃិនៈ ហើយក្រោយមោយ៉ាងម៉េចដែរ អ្នកហ្នឹងដែលរាយការណ៍ហ្នឹង មានគេដែលមោចាប់អីទេ?

កាន់ៈ អត់ទេ! អត់ដែលមានចាប់ទេ ។

ឃិនៈ មានដែលចាប់អ្នកណាដែលដាំបាយហូបអីទេ?

កាន់ៈ អត់ទេ!

ឃិនៈ ចុះអ៊ំមានប្រសាសន៍ថាអ៊ំជាអនុប្រធានកងឈ្លបឃុំ?

កាន់ៈ បាទ!

ឃិនៈ អញ្ចឹងប្រធានលើអ៊ំមានឈ្មោះអី?

កាន់ៈ ឃុត ។

ឃិនៈ ទៅណាហើយគាត់ហ្នឹង?

កាន់ៈ នៅ ។

ឃិនៈ ឃិន ឃុត អ្ហែះ?

កាន់ៈ បាទ!

ឃិនៈ ឃិន ឃុត រាល់ថ្ងៃនៅឯណា?

កាន់ៈ នៅជើងណោះ ។

ឃិនៈ ភូមិអី?

កាន់ៈ ភូមិគោក ។

ឃិនៈ ឃុំអមលាំងដែរ?

កាន់ៈ បាទ! ឃុំអមលាំង

ឃិនៈ ហ្នឹងប្រធានរបស់អឹណោះ?

កាន់ៈ បាទ!

វ៉ាស៊ីៈ ឃុត ហ្នឹងកាចទេអី?

ឃិនៈ គាត់កាចទេ ដែលសម្លាប់មនុស្សផ្ទាល់ដៃទេ ឃិន ឃុត ហ្នុង?

កាន់ៈ ខ្ញុំមិនសូវដឹងគេដែរ បើគាត់ឲ្យខ្ញុំដើរធ្វើការគេណោះ ។ ត្រង់សម្លាប់មិនសម្លាប់មិនដឹងដែរ ។

ឃិនៈ មានដែល ឃុត ហ្នឹងបញ្ជូឲ្យអឹទៅចាប់ចងអ្នកណាគេមួយដែលខុស?

កាន់ៈ អត់ទេ ។

ឃិនៈ ចុះក្រៅពីអឹដូចថា កងឈ្លបដទៃទៀតមានដែលទៅចងទៅចាប់អ្នកណាៗទេ ដែលឃុត បញ្ជា?

កាន់ៈ អត់ទេ ។

ឃិនៈ អញ្ចឹងឈ្លបហ្នឹងមាននាទីដើរក្តាប់សភាពការណ៍ ដល់ឃើញគេខុសអត់មានដែលចាប់ចងអីទេ?

កាន់ៈ អត់ទេៗ ។

ឃិនៈ អត់ដែលមានចាប់បញ្ជូនទៅម-១៣ កន្លែងតា ឌុច អីទេណោះ?

កាន់ៈ អត់ទេខ្ញុំ!

ឃិនៈ ទេនិយាយពី ឃុត អ្វាស់មានដែលទេ?

កាន់ៈ ដឹងអីគេ អានេះតាមបុគ្គលគេខ្ញុំអត់ដឹងទេ ។

ឃិនៈ ចុះក្រែងធ្វើជាមួយគ្នា យើងអាចឃើញអ្វាស់ ឃើញដាក់ស្តែងអ្វាស់?

កាន់ៈ អត់ទេ!

ឃិនៈ អញ្ចឹងប្រជាជនខុសឆ្គងនៅកន្លែងនេះ បើមិនអាច បើសិនជាមានការខុសឆ្គងចាប់បញ្ជូនទៅសន្តិសុខដែរឬក៏អី?

កាន់ៈ អត់ទេ! អត់ដែលចាប់បញ្ជូនពីណាទៅទេខ្ញុំ ។

ឃិនៈ ទេ និយាយពី តាឃុត អីហ្នឹងណាស់?

កាន់ៈ ទេ បុគ្គលគេខ្ញុំមិនសូវដឹងដែរ ។

ឃិនៈ ចុះឮថានៅនេះមានសិទ្ធិសម្លាប់ផ្ទាល់មិនបាច់ចាប់បញ្ជូនទៅមន្ទីរសន្តិសុខ មានទេ មានដែលមានទេ? មានដែលឃើញគា ឃុត ហ្នឹងយកពីណាទៅសម្លាប់អីទេ?

កាន់ៈ ទេ! ឃើញគេយកដែរ ប៉ុនខ្ញុំអត់ដែលសម្លាប់គេទេ ។

ឃិនៈ អត់ដែលសោះណោះ?

កាន់ៈ ទេ!

ឃិនៈ ហើយក្រោយមកដល់ឆ្នាំណាដែលអ៊ំឈប់ អ៊ំធ្វើដល់ឆ្នាំណា?

កាន់ៈ អត់ទេ! ខ្ញុំធ្វើបានមួយឆ្នាំ ។

ឃិនៈ ធ្វើឆ្នាំណា?

កាន់ៈ ធ្វើឆ្នាំខ្មែរក្រហម ។

ឃិនៈ ក្នុងអំឡុងឆ្នាំណា ក្រោយ៧៥ ឬមុន ៧៥?

កាន់ៈ ទេ! ខ្ញុំមិនដឹងចិតប៉ុន្មានៗទេ ។

ឃិនៈ មកទល់ ៧៩ ហ្នឹងធ្វើបានតែមួយឆ្នាំទេ?

កាន់ៈ បាទ! ធ្វើបានមួយឆ្នាំ ។

ឃិនៈ ហើយមូលហេតុអីបានជាឈប់ គេឲ្យឈប់ ឬសុំគេឈប់?

កាន់ៈ អត់ទេ! ខ្ញុំសុំគេឈប់ហ្នឹង ។

ឃិនៈ ហើយក្រោយពីធ្វើឈ្លបមក មានធ្វើអីទៀតទេ?

កាន់ៈ អត់ទេ! ធ្វើស្រែរហូត ។

ឃិនៈ ចុះថាអ៊ំមានធ្លាប់ធ្វើជាប្រធានឃុំអមលាំងហ្នឹង តើមានដែលធ្វើទេ?

កាន់ៈ អត់ដែលធ្វើទេខ្ញុំ ។

ឃិនៈ ចុះប្រធានឃុំហ្នុងឈ្មោះអី?

កាន់ៈ ប្រធានឃុំឈ្មោះ តាព្រីង ។

វ៉ាស៊ីៈ អ៊ំថាអ៊ំលាឈប់ តើទៅលាពីណាគេ?

កាន់ៈ សុំ អាឃុត

វ៉ាស៊ីៈ ចុះមេលើតា ឃុត ហ្នឹងមួយទៀតឈ្មោះអីដែរ?

កាន់ៈ មាន តាប៊ុន ហ្នឹងហើយ ។

ឃិនៈ ប៊ុន ហ្នឹងមិនមែនគណៈឃុំទេ ជាប្រធានសន្តិសុខលើ ឃុត ហ្នឹងទៀត?

កាន់ៈ បាទ!

ឃិនៈ ប៊ុន ឬប៉ុន?

កាន់ៈ ប៊ុន ។

វ៉ាស៊ីៈ ធ្វើការនៅឯណាពួកហ្នុង?

កាន់ៈ .......................

ឃិនៈ នៅឯណា?

កាន់៖ ស្រុក ។ ប៉ុនទៅគីរីរម្យអីណាណោះ ។

យិន៖ គាត់នៅរស់ដែរអញ្ចឹង ប៉ុន ហ្នឹង?

កាន់៖ បាទ!

យិន៖ នៅគីរីរម្យ?

កាន់៖ បាទ!

យិន៖ អញ្ចឹងអ៊ំមិនដែលបានធ្វើមេឃុំទេ?

កាន់៖ អត់ទេ ។

យិន៖ ហើយក៏មិនដែលបានសម្លាប់មនុស្សដោយផ្ទាល់ដៃដែរ?

កាន់៖ អត់ទេ ។

យិន៖ ក្រែងអ៊ំលាក់លៀមអីទេ?

កាន់៖ អត់ទេ! ខ្ញុំអត់មានលាក់លៀមអីទេ ។

យិន៖ អត់មាន យុត នឹងដើរបញ្ជាថាអ្នែងយកមនុស្សនេះទៅសម្លាប់ចោលត្រង់ណោះៗអី កន្លែងណាអីៗ?

កាន់៖ អត់ទេ ។

យិន៖ ចុះបញ្ហា យុត ហើយនឹង ប៉ុន មានដែលចេញចូលទៅមន្ទីរ ម-១៣ ឌុច គ្រប់គ្រងដែរទេ?

កាន់៖ ដឹងអី ខ្ញុំមិនសូវដឹងដែរ ។ ព្រោះគេធំជាងខ្ញុំ

យិន៖ អញ្ចឹងប្រជារាស្ត្រដែលគ្រប់គ្រង អត់ដែលឃើញ ប៉ុន ហើយហ្នឹងយុត ហ្នឹងបញ្ជូនទៅហ្នុង អត់ដែលទេ?

កាន់៖ អត់ដែលទេ ។

យិន៖ អញ្ចឹងមានន័យថានៅក្នុងទីនេះ អត់មានសម្លាប់មនុស្សទេអញ្ចឹងនៅក្នុងឃុំអមលាំងនេះ?

កាន់៖ បាទ! អត់ទេ ។

យិន៖ ចុះអ្នកដែលជាប់នៅក្នុងម-១៣ហ្នឹង គើយកពីណាមៅ?

កាន់៖ ដឹងអី មិនដឹងជាយកពីណាបើខ្ញុំអត់ដែលជួបគេដែរ ។

យិន៖ អញ្ចឹងរឿងបញ្ហា លោកអ៊ំអត់ដែលស្គាល់ ឌុច សោះ ហើយក៏អត់ស្គាល់កន្លែងហ្នុងដែរ?

កាន់៖ អត់ទេ ។

យិន៖ មិនដែលចេញចូលហើយក៏មិនដែលស្គាល់ ឌុច ដែរ?

កាន់៖ បាទ!

យិន៖ អូរ! បើអញ្ចឹងជាសេនាជនមែន ជាកងឈ្លបមែន ឈ្លបរបស់ឃុំ មិនមែនជាកងឈ្លបបុរីរបស់ម-១៣ហ្នឹងទេ?

កាន់៖ មិនមែនទេ ។

ឃិន៖ អញ្ចឹងពិតប្រាកដហើយអ៊ំណោះ?

កាន់៖ បាទ! ច្បាស់ណាស់ ។

ឃិន៖ អញ្ចឹងសូមថ្លែងអំណរគុណដែលបានសំដែងការស្មោះត្រង់ប្រាប់ដល់ក្រុមស្រាវជ្រាវយើងខ្ញុំ ។ ខ្ញុំគ្រាន់តែសួរថា ក្រែងលោកអ៊ំមានស្គាល់ ឌុច ថា ឌុច ហ្នឹងមកនៅទីនេះ ។ ធម្មតាពីហ្នុងមក ទីនេះវាជិតគ្នាដែរ ក្រែងលោក ឌុច ហ្នឹងមករើសទព័រើសឈ្លបអីចេញពីកន្លែងហ្នឹងណា?

កាន់៖ អត់ទេ ។

ឃិន៖ ខ្ញុំសុំសួរបន្តិចមុនហ្នឹងបញ្ចប់ អ៊ំដែលធ្វើកងឈ្លបហ្នឹងមានដែលហាត់រៀនបច្ចេកទេសនៅឯណា ហាត់រៀនទព័ របៀបប្រយុទ្ធអីនៅឯណា?

កាន់៖ អត់ទេ! ឆ្ងាយណាស់ ខ្ញុំទៅរហូតដល់គិរីរម្យណោះ ។

ឃិន៖ ហើយពីណាជាមេមកពីណា កម្មាភិបាលមកពីណាជាអ្នកបង្ហាត់អ៊ំហ្នឹងឈ្មោះអី មកពីណា?

កាន់៖ ឈ្មោះអីនៅកុមាររមាសនេះ ។

ឃិន៖ នៅក្នុងស្រុកយើងដែរហ្នឹង មិនមែនអ្នកមកពីហាណូយអីទេ?

កាន់៖ មិនមែនទេ ។

ឃិន៖ ចុះអ៊ំស្គាល់ វឿន ទេ? វឿន កងការពារម-១៣ហ្នឹង?

កាន់៖ អត់ស្គាល់ទេខ្ញុំ ។

ឃិន៖ វឿន នៅកុមាររមាសហ្នឹងអ្ហាស! វឿន ដែលធ្លាប់ធ្វើសន្តិសុខនៅម-១៣ហ្នឹងមានដែលស្គាល់ទេ?

កាន់៖ អត់ស្គាល់ទេ ។

ឃិន៖ ចុះមានស្គាល់មួយទៀត ជនរងគ្រោះឈ្មោះ ស៊ិន នៅថ្នល់បំបែកដែលធ្លាប់ជាប់នៅម-១៣ដែរ?

កាន់៖ អត់ស្គាល់ទេ ។

ឃិន៖ អញ្ចឹងចុងក្រោយ តាមការសម្ដែងរបស់អ៊ំ សូមថ្លែងអំណរគុណណាស់ ដូចគ្មានអីសួរវែងឆ្ងាយតទៅទៀតទេ ព្រោះអ៊ំបាននិយាយថាអ៊ំមិនដែលបានធ្លាប់សម្លាប់មនុស្សដោយផ្ទាល់ដៃ ហើយក៏មិនដែលបានស្គាល់ម-១៣ ហើយស្គាល់ ឌុច ហ្នឹងដែរទេ ។ ប៉ុន្តែមានតួនាទីជាអនុប្រធានកងឈ្លបឃុំអមលាំង ប៉ុន្តែធ្វើបានតែមួយឆ្នាំហើយក៏ឈប់ទៅ ។ អញ្ចឹងអរគុណហើយណាអ៊ំណា?

កាន់៖ បាទ!

---

**ករណី មន្ទីរសន្តិសុខ (ម.១៣)**
**សម្ភាសន៍ជាមួយឈ្មោះ អ៊ុម វ៉ន ភេទប្រុស អាយុ៤២ឆ្នាំ**
**បច្ចុប្បន្នរស់នៅភូមិក្រាំង ឃុំប្រាំបីមុម ស្រុកថ្ពង ខេត្តកំពង់ស្ពឺ**
**ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៣**

Epñk{k}

ភាស៊ី: អត់ទោសបងឈ្មោះអីដែរ?

វ៉ន: បាទ! ខ្ញុំឈ្មោះ អ៊ុម វ៉ន ។

ភាស៊ី: មានឈ្មោះហៅក្រៅទេបង?

វ៉ន: នៅភូមិក្រាំង ឃុំប្រាំបីមុម ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ។

ភាស៊ី: ចុះបងមានឈ្មោះហៅក្រៅទេបង?

វ៉ន: ឈ្មោះវ៉នអញ្ចឹងម៉ង ។

ភាស៊ី: ឈ្មោះវ៉នអញ្ចឹងម៉ង?

វ៉ន: បាទ! កាលពីឆ្នាំ១៩៧២ មន្ទីរឃុំឃាំងឈ្មោះមន្ទីរ(ម.១៣)នៅស្រុកឃុំ នៅខាងជើងស្រុកឃុំ ខ្ញុំផ្ទាល់ម៉ង ហើយឌុចហ្នឹងនៅកាន់ក្តាប់នៅនរគបាលហ្នឹងម៉ង ។

ភាស៊ី: មុនដំបូងនៅនរគបាល?

វ៉ន: បាទ! នរគបាល ហើយបានដឹកនាំយើងខ្ញុំហ្នឹងឲ្យទៅ កាលហ្នឹងយើងខ្ញុំនៅកុមារឡើយនៅតូច ហើយឲ្យទៅកាន់នៅគុកនៅយាម ហៅថាកងការពារអ្នកទោស កងការពារគុក តែបទបញ្ជាពីគាត់ម៉ោមិនដឹងពីណាម៉ោទេ ខ្ញុំដឹងពីគាត់ហ្នឹងម៉ង គាត់ផ្ទាល់ហ្នឹងម៉ង ។

ភាស៊ី: គាត់ជាអ្នកដាក់បញ្ជាម៉ោផ្ទាល់?

វ៉ន: បាទ!

ភាស៊ី: ហើយម៉េចទៀតទៅបង?

វ៉ន: ហើយធ្វើការកន្លែងគេហ្នឹងមានតែការវ៉ៃ ការដេរ ការដុំ ការកាប់សម្លាប់ហ្នឹងម៉ងអត់មានដែនការអីទេ សួរចម្លើយអ្នកល្អក៏ដោយអ្នកអាក្រក់ក៏ដោយ មិនដឹងថាល្អទេ ត្រូវការគាត់វ៉ៃៗ ត្រូវការគាត់សម្លាប់ៗម៉ង ។

ភាស៊ី: អញ្ចឹងឪពុកបងឈ្មោះអីដែរបង?

វ៉ន: ឈ្មោះ អ៊ុម អេង ។

ភាស៊ី: អ៊ុម អេង ។ ចុះម្តាយ?

វ៉ន: ម្ដាយឈ្មោះ គីញ កែវ ។

វ៉ាស៊ី: គាត់ទាំងពីរនាក់នៅរស់ទេសព្វថ្ងៃ?

វ៉ន: រស់ ។

វ៉ាស៊ី: ឪពុកអាយុប៉ុន្មានហើយឪពុកបង ខ្ទង់ប៉ុន្មាន?

វ៉ន: ខ្ទង់៦៨ ។

វ៉ាស៊ី: ចុះម្ដាយ?

វ៉ន: ម្ដាយ៦៧ ។

វ៉ាស៊ី: គាត់រស់នៅជាមួយបងរាល់ថ្ងៃ?

វ៉ន: បាទ! អត់ទេគាត់នៅស្រុក ។

វ៉ាស៊ី: អូ! នៅប្រាំបីមុមណោះអេ្ហះ?

វ៉ន: បាទ!

វ៉ាស៊ី: អញ្ចឹងបងរាល់ថ្ងៃនៅនេះនៅស្រុកខាងប្រពន្ធទេអេ្ហះ?

វ៉ន: បាទ!

វ៉ាស៊ី: អញ្ចឹងនៅក្នុងភូមិហ្នឹងដែរណោះ?

វ៉ន: បាទ!

វ៉ាស៊ី: អញ្ចឹងខ្ញុំចង់ដឹងពីជីវិតបងកាលនៅកុមារ មុននឹងចូលនៅក្នុងមន្ទីរ(ម.១៣)របស់ឌុចហ្នឹង តើបងនៅធ្វើអីដែរ?

វ៉ន: ខ្ញុំនៅធ្វើស្រែជាមួយម្ដាយ ។

វ៉ាស៊ី: កាលហ្នុងបងអាយុប៉ុន្មាន?

វ៉ន: កាលហ្នុងខ្ញុំអាយុ១៣ឆ្នាំ ។

វ៉ាស៊ី: ហើយពេលណា បងមាននៅចាំថ្ងៃខែទេ ពេលណាដែលឌុចហ្នឹងហៅបងទៅ?

វ៉ន: ខ្ញុំមិនចាំដែរកាលហ្នុង ។

វ៉ាស៊ី: ពេលដែលឌុចម៉ោហៅទៅ តើជួបបងឬក៏ជួបឪពុកម្ដាយបង?

វ៉ន: ជួបឪពុកម្ដាយខ្ញុំផ្ទាល់ ។

វ៉ាស៊ី: ហើយបងមានដឹងថាឌុចហ្នឹងបាននិយាយអីខ្លះជាមួយឪពុកម្ដាយបងទេ?

វ៉ន: អត់មាននិយាយអីទេ និយាយថាទៅកន្លែងខ្ញុំហ្នឹងធ្វើការស្រួលទេ ខ្ញុំមិនដឹងថាទៅកន្លែងគុក កាលឪពុកម្ដាយខ្ញុំផ្ទាល់ក៏អត់ដឹងដែរ ។

វ៉ាស៊ី: អញ្ចឹងពេលហ្នឹង គាត់ហៅទៅហ្នឹង តើបងឡើងម៉ោពីស្រែក្នុងសម្លៀកបំពាក់យ៉ាងម៉េច ឬក៏បងនៅផ្ទះ?

វនៈ ខ្ញុំនៅផ្ទះ ។

ភាសុីៈ នៅផ្ទះទេអ្ហេះ?

វនៈ បាទ!

ភាសុីៈ ចុះបងមានអារម្មណ៍ម៉េចដែរពេលដែលឌុចយកបងទៅអញ្ជឹង?

វនៈ ទៅដល់ខ្ញុំមានអារម្មណ៍រំភើបដែរ ខ្ញុំថាអើកន្លែងគេហ៊ឺកហ៊ឺន គេហៅកន្លែងហ៊ឺកហ៊ឺន បាទមន្ទីរ ហ៊ឺកហ៊ឺន ហើយអស់រយៈបីបួនខែម៉ោបានខ្ញុំដឹងថាកន្លែងនេះជាកន្លែងឃាដករ ។

ភាសុីៈ ពេលដែលបងទៅជាមួយឌុចចេញពីផ្ទះទៅហ្នឹង គាត់យកអីម៉ោយកបងទៅ?

វនៈ ដើរ ។

ភាសុីៈ ដើរទេអ្ហេះ?

វនៈ បាទ!

ភាសុីៈ ចុះគាត់នាំបងទៅម្នាក់ឯងទេ?

វនៈ បាទ! ក្នុងភូមិខ្ញុំហ្នឹងគេម៉ោប៉ុន្មាននាក់ដែរក្មេងៗ តែគ្រាន់ខ្ញុំហ្នឹងម៉ោក្រោយគេ ។

ភាសុីៈ បងចាំខែទេបងទៅហ្នឹង?

វនៈ មិនចាំទេ តែបើខ្ញុំស្គាល់ឆ្នាំ....

ភាសុីៈ ឆ្នាំ៧២ហ្នឹង?

វនៈ បាទ!

ភាសុីៈ ពេលដែលបណ្តើរបងទៅឌុចមាននិយាយអីជាមួយបងទេ?

វនៈ អត់មាននិយាយអីទេ និយាយតែថាទៅកន្លែងហ្នុងខំធ្វើការទៅក្មួយ ប្អូនអញ្ជឹងទៅណា ។

ភាសុីៈ ឌុចហ្នឹងមានសន្យាជាមួយបងថា ឲ្យខំធ្វើការទៅនឹងផ្តល់អីម៉ោបងវិញទេ?

វនៈ មានចឹងដែរ ផ្តល់ដូចឧបករណ៍ខ្វះខាតឪពុកម្តាយចឹង បាទខំឲ្យ ពេលចន្លោះម៉ោវិញអត់ ។

ភាសុីៈ ពេលដែលបងទៅធ្វើការនៅហ្នុងគេមានឲ្យបងម៉ោលេងផ្ទះទេ?

វនៈ មិនទេ ២ឆ្នាំក្រោយម៉ោបានគេឲ្យម៉ោលេង ឲ្យម៉ោលេងបានពីរថ្ងៃ បីថ្ងៃដែរ?

ឃិនៈ អញ្ជឹង៧២ ៧៣?

វនៈ ៧៤បានគេឲ្យម៉ោលេងផ្ទះ ។

ឃិនៈ ៧៤បានម៉ោលេងផ្ទះបានម្តង?

វនៈ បាទ! ជិតបែកភ្នំពេញយើង ។

ភាសុីៈ ពេលដែលបងទៅហ្នឹងគេមានឲ្យបងកាន់កាំភ្លើងឬក៏ឲ្យបងធ្វើអីដែរ?

វនៈ អត់ដែលទេ នៅខាង អើថាកន្លែងចម្ការគេអ្ហាស នៅដេកចាំចម្ការក្រោយកន្លែងគុកហ្នឹង ។

ឃិនៈ អញ្ជឹង?

វន៖ បាទ!

ឃិន៖ ចម្ការអី?

វន៖ ចម្ការដាំដំឡូងដាំអីពួកអ្នកទោសដាំហ្នឹងអ្នាស ។

ឃិន៖ មិនមែនជាសន្តិសុខមានកាំភ្លើងមានអីទេបីង?

វន៖ មិនមែនទេ ។

ភាស៊ី៖ គិតទៅឆ្នាំណាបានបងក្លាយខ្លួនជាអ្នកការពារមន្ទីរហ្នឹង?

វន៖ កាន់ក្តាប់ការពារមន្ទីរហ្នឹងផ្ទាល់ម៉ង?

ភាស៊ី៖ បាទ!

វន៖ អត់ដែល ។

ឃិន៖ អត់ឲ្យមានកាំភ្លើងយាមអ្នកទោស ការពារអ្នកទោសអីទេបីង?

វន៖ អត់ដែលទេ ដែលទៅម៉ាងរបស់ក្នុងហ្នឹង ការងារមានតែមើលគោហើយនឹងដាំឡូងហ្នឹងម៉ង ។

ភាស៊ី៖ ចុះបងមានដែលឃើញអ្នកទោសអី ពួកកូនចៅឌុចហ្នឹងនាំអ្នកទោសទៅធ្វើទារុណកម្ម?

វន៖ ដែល ។

ភាស៊ី៖ ដែលឃើញដែរ?

វន៖ បាទ! ឃើញផ្ទាល់ម៉ង ។

ភាស៊ី៖ ឃើញយ៉ាងម៉េចខ្លះទៅបងរៀបរាប់មើល?

វន៖ ឃើញជួនកាលវាវ៉ៃអញ្ចឹងទៅ ជួនកាលបាញ់ចោលអញ្ចឹងទៅ ជួនកាលអារកអីចឹងទៅ ។

ឃិន៖ ច្រើនទេ?

វន៖ ជួនកាលម៉ារណ្តៅមាន១០នាក់ ២០នាក់អី ៥០-៦០នាក់ក៏មានដែរ ។

ភាស៊ី៖ ពេលដែលបងឃើញហ្នឹងបងកំពុងធ្វើអីដែរ?

វន៖ ពេលខ្ញុំឃើញខ្ញុំនៅចម្ការនៅមើលគោ គោម៉ានឹមពីរនឹម ។

ឃិន៖ ចម្ងាយប៉ុន្មាន?

វន៖ ចម្ងាយប្រហែល អើយើង៥០ម៉ែត្រ ២០ម៉ែត្រពីគ្នាហ្នឹង ។

ឃិន៖ អញ្ចឹងមានពួសម្រែកទេ?

វន៖ ស្រែកពេញតែហ្នឹង ហើយក្នុងម៉ាអ្នកធ្វើការនៅហ្នឹងវាអត់ចេះលាក់ទេ វាថាកងការពារហើយ ថាពួកគេហ្នឹងហើយណាអត់លាក់ទេ បើក្រៅពីហ្នឹងអត់ឲ្យចូល អត់ឲ្យដឹងទេ កាលណាចូលដឹងពុ អ្នកនោះក៏អត់រួចខ្លួនដែរ ។

ភាស៊ី៖ អញ្ចឹងបងមិនមែនការពារមន្ទីរហ្នឹង ប៉ុន្តែបងស្ថិតក្នុងកងការពារដែរ?

វន៖ បាទ!

ភាស៊ីៈ បងមានដឹងទេតើកងការពារនៅក្នុងមន្ទីរហ្នឹងតើគេចែកជាប៉ុន្មានផ្នែកដែរ?

វនៈ ចែកចេញវាមេៗនោះវាច្រើនណាស់ អ្នកប្រធានកាន់ក្តាប់ហ្នឹងអ្នួស ។

ភាស៊ីៈ បាទ!

វនៈ មើល តាណែន ហើយតាជឿន ហើយតាទិត្យ ។

ភាស៊ីៈ ចុះប្រធានបងឈ្មោះអីដែរ?

វនៈ ប្រធានខ្ញុំហ្នឹងតាទិត្យ ។

ភាស៊ីៈ តាទិត្យហ្នឹងគាត់ជាមនុស្សយ៉ាងម៉េច?

វនៈ អរ! តាណែនទេ តាណែន តាណែនហ្នឹងនៅក្នុងភូមិត្រពាំងគ្រោកដូចខ្ញុំដែរ ជាមួយខ្ញុំដែរ ។

ភាស៊ីៈ គាត់ជាមនុស្សយ៉ាងម៉េចដែរមើលទៅ?

វនៈ គាត់ហ្នឹងរាងខ្មៅ ខ្ពស់ដែរ សម្បុរសណ្តែកបាយ ។

ឃិនៈ ប៉ុន្តែប្រធានគេឲ្យមានសិទ្ធិមានកាំភ្លើងទេ?

វនៈ មាន, បន្ទាប់ពីអ្នកធំហ្នឹងម៉ោហើយ សេនាដៃស្តាំរបស់តាឌុចហ្នឹងផ្ទាល់ម៉ង ។

ភាស៊ីៈ រួចបងនៅកូនចៅគាត់?

វនៈ បាទ!

ភាស៊ីៈ អញ្ចឹងគាត់តាណែនហ្នឹងគាត់គ្រប់គ្រងប៉ុន្មានក្រុមដែរ?

វនៈ អើម៉ាផ្នែកៗវាផ្នែក ថាយើងឥឡូវហៅ“ខ”មួយ “ខ”ពីរចឹងណា ។

ភាស៊ីៈ បាទ! គាត់នៅ“ខ”ទីប៉ុន្មាន?

វនៈ ខ្ញុំនៅ“ខ”ទីពីរ តាណែន ។

ភាស៊ីៈ “ខ”ទីមួយកិច្ចការអីខ្លះទៅ?

វនៈ កិច្ចយប់ព្រលប់អីខ្ញុំអត់ដឹងអីទេ តែគ្រាន់តែក្រៅអំពីសួរចម្លើយហ្នឹងម៉ង...... ។

ភាស៊ីៈ នៅក្នុង“ខ”មួយៗដែលក្រោមការគ្រប់គ្រងរបស់តាណាងអ្ហេះ?

វនៈ តាណែន ។

ភាស៊ីៈ តាណែន ។ មានក្រុមសួរចម្លើយទេ?

វនៈ មាន ។

ភាស៊ីៈ មានដែរ ។ ចុះក្រុមសម្លាប់?

វនៈ ក្រុមសម្លាប់មាននៅហ្នឹងដូចគ្នាគេចឹង ៣នាក់អ្នកសម្លាប់ហ្នឹង ហ្នឹងអ្នកសម្លាប់ផ្ទាល់ហ្នឹងមេគេៗ ហ្នឹង ប្រធាន“ក” ប្រធាន“ខ”ហ្នឹង ។

ភាស៊ីៈ ចុះរាល់ថ្ងៃតាណែនហ្នឹងនៅរស់ទេបង មានដឹងទេ?

វនៈ មិនដឹងទេ ។

វ៉ាស៊ីៈ ហើយនៅពេលដែលបងឃើញគេសម្លាប់មនុស្សចឹងអារម្មណ៍បងរបៀបម៉េចដែរ?

វ៉នៈ ខ្លាច គ្រាន់តែឃើញខ្លាច ។

យ៉ិនៈ ខ្លាចដែរ?

វ៉នៈ បាទ! ហើយខ្លាចម្លោះធ្វើមិនឲ្យខុស ខ្លាចក្រែងលោធ្លងដល់ខ្លួន ។

យ៉ិនៈ អញ្ចឹងនិយាយរឿងចម្ការហ្នឹង លោកប្អូនគ្រាន់តែមើលថែអ្នកទោសធ្វើ ឬក៏ធ្វើផ្ទាល់ខ្លួនឯង?

វ៉នៈ នៅកាន់កន្លែងអ្នកទោសហ្នឹងធ្វើដែរហ្នឹង ។

យ៉ិនៈ យើងក៏ធ្វើអ្នកទោសក៏ធ្វើ?

វ៉នៈ បាទ! តែគ្រាន់អត់កាំភ្លើងអត់អីដែរ អ្នកទោសស្រាលអ្ហាស គេហៅថាស្រាលទោស ។

យ៉ិនៈ អរ! អ្នកទោសស្រាលទោស?

វ៉នៈ បាទ! ស្រាលទោសគេឲ្យម៉ោធ្វើចម្ការហ្នឹង ។

យ៉ិនៈ អត់មានដាក់ខ្នោះដាក់អីទេអ្នកទោសហ្នឹង?

វ៉នៈ អត់ទេ យប់ឡើងបានគេដាក់ យប់ឡើងបានគេចូលក្នុងមន្ទីរហ្នឹងទៅ ។

យ៉ិនៈ អញ្ចឹងខ្ញុំចង់សួរបញ្ជាក់បន្តិច ទាំងសន្តិសុខដែលមានកាំភ្លើងទាំងអស់ប្រហែលប៉ុន្មាន ដែលកូនចៅតាឌុចអ្ហាស សរុបមើលទៅប្រហែលប៉ុន្មាននាក់ក្នុងមន្ទីរ១៣ហ្នឹង ប៉ាន់ស្មានមើល?

វ៉នៈ ទេបងវាច្រើនដែរ មិនលើសអីតែ១០នាក់ហ្នឹងទេ ។

យ៉ិនៈ អ្ហា! មន្ទីរមួយហ្នឹងតែ១០នាក់ហ្នឹង?

វ៉នៈ បាទ!

យ៉ិនៈ ទេម៉ាក្រុមទាំងអស់ម៉ាកូនចៅតាឌុចហ្នឹងអ្ហាស?

វ៉នៈ បាទ! មានតែប៉ុនហ្នឹងទេក្នុងម៉ាមន្ទីរហ្នឹង ១០ទៅ១៥នាក់តែប៉ុនហ្នឹងទេ ។

យ៉ិនៈ ហើយហ្នឹងដែលសាច់សុទ្ធដែលកាន់កាំភ្លើងប៉ុន្មាននាក់?

វ៉នៈ ដែលសាច់សុទ្ធកាន់កាំភ្លើងការពារហ្នឹងតែ៨នាក់ទេ ។

យ៉ិនៈ ហើយជាអ្នកវៃប្រហែលប៉ុន្មាននាក់ ដែលវៃផ្ទាល់?

វ៉នៈ អារឿងវៃកាប់ខ្ញុំអត់ដឹងទេ ឃើញបាទ អ្នកណាក៏វៃៗ ឲ្យតែមេការគេហ្នឹងម៉ង បាទប្រធាន ។

វ៉ាស៊ីៈ ហើយក្រោយពេលដែលនាំបងទៅហ្នឹង តើឌុចដែលម៉ោជួបបងញឹកញាប់ទេ?

វ៉នៈ តាឌុចនៅហ្នឹងម៉ងបាទ ។

វ៉ាស៊ីៈ បងឃើញគ្រប់សកម្មភាពរបស់ឌុចម៉ង?

វ៉នៈ បាទ! នៅពាល់ថ្ងៃហ្នឹងម៉ង ។

វ៉ាស៊ីៈ គាត់ខស្សាហ៍ស្លៀកពាក់ខោអាវអីជាងគេ?

វ៉នៈ ស្លៀកពាក់ច្រើនខោអាវពណ៌ស្វៃ ។

ភាស៊ីៈ បងដឹងថាឈ្មោះក្រៅឌុចហ្នឹងឈ្មោះក្រៅឈ្មោះអីគេ?

វ៉នៈ មិនដឹង ។

ភាស៊ីៈ ឮតែគេហៅតាឌុចៗអញ្ចឹងម៉ងអ្ហេះ?

វ៉នៈ បាទ!

ភាស៊ីៈ ហើយបងមើលទៅតើគាត់មានបញ្ហាអីដល់បងខ្លះទេ ដាក់បញ្ហាឲ្យបងធ្វើអី បញ្ហាថាម៉េចៗទេ?

វ៉នៈ មានដែរតែគ្រាន់តែក្រៅពីចម្ការហើយនឹងគោហ្នឹង ហើយនឹងហាមឃាត់កុំឲ្យផ្សព្វផ្សាយដំណឹងរឿងការប់ចាក់អីហ្នឹងចេញក្រៅ ។

ភាស៊ីៈ បងដែលឃើញតាឌុចហ្នឹងធ្វើទារុណកម្មអ្នកទោសទេ?

វ៉នៈ ដែល ។

ឃិនៈ ដែលឃើញផ្ទាល់អ្ហេះ?

វ៉នៈ ស្ទូរចម្លើយបាទ ។

ឃិនៈ ស្ទូរចម្លើយអ្ហេះ?

វ៉នៈ បាទ! ស្ទូរចម្លើយ ពេលស្ទូរចម្លើយ ពេលចង់ គាត់ថាពេលចង់បាញ់ៗ ។

ឃិនៈ បាញ់ម៉េច បាញ់ផ្ទាល់ខ្លួនគាត់ ឬក៏បាញ់គេ?

វ៉នៈ បាញ់ផ្ទាល់ខ្លួនគាត់ គាត់ខ្ជិលទៅតំណាងគាត់ហ្នឹងបាញ់ទៅ ។

ឃិនៈ ប៉ុនបាញ់ផ្ទាល់ដៃក៏មានដែរ?

វ៉នៈ បាញ់ផ្ទាល់ដៃក៏មាន វៃផ្ទាល់ដៃក៏មាន ។

ភាស៊ីៈ វិធីគាត់ធ្វើទារុណកម្មតើធ្វើយ៉ាងម៉េចទៅ?

vn³ Kat;sYrcemøIy Kat;ehABIKukhñwgeTA eTAnMaeTAkEnøgKat; eTApÞHKat;Gðas pÞHCuMvijhñwg kEnøgKat;hñwgsYrcemøIy sYrBIenHBIenaHGBa©wgeTA ehIyGñkeTaseqøIyfaGt;GIGt;k¾év: Edr év:eCrGBa©wgeTA Tat;Fak;GBa©wgeTA manGnøÚgmanG‘ÍcwgeTA dMbgEdk dMbgb£sSIG‘Ícwg eTA.

ភាស៊ីៈ ហើយអ្នកទោសច្រើនម៉ោពីខាងណាទៅបង?

វ៉នៈ ទេមិនដឹងជាម៉ោពីខាងណាខាងណីទេបង បើម៉ោពីណាក៏ចូលហ្នឹងៗ

ឃិនៈ របៀបជាអ្នកទោស របៀបស្លៀកពាក់ជាទាហានអីទេ?

វ៉នៈ បាទ! ខ្លះមានជាទាហាន ខ្លះក៏ខោអាវខ្មៅចឹងទៅ ខោអាវយើងធម្មតាចឹងទៅ ពណ៌ចំរុះ ។

ឃិនៈ មានស្រ្តីអីទេ ស្រ្តី កុមារអីទេ?

វ៉នៈ មានទាំងតូចទាំងធំ ទាំងចាស់ទាំងក្មេង ។

ភាស៊ីៈ ហើយសកម្មភាពរបស់ឌុចរាល់ថ្ងៃហ្នឹងបងគិតថា សកម្មភាពរបស់គាត់អប់រំមនុស្សឲ្យតែល្អឬក៏ជាសកម្មភាបយ៉ាងម៉េច?

វ៉នៈ ខ្ញុំថាអត់ល្អទេ បើសិនជាគាត់នៅបន្តទៅទៀតច្បាស់ជាអស់ហើយខ្មែរយើង ពីនោះម៉ោដល់ប៉ុនណោះអស់ប៉ុនណោះទៅហើយ ។

រ៉ាស៊ីៈ កាលហ្នឹងគាត់មានអាយុប៉ុន្មានដែរតាឌុចនៅហ្នឹង?

វ៉នៈ ខ្ញុំអ្ហេះ?

រ៉ាស៊ីៈ អត់ទេឌុចអ្ហាស?

វ៉នៈ មិនដឹងប៉ុន្មានទេ ខ្ទង់អន្ទឹកហើយ វៃ៣០លើសអីហ្នឹងហើយ ។

យិនៈ ហើយប្អូនអាយុប៉ុន្មានដែរពេលហ្នឹង?

វ៉នៈ ខ្ញុំ១២ ១៣ឆ្នាំ ។

យិនៈ ១៣ឆ្នាំ?

រ៉ាស៊ីៈ ហើយពេលដែលបងឃើញការសួរចម្លើយរបស់ឌុច ហើយនឹងការដាក់បញ្ហារបស់ឌុច បងមាននឹកឃើញពីការដែលឌុចទៅនាំបងម៉ោទេ?

វ៉នៈ ដែល ។

រ៉ាស៊ីៈ បងអាចប្រៀបធៀបមើល តើពេលដែលឌុចទៅនាំបងម៉ោឌុចប្រើសំដីអីខ្លះ ពេលដែលសកម្មភាពរបស់ឌុចនៅក្នុងមន្ទីររបស់គាត់កាន់កាប់ហ្នឹង គាត់និយាយសំដីអីខ្លះ?

វ៉នៈ ដែលនឹកឃើញចឹងដែរ នឹកឃើញថាកាលទៅយកម៉ោអាចនិយាយជាមួយឪពុកម្ដាយខ្ញុំនិយាយស្រួល និយាយថាខំបំពាក់បំប៉នស្មារដើម្បីឲ្យចេះដឹង ដល់ផ្ទុយស្រឡះម៉ោផ្ទាល់វិញ ឃើញការកាប់សម្លាប់អញ្ចឹង ខុសផ្ទុយស្រឡះពីគាត់ដឹកនាំខ្ញុំម៉ោវិញ ។

រ៉ាស៊ីៈ ហើយបងមានអារម្មណ៍យ៉ាងម៉េចដែរ ចង់រត់ចេញដែរឬក៏ម៉េច?

វ៉នៈ ចង់ដែរតែគេមិនឲ្យចេញម៉ង ចូលក៏មិនឲ្យចូល ចេញក៏មិនឲ្យចេញ ។

រ៉ាស៊ីៈ អញ្ចឹងនៅពេលដែលបងគ្រប់គ្រងអ្នកទោសដែលធ្វើការងារហ្នឹងអ្ហាស?

វ៉នៈ បាទ!

រ៉ាស៊ីៈ បងមានដែលទាក់, មានគ្នាប៉ុន្មាននាក់កាលហ្នឹង?

វ៉នៈ គ្នាខ្ញុំ៥ ៦នាក់ក្មេងៗ ។

រ៉ាស៊ីៈ ហើយគ្នាបងមានដែលធ្វើ វៃដុំអីអ្នកទោសធ្វើកិច្ចការហ្នឹងទេ?

វ៉នៈ មិនហ៊ានទេ អត់ហ៊ានទេ តែគ្រាន់តែបទបញ្ជាប្រើឲ្យហៅអាទាំងអស់ ហៅអាទាំងអស់ ។

យិនៈ អរ! ហៅអ្នកទោសហ្នឹង?

វ៉នៈ បាទ! ចាស់ចំណាស់ហ្នឹងក៏ដោយក៏ហៅអាដែរ ។

យិនៈ មានឌុចបញ្ជាប្អូនៗដែលវៃផ្ទាល់ដៃអ្ហាស មានទេ?

វ៉នៈ មាន ។

យិនៈ វៃអ្នកទោសអ្ហាស?

វ៉នៈ បាទ!

ឃិនៈ បើគាត់បញ្ជាត្រូវតែរ៉ៃ?

វ៉ន: ត្រូវតែរ៉ៃ អត់រ៉ៃអត់បានម៉ង ។

ភាស៊ី: ចុះបងផ្ទាល់មានដែលទទួលបញ្ជាអញ្ចឹងដែរទេ?

វ៉ន: ខ្ញុំមិនដែលទៅក្នុងហ្នឹង ពួកអ្នកចម្ការហ្នឹងគេអត់ឲ្យទៅផ្ទាល់កន្លែងគុក ដែលកន្លែងគេរ៉ៃចុះសួរចម្លើយផ្ទាល់ទេ តែបើគេដាក់គុកយប់ឡើង ឬក៏ថ្ងៃឡើងក្នុងដីហ្នឹង អាហ្នឹងដែលបាន តែបើថាគុកកន្លែងសួរចម្លើយម៉ងអត់ដែលបាន ។

ភាស៊ី: មិនដែលបានចូលទេ?

វ៉ន: អត់ឲ្យចូលទៅកុមារៗ ។

ភាស៊ី: មើលនៅក្នុងមន្ទីរហ្នឹងវាមានរបងដូច (សាក្សីនិយាយកាត់)

វ៉ន: របង ។

ឃិនៈ របងដែរ?

វ៉ន: បាទ!

ភាស៊ី: អញ្ចឹងបងនៅក្នុងរបបហ្នឹងម៉ងអ្ហេះ?

វ៉ន: នៅក្នុងហ្នឹងម៉ង ។

ភាស៊ី: ហើយនៅក្នុងហ្នឹងមានអ្នកទោសជាប់នៅក្នុងដី?

វ៉ន: ក្នុងដី ដាក់គុកក្នុងដី ។

ភាស៊ី: ហើយចុះអ្នកទោសដែលចេញម៉ោធ្វើការនោះអ្នកទោសរបៀបណាទៅ?

វ៉ន: អាហ្នឹងគេហៅសម្រាលទោសអាម៉េចនោះ ។

ឃិនៈ អូ! ទោសស្រាល?

វ៉ន: បាទ! ទោសស្រាលហើយបានគេឲ្យបញ្ចេញម៉ោធ្វើការ ។

ភាស៊ី: ហើយយប់ឡើងគេឲ្យទេដេកនៅណាទៅ?

វ៉ន: យប់ឡើងបញ្ចូលក្នុងហ្នឹងវិញ ។

ភាស៊ី: ចូលក្នុងដីវិញ?

វ៉ន: បាទ! ក្នុងដីវិញ ។

ឃិនៈ ចុះមានរស់ខ្លះទេដែលទោសស្រាលដែលឡើងធ្វើការហ្នឹងហ្មា៎ ចុងក្រោយម៉ោមានលែងខ្លះទេ?

វ៉ន: អ្ហូ! មានខ្លះដែរ តែពូតែលែងៗ អើខ្លះហើយថាលែងហើយចាប់បានម៉ោវិញថារត់ ដំណើរដែលលែងទៅថាលែងយកទៅរ៉ៃចោលមិនដឹងអីមិនដឹង ។

ភាស៊ី: ហើយបងដែលបានទទួលអីពីឌុចទេ ឌុចដែលបានផ្តល់ជាសំលៀកបំពាក់ ឬផ្តល់ជា?

ឃិនៈ ខោអាវ ស្បែកជើង មក់អីទេ?

វ៉ន: មិនៗទេ ។

ឃិនៈ ហើយបានពីណាសំលៀកបំពាក់យើង?

វ៉នៈ មានតែចេះ ខុសពីហ្នឹង កន្លែងហ្នឹងម៉ង តែមិនដឹងបានម៉ោពីណាពីណីទេ តែបើគាត់ម៉ោបើក ផ្ទាល់ក្នុងមន្ទីរហ្នឹងអត់ដែលទេ ។

វ៉ាស៊ីៈ បងមានដែលបានធ្វើដាកងការពាររបស់គាត់ផ្ទាល់ទេ?

វ៉នៈ មិនទេបងអត់ដែលទេ តែបើកូនចៅហ្នឹងគឺយើង តែបើឲ្យសេនាដៃជាមួយគាត់ហ្នឹងអត់ដែលទេ ។

វ៉ាស៊ីៈ ហើយចុះមន្ទីរហ្នឹងផ្លាស់ទៅនៅភ្នំពេញ តើបងទៅនៅភ្នំពេញជាមួយខុចដែរអត់?

វ៉នៈ ខ្ញុំបែកហើយ ខ្ញុំចេញដែរ ចេញឆ្នាំ៧៨ ។

វ៉ាស៊ីៈ គាត់ឲ្យចេញម៉ងឬក៏?

វ៉នៈ បាទ! គាត់ឲ្យកុមារៗម៉ោ ។

ឃិនៈ ឲ្យម៉ោរកគ្រួសារវិញ?

វ៉នៈ រំសាយៗ ។

ឃិនៈ រំសាយ?

វ៉នៈ បាទ! ឲ្យចូលភាគចូលអីណាៗក្មេងៗហ្នឹង ។

វ៉ាស៊ីៈ កាលហ្នុងបងចូលអី?

វ៉នៈ ខ្ញុំចូលកុមារ ។

វ៉ាស៊ីៈ ចូលអង្គភាពកុមារ?

វ៉នៈ បាទ!

វ៉ាស៊ីៈ ហើយមានដែលទៅជួបឪពុកម្តាយទេ អត់ទេអ្ហេះ?

វ៉នៈ អត់ទេ ដូចបែកឆ្នាំ៧៥ម៉ង ។

ឃិនៈ ឥឡូវពី៧៥ ៧៦ ៧៧ ប្អូនមានធ្វើការអីទៀតទេ?

វ៉នៈ ខ្ញុំពេលនោះម៉ោអត់រហូតនៅកុមារ ។

វ៉ាស៊ីៈ កងកុមារបងនៅណាដែរ?

វ៉នៈ កងកុមារខ្ញុំនៅខត្តុង ។

វ៉ាស៊ីៈ ហើយបងមាននាទីអីដែរពេលហ្នុង នៅកងកុមារហ្នឹង?

វ៉នៈ អត់មាននាទីអីទេ ខ្ញុំរែកតែដី ។

ឃិនៈ អ្ហាក!

វ៉នៈ ខ្ញុំរែកតែដីខ្លាចគេសម្លាប់ខ្លួនផង ។

ឃិនៈ អញ្ចឹងទៅវិញ?

វន៖ បាទ!

ភ៉ាស៊ី៖ ចុះឌុចអត់មានប្រាប់ថាម៉េចៗទេ?

វន៖ អត់ ។

ភ៉ាស៊ី៖ អត់មានបានធ្វើប្រវត្តិរូបអីទេបងអ្ហេះ?

វន៖ អត់ទេ ។

ឃិន៖ ទៅជាតស៊ូក្នុងគុកនោះប៉ុន្មានឆ្នាំអត់អំពើ ម៉ោធ្វើជាកូនចៅគេវិញ?

វន៖ អត់....។

ឃិន៖ ប៊ិះតាំងគេវ៉ៃចោលទៀត?

វន៖ (ស៊ើប)

ភ៉ាស៊ី៖ ក្នុងចំណោមកុមារដែលទៅជាមួយបងទាំងអស់ នៅក្នុងដែលបងបានស្គាល់អ្ហាស ហើយនៅពេលដែលចេញម៉ោវិញ តើមានកុមារប៉ុន្មានដែលបានវ៉ៃមនុស្សនៅក្រោមការបញ្ជារបស់ឌុចហ្នឹង?

វន៖ កុមារវាច្រើនដែរបង វាពីបីនាក់ហ្នឹងដែរ ប៉ុន្តែគ្រាន់តែវា ខ្ញុំចាំឈ្មោះខ្លះវាអត់ខ្លះណា ។

ឃិន៖ ឥឡូវប្អូនឯងរៀបរាប់ដែលប្អូនឯងចាំមើលឈ្មោះអីខ្លះ?

វន៖ ឈ្មោះស៊ើន សឿន ព្រោះអីពីរនាក់នេះនៅជិតភូមិគ្នា អស់ពីហ្នឹងម៉ោវាភ្លេចឈ្មោះភ្លេចអស់ទៅ វាយូរហើយមិនសូវចាំអ្ហាសបង ។

ភ៉ាស៊ី៖ ស៊ើន, សឿន ហ្នឹងមាននិយាយប្រាប់បងថា ពីការសម្លាប់មនុស្សម៉េចៗទេ?

វន៖ ទេបើឃើញតែវ៉ៃអញ្ចឹងហើយ ។

ភ៉ាស៊ី៖ អរ! បងឃើញផ្ទាល់ម៉ង់អ្ហេះ?

វន៖ បាទ! បើវ៉ៃអញ្ចឹងអ្ហើយ បញ្ជាពីគាត់ម៉ោ បញ្ជាពីឌុចម៉ោឧទាហរណ៍ថាឈ្មោះបងអញ្ចឹង អើវ៉ៃអានេះមួយអ្នាក់ អើអានេះទៅជួយអ្នាក់ មានតែចឹង ។

ឃិន៖ ហើយពេលនោះអាយុប្រហែលជា១៣ដូចជាប្អូនឯងដែរ?

វន៖ បាទ! ១៣ ១៨អីហ្នឹង ប៉ុនៗតែគ្នាហ្នឹង ។

ឃិន៖ កម្លាំងប៉ុនហ្នឹងតើឧបករណ៍អីដែលវ៉ៃសាប់ហ្នឹង?

វន៖ រំពាត់ព្រិច អត់ដែលសាប់ ឲ្យវ៉ៃស្លូរចម្លើយវ៉ៃស្លូរបាទ រំពាត់ព្រិចរំពាត់អីហ្នឹង ដំបងអីតូចធំស្រេចតែគេបោះឲ្យអាណាវ៉ៃអាហ្នឹងទៅ ។

ឃិន៖ ឲ្យជួយវ៉ៃគាត់អញ្ចឹង?

វន៖ បាទ!

ភ៉ាស៊ី៖ កុមារៗដែលឌុចនាំទៅហ្នឹងមានគ្នាប៉ុន្មាននាក់ដែរបងនៅក្នុងមន្ទីរហ្នឹង?

វិនៈ នៅក្នុងមន្ទីរហ្នឹងគ្នា៦នាក់ ។
រ៉ាស៊ីៈ យកពីភូមិបងទៅទាំងអស់ម៉ង?
វិនៈ អត់ទេ ភូមិខ្ញុំគ្នាប៉ុន្មាននាក់ ភូមិលិចៗអ្ហោះ ភូមិអម្ពាំង ភូមិតានាបអីចឹងទៅ ។
រ៉ាស៊ីៈ នៅក្នុងភូមិអម្ពាំងតែមួយហ្នឹង?
វិនៈ បាទ!
រ៉ាស៊ីៈ ប៉ុនបងកាលហ្នុងនៅក្នុងឃុំប្រាំបីមុមទេអ្ហេះ?
វិនៈ ខ្ញុំឃុំប្រាំបីមុម ។
ឃិនៈ អញ្ចឹងរស់ច្រើនយ៉ាងកុមារៗសម័យហ្នុង?
វិនៈ ទេឥឡូវបាត់អស់ទៅហើយ មិនដឹងស្លាប់មិនដឹងអីបើយូរហើយអត់ឃើញមុខឃើញមាត់ផង ។
រ៉ាស៊ីៈ ហើយបងរាល់ថ្ងៃដឹងថាបងនៅរស់ឬស្លាប់ហើយ?
វិនៈ ថាបាត់ៗមុខថាស្លាប់ហើយ តែឥឡូវពុំថារស់ នៅរស់ហ្នឹងទៅ ។
រ៉ាស៊ីៈ ចុះបើសិនជាបងបានជួបគាត់ តើបងគិតថាគាត់ស្គាល់បងទេ?
វិនៈ មើលទៅបែបដំណើរមិនដឹងទេ តែគ្រាន់ថាមុខខ្ញុំ ខ្ញុំថាខ្ញុំស្គាល់គាត់ហើយ ។
រ៉ាស៊ីៈ បងឃើញដឹងថាស្គាល់ម៉ងណោះ?
វិនៈ ខ្ញុំឃើញខ្ញុំស្គាល់ហើយ ។
រ៉ាស៊ីៈ មានត្រង់ណាចំណាំទេបង?
វិនៈ បាទ!
រ៉ាស៊ីៈ គាត់មានត្រង់ណាចំណាំទេ?
វិនៈ ចំណាំ ទេពិបាកសន្និដ្ឋានដែរចំណាំហ្នឹង ។
ឃិនៈ គាត់ហ្នឹងជាមនុស្សសាមញ្ញធ្លាប់លេងសើចឬក៏ជាកាចសាហាវអី មុខក្រញៀវអី?
វិនៈ ទេគាត់ហ្នឹងអត់សូវគាប់គួរកអ្នកណាទេ មុខគាត់ចងជាប់ដែរហ្នឹង ។
ឃិនៈ ចងជាប់ដែរ?
វិនៈ បាទ! ចងជាប់ដែរ ។
ឃិនៈ គាត់និយាយលេងតែជាមួយចាស់ៗទេចឹងអ្ហោះ?
វិនៈ បាទ!
ឃិនៈ ជាមួយអ្នកទោសអី?
វិនៈ តែបើថានេះហ្នឹងគាត់ចងជាប់ដែរហ្នឹង និយាយម៉ាត់ៗដែរហ្នឹង ចង់តែខ្លាចដុំៗហ្នឹងអ្ហាស លេងមុខណាស់ ។
រ៉ាស៊ីៈ បងឃើញគាត់សម្លាប់មនុស្សប៉ុន្មានដងដែរបង?

វិនៈ ទេបង សម្លាប់នោះវាឃើញច្រើនដងដែរហើយ ។

រ៉ាស៊ីៈ ច្រើនដងដែរ?

វិនៈ រាប់មិនអស់ដែរ ។

ឃិនៈ វារាប់មិនឈ្នះទៅហើយ?

វិនៈ បាទ!

ឃិនៈ បើអញ្ចឹងគាត់សួរចម្លើយរាល់ថ្ងៃម៉ងឌុចហ្នឹង?

វិនៈ រាល់ថ្ងៃ អត់មានពេលវេលាទេ ថ្ងៃ យប់ ។

រ៉ាស៊ីៈ គាត់មានដែលឡើងទៅភ្នំពេញទេ?

វិនៈ អត់ដែលទេបង ។

រ៉ាស៊ីៈ បើឡើងទៅប្រជុំឡើងទៅអីមានទេ?

វិនៈ អត់ដែលទេ ដែលនៅក្នុងប្រជុំក្នុងហ្នឹងម៉ង ។

រ៉ាស៊ីៈ ប្រជុំក្នុងហ្នឹងម៉ង?

វិនៈ បាទ! ក្នាងងហៅប្រជុំហ្នឹងតែម៉ង ។

រ៉ាស៊ីៈ ប្រជុំហ្នឹងបងមានដឹងថាគេប្រជុំពីផែនការអីទេ?

វិនៈ មានផែនការអី មានតែផែនការលាក់ការណ៍តែប៉ុនហ្នឹង ហើយហ្នឹងមើលខុសត្រូវតែប៉ុនហ្នឹង អត់មានរឿងអីទៀតដែលក្រៅអំពីហ្នឹងអត់ ។

ឃិនៈ អញ្ចឹងអ្នកទោសនៅទីនេះគ្មានអ្នកណារត់រួចម្នាក់ទេណោះ?

វិនៈ បានចេញក្នុងហ្នឹងហើយកម្រណាស់បង ។

ឃិនៈ ចូលជាប់ហ្នឹងហើយកម្ររត់ណាស់?

វិនៈ បាទ! កម្រចេញណាស់ ។

ឃិនៈ ហើយចុះអាអ្នកទោសស្រាលហ្នឹងក៏អត់រត់ដែរចឹង ដែលអត់ដាក់ច្រវាក់ហ្នឹងអ្នាស?

វិនៈ ស្រាលហ្នឹង ដែលគេដាក់ឲ្យធ្វើការហ្នឹង ស្រាលហ្នឹងមានដែរ ។

រ៉ាស៊ីៈ មានរត់ដែរ?

វិនៈ មានរត់ ខ្លះក៏មានបញ្ចេញម៉ោវិញដែរ ទៅខាងណា ទៅរស់មិនដឹង ចេញទៅស្លាប់មិនដឹង ។

ឃិនៈ អូ! ចេញសម្លាប់ក៏មិនដឹង?

វិនៈ បាទ!

ឃិនៈ ឲ្យតែធ្វើខុសគេយកចេញទៅ?

វិនៈ បាទ! ធ្វើការៗចឹងត្រូវឈ្មោះប៉ុន្មាននាក់ៗហៅទៅ គេដឹកឡានទៅដាក់ឡានទៅ ។

ឃិនៈ អូ! ដាក់ឡានផង?

វ៉នៈ	បាទ! ជួនកាលបណ្ដើរទៅ ប៉ុន្ដែមិនដឹងជាទៅខាងណា ។
ភាស៊ីៈ	រហូតមកដល់បច្ចុប្បន្នបងមានអារម្មណ៍ម៉េចដែរ ពេលដែលបងនឹកឃើញរឿងរ៉ាវកាលនៅធ្វើជាមួយខុចអ្នាស?
វ៉នៈ	នឹកឃើញស្ដាយខ្លួន ។
ភាស៊ីៈ	ស្ដាយយ៉ាងម៉េចខ្លះទៅ?
វ៉នៈ	ស្ដាយដែលកំហុស ហើយម្យ៉ាងក៏នៅក្មេងខ្ចី ហើយម្យ៉ាងទៀតក៏នឹកឃើញដល់ ដែលមនុស្សហាក់បីដូចសត្វ អត់មានដឹងកំហុសអីសោះឲ្យវ៉ៃចោល ឆ្អឹកគរ ។
យិនៈ	ប្អូនអាណិតអាសូរអ្នកស្លាប់ហ្នុងដែរចឹង?
វ៉នៈ	បាទ!
ភាស៊ីៈ	បងមានបាននិយាយរឿងរ៉ាវហ្នឹងប្រាប់ឪពុកម្ដាយបងទេ?
វ៉នៈ	ខ្ញុំបាននិយាយប្រាប់ ។
យិនៈ	អញ្ចឹងណោះ?
ភាស៊ីៈ	គាត់ថាម៉េច?
វ៉នៈ	គាត់ថា មានបន្ដែមថា បើកូនឯងចេញម៉ោច្បាស់ជាស្លាប់ ។
ភាស៊ីៈ	បើជ្រុលហើយចេះតែនៅទៅ?
វ៉នៈ	បាទ!
យិនៈ	អូ! អាពេលចេញទៅធ្វើការហ្នឹងអ្នាស?
វ៉នៈ	បាទ!
យិនៈ	អូ! អាពេលហ្នឹងច្បាស់ហើយបើចេញម៉ោនោះ ។
ភាស៊ីៈ	បងមានដែលបានរៀនវគ្គនយោបាយវគ្គអីនៅក្នុងមន្ទីរ១៣ហ្នឹងទេ?
វ៉នៈ	អត់ដែលទេបង ។
យិនៈ	អត់ដែលទេ?
វ៉នៈ	ប៉ិនអក្សរមអត់ចេះផង ។
យិនៈ	ចុះអាយុទ្ធសាស្ដ្រវិធីប្រយុទ្ធការបាញ់កាំភ្លើងអី របៀបទ័ព របៀបទាហានមានបង្រៀនទេ?
វ៉នៈ	ហ្នឹងបានម៉ោបង្រៀន ក្រោយពីហ្នឹងម៉ោបានបង្រៀនចូលទ័ពចូលអីហ្នឹង ចេះដឹង ។
យិនៈ	ចូលទ័ពខាងណា?
វ៉នៈ	ចូលទ័ពយើងហ្នឹង ទ័ពយើងឥឡូវៗហ្នឹង ។
យិនៈ	ក្រោយ៧៩ហ្នឹងអ្ហេះ?
វ៉នៈ	បាទ!

ឃិនៈ បានម៉ោធ្វើទីពខាងនេះវិញ?

វ៉ន: បាទ!

វ៉ាស៊ីៈ តើបងមានអារម្មណ៍អីគុំគួនជាមួយឌុចដែរទេ?

វ៉ន: នឹកឃើញគួចចិត្តដែរ តូចចិត្តមិនដឹងធ្វើម៉េច ។

វ៉ាស៊ីៈ ចុះបើសិនជាមានតុលាការកាត់ទោសគាត់ តើបងចង់ឲ្យមានតុលាការកាត់ទោសគាត់ទេ?

វ៉ន: ឲ្យតុលាការធ្វើតាមច្បាប់គាត់ទៅ តាមកំហុសពួកគាត់ ។

វ៉ាស៊ីៈ បងយល់ថាគាត់ជាមនុស្សយ៉ាងម៉េចដែរ?

វ៉ន: ខ្ញុំថាមនុស្សគាត់នេះបើសិនជាក្នុង ខ្ញុំផ្ទាល់ម៉ង តាមខ្ញុំពិនិត្យគិតមើលទៅខ្ញុំថាមនុស្សហ្នឹងមិនមែន ជាធម្មតាទេ បើនឹកឃើញការធម្មតា កាលពីជំនាន់នោះគាត់នឹកឃើញខ្លះៗអ្វាស ។

វ៉ាស៊ីៈ គាត់នឹកឃើញម៉េច?

វ៉ន: នៅនឹកឃើញថាមនុស្សជាសត្វទៅវិញ ។

វ៉ាស៊ីៈ អរ! គាត់នឹកឃើញថាអញ្ចឹង?

វ៉ន: បាទ!

ឃិនៈ វាគ្មានអីទេ ដែលថាមេត្តាអាណិតអាសូរអីគឺគ្មានសោះណោះ?

វ៉ន: បាទ!

ឃិនៈ បើអញ្ចឹងបានន័យថាគាត់នេះវាមិនធម្មតា?

វ៉ន: បាទ!

ឃិនៈ មិនធម្មតាបានន័យថាសាហាវណាស់ របៀបដូចសត្វមិនដឹងខុសត្រូវ លួនិយាយអញ្ចឹងត្រូវ ហើយ ។

វ៉ាស៊ីៈ បងចង់ឲ្យ បើសិនជាមានតុលាការបងចង់ឲ្យតុលាការកាត់ទោស ឬក៏ដាក់គុកគាត់យ៉ាងម៉េចដែរ បង?

វ៉ន: ហ្អឺ! អាហ្នឹងធ្វើតាមច្បាប់កំហុសគាត់ទៅ ។

វ៉ាស៊ីៈ ចុះបងផ្ទាល់បងយល់ថាគាត់មានកំហុសអីដែរ?

វ៉ន: កំហុសសម្លាប់មនុស្សហ្នឹងម៉ង ។

វ៉ាស៊ីៈ បងឃើញផ្ទាល់នឹងភ្នែកម៉ងឃើញគាត់សម្លាប់មនុស្ស?

វ៉ន: បាទ!

ឃិញៈ សម្លាប់របស់គាត់ហ្នឹងបើតាមពត៌មានថា ដូចជាអីនេះថា អាខុសក៏សម្លាប់ អាត្រូវក៏សម្លាប់ មិនដឹងថាខុស មិនដឹងថាត្រូវគឺសម្លាប់ទាំងអស់?

វ៉ន: បាទ!

ឃិនៈ អញ្ចឹងបានន័យថាអត់យុត្តិធម៌ទេមែនទេ?

វនៈ បាទ! អានេះនិយាយតាមចិត្តគាត់ចង់ម៉ង ។

ភ៉ាស៊ីៈ ខ្ញុំចង់សួរបងបម្តងទៀត តើឌុចហ្នឹងបានសម្លាប់មនុស្សប៉ុន្មាននាក់ដែរ?

វនៈ មិនដឹងជាប៉ុន្មាន រាប់មិនអស់ទេដំណើរ ខ្ញុំឃើញហ្នឹងវាច្រើន ឃើញហ្នឹងវាច្រើនពេក ច្រើនណាស់ទៅហើយ ។

ភ៉ាស៊ីៈ កាលហ្នុងគាត់មានប្រពន្ធនៅ ឌុចហ្នឹងមានប្រពន្ធនៅ?

វនៈ មាន ។

ភ៉ាស៊ីៈ មានកូននៅ?

វនៈ ហ្អឺ! កូនហ្នឹងមិនដឹងជាមានអត់ទេ ។

ភ៉ាស៊ីៈ ប្រពន្ធគាត់ឈ្មោះអី?

វនៈ អត់ស្គាល់ឈ្មោះទេ ។

ភ៉ាស៊ីៈ ឃើញតែមុខអ្ហេះ?

វនៈ ឃើញតែមុខ ។

ភ៉ាស៊ីៈ រាងរៅគាត់ម៉េចទៅ?

ឃិនៈ រាងសដូចចិនទេ ។

វនៈ មិនសប៉ុន្មានទេបង អត់សទេ ។

ឃិនៈ អត់សទេអ្ហេះ?

វនៈ បាទ!

ឃិនៈ ចិនខ្មែរទេ?

វនៈ ខ្មែរទេ ។

ភ៉ាស៊ីៈ កាចទេប្រពន្ធគាត់ ឬក៏មុស្សធម្មតា?

វនៈ មិនដឹងដែរ ព្រោះប្រពន្ធខាងណោះប្រពន្ធនៅផ្ទះ ។

ភ៉ាស៊ីៈ ប្រពន្ធនៅផ្ទះ?

វនៈ បាទ!

Xin³ EN+ ´cg;sYcugeRkaybnþicNa GrKuNb¥ÚnehIy faDuchñwgmanpÞHenAEk,rhñwgmYy etI \LÚvpÞHhñwgKat;enAsl;ral;éf¶eTpÞHKat;hñwg?

វនៈ ទេអត់បានដឹង ។

ឃិនៈ នៅភូមិហ្នុង អត់បានដឹងទេណោះ?

វនៈ នៅឆ្ងាយដែរ ។

ឃិនៈ នៅឆ្ងាយដែរ ។

ភ៉ាស៊ីៈ  បងមានអីចង់បន្ថែម ឬក៏មានយោបល់អីបងចង់បញ្ចេញ?

វ៉នៈ  អត់មានបន្ថែមអីទេ ខ្ញុំសុំតែបន្ថែមថាតុលាការកាត់ទោសហ្នឹងឲ្យគាត់នេះទៅ .......... មើលទៅលប់លៀងកំហុសគាត់មិនជ្រះទេ ច្រើនណាស់ ។

ភ៉ាស៊ីៈ  អញ្ចឹងអរគុណបងច្រើនបង ។  ពេល៧៩បងចេញម៉ោបងចូលធ្វើការជាទាហាននៅក្នុងសម័យយើងឥឡូវនេះ?

វ៉នៈ  បាទ!

ភ៉ាស៊ីៈ  ចុះរហូតដល់បច្ចុប្បន្នបងឈប់ហើយ?

វ៉នៈ  បច្ចុប្បន្នឈប់ហើយ ។

ភ៉ាស៊ីៈ  ឈប់ហ្នឹងរំសាយក៏អី?

វ៉នៈ  អត់ទេខ្ញុំឈប់ ។

ឃិនៈ  សុំឈប់ម៉ង?

វ៉នៈ  បាទ!

ឃិនៈ ឈប់មុនគេរំសាយទៀត?

វ៉នៈ  បាទ!

ភ៉ាស៊ីៈ  កាលហ្នុងបងធ្វើទាហាននៅណាដែរ?

វ៉នៈ  ខ្ញុំធ្វើទាហាននៅប៉ៃលិន កងពល១៩៦ ។

វ៉នៈ  នៅក្នុងវរៈណាដែរបង?

វ៉នៈ  នៅវរៈសេនាធំលេខ២ កងពល១៩៦ ។

ភ៉ាស៊ីៈ  របស់រដ្ឋកម្ពុជាយើងហ្នឹង?

វ៉នៈ  បាទៈ

ភ៉ាស៊ីៈ  ចុះម៉េចបាននៅប៉ៃលិនណោះវិញ?

វ៉ន  កាលពីហ្នុងដឹងអាម៉េចទៅអីហ្នុង ។

ភ៉ាស៊ីៈ  មេបងឈ្មោះអីទៅ?

វ៉នៈ  ញ៉ឹក ហួន ។

ឃិនៈ អរ! សម័យ ញ៉ឹក ហួន ។

ភ៉ាស៊ីៈ  ហ្នឹងប្រធានអីគេ?

វ៉នៈ  ប្រធានកងពល ។

ភ៉ាស៊ីៈ  ប្រធានកងពលម៉ង?

វ៉នៈ  បាទ!

ភ៉ាស៊ីៈ កាលហ្នឹងបងមានប្រពន្ធនៅ?

វិនៈ នៅ ។

ភ៉ាស៊ីៈ ទឹមមានឥឡូវទេ?

វិនៈ បាទ!

ភ៉ាស៊ីៈ ប្រពន្ធបងឈ្មោះអីដែរ?

វិនៈ ឈ្មោះរ៉ុម ។

ឃិទីៈ កូនចៅប៉ុន្មាននាក់ហើយ?

វិនៈ ៧ ។

ឃិនៈ ៧នាក់ហើយ?

វិនៈ បាទ!

ឃិនៈ ប្អូនឯងឥឡូវអាយុប៉ុន្មានហើយ?

វិនៈ អាយុ៤០ជាងហើយ ។

ភ៉ាស៊ីៈ ប្រុសប៉ុន្មាន ស្រីប៉ុន្មាន?

វិនៈ ប្រុស៣ ស្រី៤ ។

ភ៉ាស៊ីៈ អញ្ជឹងអរគុណបងច្រើនអញ្ជឹងបងណា ។

វិនៈ បាទៗ!